# របាយការណ៍អង្កេតយេនឌ័រ និងបរិស្ថានកម្ពុជាឆ្នាំ២០២៤

## ព្រះរាជាណាចក្រកម្ពុជា



UN WOMEN | WOMEN COUNT

វិទ្យាស្ថានជាតិស្ថិតិ
National Institute of Statistics

# បុព្វកថា

អង្កេតយេនឌ័រ និងបរិស្ថានកម្ពុជាឆ្នាំ២០២៤ គឺជាសមិទ្ធផលថ្មីដ៏សំខាន់មួយ ដែលត្រូវបានរៀបចំធ្វើឡើងជាលើកដំបូងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អង្កេតនេះ ត្រូវបានដឹកនាំធ្វើដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដែលបានផ្ដល់នូវទិន្នន័យទូលំទូលាយ លម្អិត និងគ្រប់ជ្រុងជ្រោយ ដោយមានការបែងចែកតាមភេទទាក់ទងនឹងសមភាពយេនឌ័រ និងស្ថិរភាពបរិស្ថាន។ មូលដ្ឋានគ្រឹះទាំងនេះ មានសារៈសំខាន់ក្នុងការស្វែងយល់ពីស្ត្រី និងបុរស ដែលរងផលប៉ះពាល់ខុសគ្នានៃការប្រែប្រួលអាកាសធាតុ ការបាត់បង់ជីវចម្រុះ និងការបំពុលបរិស្ថាន ដើម្បីរៀបចំគោលនយោបាយ និងកម្មវិធីនានា ដែលធានាបាននូវភាពធន់ និងសមភាព។

ក្នុងដំណើរការការសម្ភាសន៍ស្រង់ទិន្នន័យនៃអង្កេតនេះ វិទ្យាស្ថានជាតិស្ថិតិ បានប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីជួយសម្រួលដល់ការងារបានទាន់ពេលវេលា ពង្រឹងភាពជឿជាក់ និងសុវត្ថិភាពនៃការប្រមូលទិន្នន័យ ព្រមទាំងបង្ហាញពីការត្រៀមខ្លួនរបស់កម្ពុជាក្នុងការធ្វើទំនើបកម្មប្រព័ន្ធស្ថិតិឱ្យស្របតាមស្តង់ដាជាសកល។ លទ្ធផលនៃអង្កេតនេះ នឹងផ្ដល់ទិន្នន័យសម្រាប់ការតាមដាន និងត្រួតពិនិត្យ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា។ របាយការណ៍នៃការអង្កេតនេះ នឹងផ្ដល់វឌ្ឍនភាពយេនឌ័រជូនដល់អង្គការសហប្រជាជាតិ និងជួយឱ្យប្រទេសកម្ពុជាសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០។

របាយការណ៍ការអង្កេតយេនឌ័រ និងបរិស្ថានកម្ពុជាឆ្នាំ២០២៤ មិនត្រឹមតែជាមូលដ្ឋានសម្រាប់រៀបចំគោលនយោបាយជាតិតែប៉ុណ្ណោះទេ ថែមទាំងជាឧបករណ៍លើកកម្ពស់សមភាពយេនឌ័រ និងស្ថិរភាពបរិស្ថានផងដែរ។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា របាយការណ៍នេះ នឹងត្រូវយកទៅប្រើប្រាស់យ៉ាងទូលំទូលាយដោយក្រសួងស្ថាប័ន អ្នកស្រាវជ្រាវ និងដៃគូអភិវឌ្ឍនានា សម្រាប់រួមចំណែកក្នុងការសម្រេចបានគោលដៅអភិវឌ្ឍជាតិ និងចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាល។

សមិទ្ធផលដ៏ត្រចះត្រចង់នេះ សម្រេចទៅបានដោយមានការសហការយ៉ាងជិតស្និតរវាងក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍ និងអ្នកជំនាញបច្ចេកទេសពាក់ព័ន្ធ ព្រមទាំងទីភ្នាក់ងារសហប្រជាជាតិលើកកម្ពស់យេនឌ័រ និងពង្រឹងភាពអង់អាចដល់ស្ត្រី តាមរយៈ កម្មវិធី Women Count, កម្មវិធី EmPower និង UNEP ដែលបានផ្ដល់នូវជំនួយហិរញ្ញវត្ថុនិងបច្ចេកទេស និងការសម្របសម្រួលស្ដីពីសមភាពយេនឌ័រ និងសិទ្ធិមនុស្ស ក្នុងការកាត់បន្ថយហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងបរិស្ថាន។ ក្នុងនោះ ក្រសួងកិច្ចការនារី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ក៏បានជួយសម្របសម្រួលយ៉ាងសកម្មលើការងារសមភាពយេនឌ័រ សិកម្ម ជីវចម្រុះ និងការអភិរក្ស។

ក្រសួងផែនការ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលអូស្ត្រាលី បារាំង អៀរឡង់ និងស៊ុយអែត ព្រមទាំងមូលនិធិ Bill និង Melinda Gates ដែលផ្ដល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ដំណើរការអង្កេតនេះ និងថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសនៃវិទ្យាស្ថានជាតិស្ថិតិ មន្ត្រីថ្នាក់ក្រោមជាតិ មន្ត្រីត្រួតពិនិត្យ អាជ្ញាធរឃុំ សង្កាត់ និងមន្ត្រីសម្ភាសន៍ទាំងអស់ ដែលបានខិតខំប្រឹងប្រែងធានាបានគុណភាព និងទាន់ពេលវេលា ព្រមទាំងថ្លែងអំណរគុណដល់អ្នកដែលបានចូលរួមសម្ភាសន៍ និងចែករំលែកបទពិសោធន៍ ដែលធ្វើឱ្យការអង្កេតយេនឌ័រ និងបរិស្ថានកម្ពុជាឆ្នាំ២០២៤ បញ្ចប់ទៅដោយរលូន និងទទួលបានជោគជ័យ។

រដ្ឋមន្ត្រី

ក្រសួងផែនការ
រាជធានីភ្នំពេញ
ខែសីហា ឆ្នាំ២០២៥

ប៊ិន ត្រាឈៃ

# សេចក្តីថ្លែងអំណរគុណ

អង្កេតយេនឌ័រ និងបរិស្ថានកម្ពុជា (២០២៤) អនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិ (NIS) ក្រោមការដឹកនាំប្រតិបត្តិដោយឯកឧត្តម **ទ្រី ឫទ្ធា** នាយកវិទ្យាស្ថានជាតិស្ថិតិ។ អង្កេតនេះ គ្រប់គ្រងដោយលោក **សុក កុសល** នាយករងវិទ្យាស្ថានជាតិស្ថិតិ ដែលទទួលខុសត្រូវលើការរៀបចំផែនការ ប្រតិបត្តិការ និងការវិភាគ លោកស្រី **ធន រដ្ឋា** អគ្គនាយករង នៃនាយកដ្ឋានអភិវឌ្ឍន៍សង្គម លោកស្រី **តែ រួចលីម** ប្រធាននាយកដ្ឋានផែនការ និងស្ថិតិនៃក្រសួងកិច្ចការនារី លោក **ង៉ន លីហួរ** អនុប្រធានការិយាល័យ លោក **ស្នួង គា** តំណាងពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលោកស្រី **កែវ នាទី** អនុប្រធាននាយក នៃក្រសួងបរិស្ថាន។

សូមថ្លែងអំណរគុណចំពោះក្រុមការងាររៀបចំសំណាកគំរូ ដែលដឹកនាំដោយ លោក **សុក កុសល** ព្រមទាំងលោក **ចាវ ភារ** ដែលបានគាំទ្រលើការគ្រប់គ្រងម៉ាស៊ីនមេសម្រាប់ការរក្សាទុកទិន្នន័យក្នុងអំឡុងពេលប្រមូលទិន្នន័យ។ លោក **Sanghyun Jeon** និងលោកស្រី **Tsz Yu Chang** ដែលធ្វើការនៅអង្គភាពអង្គការសហប្រជាជាតិសម្រាប់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី (UN Women) បានគ្រប់គ្រងដំណើរការការរៀបចំអង្កេត និងការសម្ភាសដោយប្រើកុំព្យូទ័រជំនួយ (CAPI)។

សូមថ្លែងអំណរគុណជាពិសេសដល់ក្រុមការងារ UN Women ក្រោមការដឹកនាំដោយលោកស្រី **Sara Duerto Valero** ដែលបានផ្តួចផ្តើមគំនិតសម្រាប់អង្កេត និងផ្តល់មូលនិធិសម្រាប់អង្កេតតាមរយៈកម្មវិធី Women Count។ យើងក៏សូមថ្លែងអំណរគុណដល់លោកស្រី **ឃុន សុភា** លោកស្រី **សុវណ្ណ រ័ត្នវតី** និងលោកស្រី **ឈន ឈុនលី** ពីការិយាល័យ UN Women ប្រចាំកម្ពុជាសម្រាប់ការ សម្របសម្រួលក្នុងការរៀបចំអង្កេតនេះ។

របាយការណ៍អង្កេតដឹកនាំរៀបចំដោយលោកស្រី **Sara Duerto Valero**, **Tsz Yu Chang**, **Sanghyun Jeon**, Sneha Kaul និងលោក **សុក កុសល** ។ ការកែសម្រួលរបាយការណ៍ត្រូវបានអនុវត្តដោយ **Mary Ann Perkins** និងការរៀបចំរបាយការណ៍ត្រូវបានអនុវត្តដោយ **Blossom** ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ការគាំទ្រហិរញ្ញវត្ថុពី**រដ្ឋាភិបាលអូស្ត្រាលី បារាំង អៀរឡង់** និង**រដ្ឋាភិបាលស៊ុយអែត** ព្រមទាំង**មូលនិធិ Bill និង Melinda Gates**។

ជាចុងក្រោយ សូមថ្លែងអំណរគុណដល់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ អាជ្ញាធររាជធានីខេត្ត ប្រធានភូមិ មន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍ ក្នុងការប្តេជ្ញាចិត្ត និងការខិតខំប្រឹងប្រែងដើម្បីទទួលបានទិន្នន័យដែលមានគុណភាព និងទាន់ពេលវេលា។ យើងក៏សូមថ្លែងអំណរគុណដល់ប្រជាពលរដ្ឋកម្ពុជា ដែលបានចំណាយពេលវេលាសម្រាប់ឆ្លើយសំណួរអង្កេតនេះ។

# មាតិកា


| | |
|---|---|
| ពាក្យកាត់ | ៤ |
| **សេចក្តីផ្តើម** | **៥** |
| គោលបំណង និងវិសាលភាពអង្កេត | ៦ |
| វិសាលភាពភូមិសាស្ត្រ | ៧ |
| កាលបរិច្ឆេទយោង | ៧ |
| វិធីសាស្ត្រជ្រើសរើសសំណាកគំរូ | ៧ |
| ក្របខ័ណ្ឌសំណាកគំរូ | ៨ |
| ប្រតិបត្តិការអង្កេត | ១០ |
| ដំណើរការវិភាគទិន្នន័យ | ១១ |
| ចរិតលក្ខណៈប្រជាសាស្ត្រ | ១២ |
| លទ្ធផល | ១៤ |
| ផ្នែកទី១ ៖ គ្រោះមហន្តរាយ | ១៤ |
| ផ្នែកទី ២៖ ការប្រែប្រួលអាកាសធាតុ | ២៩ |
| ផ្នែកទី ៣៖ ជីវភាពរស់នៅប្រចាំថ្ងៃដែលទាក់ទងនឹងបរិស្ថាន | ៤២ |
| ផ្នែកទី៤ ៖ ការអភិរក្ស និងការវិចរិលបរិស្ថាន | ៦០ |
| សេចក្តីសន្និដ្ឋាន និងជំហានបន្ទាប់ | ៩៣ |

# ពាក្យកាត់

| | |
|---|---|
| CAPI | ការសម្ភាសន៍ដោយប្រើប្រាស់កម្មវិធីជំនួយកុំព្យូទ័រ |
| GES | ការអង្កេតយេនឌ័រ និងបរិស្ថាន |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| PHC | ជំរឿនប្រជាជន និងគ្រួសារ |
| TVET | ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| UN Women | អង្គការសហប្រជាជាតិសម្រាប់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី |

# សេចក្តីផ្តើម

អង្កេតយេនឌ័រ និងបរិស្ថានកម្ពុជាឆ្នាំ ២០២៤ (GES) គឺជាអង្កេតថ្នាក់ជាតិ ដែលស្វែងយល់ពីទំនាក់ទំនងរវាងស្ត្រី និងបុរសជាមួយបរិស្ថាន។ អង្កេតនេះបានប៉ាន់ប្រមាណការប៉ះពាល់កម្រិតគ្រួសារ និងបុគ្គលលើផលវិបាកភ្លាមៗនៃព្រឹត្តិការណ៍គ្រោះមហន្តរាយថ្មីៗ និងផលប៉ះពាល់យូរអង្វែងនៃការប្រែប្រួលអាកាសធាតុ ទន្ទឹមនឹងនេះក៏បានវាយតម្លៃពីឥទ្ធិពលទៅវិញទៅមកទាំងស្ត្រី និងបុរសលើបរិស្ថាន តាមរយៈសកម្មភាពសេដ្ឋកិច្ចប្រចាំថ្ងៃ និងជីវភាពរស់នៅ។

អង្កេតយេនឌ័រ និងបរិស្ថានកម្ពុជាឆ្នាំ ២០២៤ (GES) ត្រូវបានអនុវត្តដោយ វិទ្យាស្ថានស្ថិតិ (NIS) ដោយមានការគាំទ្រពីអង្គការសហប្រជាជាតិ ទទួលបន្ទុកផ្នែកសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី (UN Women)។ ការអង្កេតនេះផ្អែកតាមសេចក្តីណែនាំអន្តរជាតិ ដែលបានផ្តល់ដោយ UN Women រួមមានម៉ូឌុលសំណួរសម្រាប់វាស់វែងទំនាក់ទំនងរវាងភេទ និងបរិស្ថាន[១] និងបានកែប្រែឱ្យសមស្របនឹងបរិបទនៅកម្ពុជា ដោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធជាតិដូចជា គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងរ៉ែ និងថាមពល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អង្គការសង្គមស៊ីវិល ដូចជា Landesa វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កម្ពុជា (CDRI) និង HEKS/EPER (ជំនួយសាសនាស្វីស)។ អង្គការអន្តរជាតិ និងដៃគូផ្សេងទៀតដែលបានចូលរួមក្នុងការពិគ្រោះរួមមាន៖ ភាពជាដៃគូកម្ពុជា អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED) អង្គការជំនួយអភិវឌ្ឍន៍អាល្លឺម៉ង់ (GIZ) Plan International អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អង្គការស្បៀងអាហារពិភពលោក(WFP)។ លទ្ធផលដែលរំពឹងទុកពីការអង្កេតនេះ គឺនឹងផ្តល់ទិន្នន័យបែងចែកតាមភេទ ដែលអាចប្រើប្រាស់សម្រាប់គ្រប់គ្រងនិងតាមដានគោលនយោបាយនៅកម្រិតជាតិ និងអន្តរជាតិ។ ទិន្នន័យនេះនឹងអភិវឌ្ឍបន្ថែមលើការអនុវត្តន៍គោលនយោបាយសំខាន់ៗ ដូចជា៖ ផែនការយុទ្ធសាស្ត្រជាតិឆ្នាំ ៥ សម្រាប់ការលើកស្ទួយសមភាពយេនឌ័រ និងស្ត្រី-ក្មេងស្រី គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ ២០៣០ សន្ទស្សន៍សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

ការប្រមូលទិន្នន័យ និងការវិភាគបានធ្វើឡើងបន្ទាប់ពីមានការកើនឡើងកំដៅខ្លាំង និងគ្រោះរាំងស្ងួតជាបន្តបន្ទាប់នៅក្នុងតំបន់ជាច្រើននៅកម្ពុជា។ នៅឆ្នាំ ២០២៤ កម្ពុជាបានកត់សម្គាល់ឃើញថាសីតុណ្ហភាពកើនឡើងខ្ពស់ ក្នុងរយៈពេល១៧០ឆ្នាំ។ សីតុណ្ហភាពកើនឡើងខ្ពស់ និងភ្លៀងតិច បានបង្កើតភាពរាំងស្ងួតជាយូរអង្វែង ដែលបណ្តាលឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ច បរិស្ថាន និងសុខភាពសាធារណៈ។ លទ្ធផលនៃការអង្កេតនេះបានឆ្លុះបញ្ចាំងពីភាពងាយរងគ្រោះចំពោះគ្រោះធម្មជាតិ ដូចជា រាំងស្ងួត អាកាសធាតុក្តៅខ្លាំង ព្យុះ និងខ្យល់កន្ត្រាក់

---

[១] កម្រងសំណួរគំរូ៖ ការវាស់ស្ទង់ Nexus រវាងយេនឌ័រ និងបរិស្ថាន.

ផលប៉ះពាល់រយៈពេលវែងនៃការប្រែប្រួលអាកាសធាតុ និងបទពិសោធន៍ផ្ទាល់របស់ស្ត្រី និងបុរស ដែលត្រូវប្រឈមជារៀងរាល់ថ្ងៃជាមួយបញ្ហាបរិស្ថានទាំងនេះ។

## គោលបំណង និងវិសាលភាពអង្កេត

គោលបំណងសំខាន់នៃអង្កេតយេនឌ័រ និងបរិស្ថាន (GES)គឺដើម្បីបង្កើតទិន្នន័យស្ថិតិតំណាងជាតិដែលមានច្រើនសណ្ឋានតាមភេទ។ រួមមានទិន្នន័យកម្រិតគ្រួសារអំពីលក្ខណៈលំនៅដ្ឋាន និងទិន្នន័យកម្រិតបុគ្គលលើប្រធានបទបរិស្ថានជាច្រើនទាំងបុរស និងស្ត្រី។ ទិន្នន័យកម្រិតបុគ្គល គ្របដណ្តប់លើពិសោធន៍នៃការប៉ះពាល់គ្រោះមហន្តរាយ និងគ្រោះថ្នាក់ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ កសិកម្ម និងការប្រើប្រាស់ដីធ្លី ការចូលរួមក្នុងជីវភាពរស់នៅដែលទាក់ទងនឹងបរិស្ថាន ការងារនៅក្នុងសេដ្ឋកិច្ចបៃតង ការចូលរួមក្នុងការសម្រេចចិត្តផ្នែកបរិស្ថាន កម្មសិទ្ធិទ្រព្យសម្បត្តិ និងការធ្វើដំណើរ។ GES ឆ្នាំ២០២៤ ភាគច្រើនប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំអន្តរជាតិ ដូចដែលបានរៀបរាប់នៅក្នុងគំរូកម្រងសំណួរ សម្រាប់ការវាស់វែង រវាងយេនឌ័រ និងបរិស្ថាន ស្របជាមួយបរិបទនៅកម្ពុជា។

| ម៉ូឌុល | សេចក្តីពិពណ៌នា | កម្រិត |
|---|---|---|
| ១ | បញ្ជីសមាជិកគ្រួសារ | កម្រិតគ្រួសារ |
| ២ | លក្ខណៈផ្ទះសម្បែង | កម្រិតគ្រួសារ |
| ៣ | លក្ខណៈបុគ្គល | កម្រិតបុគ្គល |
| ៤ | ផលប៉ះពាល់ដោយគ្រោះមហន្តរាយ ការរៀបចំទុកមុន និងផលវិបាក | កម្រិតបុគ្គល |
| ៥ | ផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុ និងការរៀបចំទុកមុន | កម្រិតបុគ្គល |
| ៦ | ការងារនៅក្នុងសេដ្ឋកិច្ចបៃតង | កម្រិតបុគ្គល |
| ៧ | កសិកម្ម និងការប្រើប្រាស់ដី | កម្រិតបុគ្គល |
| ៨ | ជីវភាពទាក់ទងនឹងបរិស្ថាន | កម្រិតបុគ្គល |
| ៩ | ការកាន់កាប់ទ្រព្យសម្បត្តិ | កម្រិតបុគ្គល |
| ១០ | ការសម្រេចចិត្ត និងការធ្វើដំណើរ | កម្រិតបុគ្គល |

## វិសាលភាពភូមិសាស្ត្រ

ការជ្រើសរើសសំណាកគំរូ សម្រាប់អង្កេតយេនឌ័រ និងបរិស្ថាន ឆ្នាំ ២០២៤ (GES) នៅកម្ពុជា បានប្រើវិធីសាស្ត្រសមាមាត្រច្រើនដំណាក់កាល (Multistage Probability Approach) ដើម្បីធានា បានតំណាងកម្រិតជាតិ ទីប្រជុំជន និងជនបទ។ ការអង្កេតនេះក៏បានគ្របដណ្តប់តំបន់ភូមិសាស្ត្រធំៗនៅកម្ពុជាចំនួនបួនតំបន់៖ តំបន់វាលទំនាប តំបន់បឹងទន្លេសាប តំបន់ឆ្នេរសមុទ្រ និងតំបន់ខ្ពង់រាប និងភ្នំ។ តំបន់ទាំងនេះតំណាងឱ្យភាពផ្សេងគ្នាផ្នែកតាមអេកូឡូស៊ី និងអាកាសធាតុនៅកម្ពុជា ក្នុងការចាប់យកភាពខុសគ្នារវាងតំបន់នានា លើភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។ ក្នុងតំបន់នីមួយៗ បានអនុវត្តន៍ការជ្រើសរើសតាមដំណាក់កាលជាច្រើន ចាប់ពីស្រុក ឬឃុំ រហូតដល់គ្រួសារនិងបុគ្គលដែលបានជ្រើសយកដោយចៃដន្យ ដើម្បីធានាបានទិន្នន័យដែលអាចទុកចិត្តបាន និងតំណាង សម្រាប់ការរៀបចំគោលនយោបាយ និងផែនការតាមតំបន់។ តំបន់ភូមិសាស្ត្រនីមួយៗ ការអង្កេត GES ២០២៤ នៅកម្ពុជា គ្រប់គ្រួសារប្រក្រតីទាំងអស់មានសិទ្ធិចូលរួម លើការសម្ភាសន៍បុគ្គល ជាក់លាក់ដែលមានអាយុ ១៥ ឆ្នាំឡើងទៅក្នុងគ្រួសារ។

## កាលបរិច្ឆេទយោង

ការប្រមូលទិន្នន័យ សម្រាប់អង្កេតយេនឌ័រ និងបរិស្ថាន ឆ្នាំ ២០២៤ (GES) នៅកម្ពុជា បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី ២ ខែសីហា ដល់ថ្ងៃទី ២ ខែតុលា ឆ្នាំ ២០២៤។ ទិន្នន័យភាគច្រើនមានរយៈពេលយោង រយៈពេល ១២ ខែ គិតចាប់ពីថ្ងៃសម្ភាសន៍។ បែបបទសំណួរបានបញ្ជាក់យ៉ាងច្បាស់ចំពោះធាតុទិន្នន័យដែលមានរយៈពេលយោងខុសពីរយៈពេល១២ខែ ដូចជាទិន្នន័យដែលទាក់ទងនឹងដំណើរដែលកើតឡើងជាបន្តបន្ទាប់ៗ ដូចជាការប្រែប្រួលអាកាសធាតុ ដែលជាទូទៅមានរយៈពេលយោងសម្រាប់អាយុកាលទាំងមូល។

## នីតិវិធីជ្រើសរើសសំណាកគំរូ

អង្កេតយេនឌ័រ និងបរិស្ថានកម្ពុជា ឆ្នាំ២០២៤ (CGES) បានអនុវត្តជាលើកដំបូងនៅកម្ពុជា។ អង្កេតនេះ ធ្វើឡើងដើម្បីផ្តល់ទិន្នន័យតំណាងជាតិស្តីពីបញ្ហាយេនឌ័រ និងបរិស្ថានដោយលទ្ធផលនឹងត្រូវបែងចែកតាមតំបន់ទីប្រជុំជន និងជនបទ និងតាមតំបន់ភូមិសាស្ត្រធំចំនួនបួនផងដែរ។ ការជ្រើសរើសសំណាកគំរូ បានប្រើវិធីសាស្ត្រច្រើនដំណាក់កាល ៖ ដំណាក់កាលទីមួយ ក្រមិតឃុំ (Communes) ត្រូវបានជ្រើសជាឯកតាជ្រើសយកគំរូដំបូង (Primary Sampling Units – PSUs) ដែលមានចំនួនសរុប ២៥០ឃុំ។ ឃុំនីមួយៗ ដែលបានជ្រើសតាមសមាមាត្រស្មើគ្នា (equal probability) ភូមិចំនួន ២ ត្រូវបានជ្រើសជាឯកតាជ្រើសយកគំរូទីពីរ (Secondary Sampling Units – SSUs) ដោយសរុបមាន ៥០០ភូមិ។ នៅក្នុងដំណាក់កាលទីបី គឺជាឯកតាជ្រើសយកគំរូទីបី (Tertiary stage) គ្រួសារចំនួន ១០ត្រូវបានជ្រើសដោយចៃដន្យពីក្នុងពីភូមិនិមួយៗ។ នៅក្នុងដំណាក់កាលទីបួន បុគ្គលម្នាក់ស្រី និងបុគ្គលម្នាក់ប្រុស (មានអាយុ ១៥ឆ្នាំឡើង) ត្រូវបានជ្រើសដោយចៃដន្យពីបញ្ជីសមាជិកគ្រួសារដើម្បីឆ្លើយសំណួរ។ សម្រាប់គ្រួសារដែលមានតែបុគ្គលមួយគត់ មានតែបុគ្គលនោះប៉ុណ្ណោះដែលបានឆ្លើយសំណួរ។ សរុបរួម ការអង្កេតនេះបានអនុវត្តលើ ស្ត្រីចំនួន ៤,៩៦១នាក់ និង បុរសចំនួន ៤,៨៤៣នាក់។

# ក្របខ័ណ្ឌសំណាកគំរូ

ក្របខ័ណ្ឌសំណាកគំរូសម្រាប់ជ្រើសរើសសំណាកគំរូអង្កេតយេនឌ័រ និងបរិស្ថានកម្ពុជាឆ្នាំ ២០២៤ (CGES) បានមកពីក្របខ័ណ្ឌបញ្ជីឈ្មោះឃុំ/ សង្កាត់នៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ (GPCC) ដោយគ្មានតំបន់ភូមិសាស្ត្រណាដែលត្រូវបានលើកលែង។ បញ្ជីគំរូនេះមានព័ត៌មានអំពីលេខកូដភូមិសាស្ត្រទាក់ទងនឹងទីតាំងផ្ទះសំបែង និងឈ្មោះមេគ្រួសារ។ សំណាកគំរូអង្កេតបានបង្ហាញក្នុងតារាង ១។ គ្រួសារប្រក្រតីទាំងអស់នៅក្នុងតំបន់ភូមិសាស្ត្រនីមួយៗ ត្រូវបានចាត់ទុកថាអាចចូលរួមអង្កេតបាន និងគោលដៅការសម្ភាសន៍លើសមាជិកគ្រួសារដែលមានអាយុ ១៥ឆ្នាំឡើងទៅ។ នៅពេលសម្ភាសន៍ សមាជិកគ្រួសារ បុរសម្នាក់និង ស្ត្រីម្នាក់ត្រូវបានជ្រើសរើសដោយចៃដន្យពីតារាងសមាជិកគ្រួសារដែលបានចុះបញ្ជីរួច GES ២០២៤។ មុនពេលជ្រើសរើស បញ្ជីសមាជិកគ្រួសារត្រូវបានជ្រើសរើសអោយនៅសល់តែសមាជិកដែលមានអាយុ ១៥ឆ្នាំឡើងទៅ និងបែងចែកជាក្រុមតាមភេទ។ ស្ត្រីម្នាក់ត្រូវបានជ្រើសរើសដោយចៃដន្យពីក្រុមស្ត្រី ចំណែកឯបុរសម្នាក់ ត្រូវបានជ្រើសរើសពីក្រុមបុរស។ នៅក្នុងករណីដែលគ្មានអ្នកសមរម្យក្នុងក្រុមណាមួយ ការសម្ភាសន៍មិនត្រូវបានអនុវត្តឡើយ។ សម្រាប់គ្រួសារដែលមានមនុស្សចាស់តែម្នាក់ ការសម្ភាសន៍ត្រូវបានធ្វើជាមួយនឹងមនុស្សនោះ ទោះបីគាត់មានភេទណាក៏ដោយ។

## តារាង១ : សំណាកគំរូសម្រាប់ការអង្កេតយេនឌ័រ និងបរិស្ថាន (GES) ឆ្នាំ ២០២៤

| កូដ | រាជធានី ខេត្ត | ចំនួនគ្រួសារ ឆ្នាំ ២០១៩ | អង្កេតយេនឌ័រ និងបរិស្ថានឆ្នាំ២០២៤(GES) | | | |
|---|---|---|---|---|---|---|
| | | | ចំនួនភូមិ | ចំនួនគ្រួសារ | ចំនួនស្ត្រី | ចំនួនបុរស |
| ១ | បន្ទាយមានជ័យ | ១៨៩,៦១០ | ២២ | ២២០ | ២១៩ | ២០៨ |
| ២ | បាត់ដំបង | ២២៧,២៨០ | ២៦ | ២៦០ | ២៦០ | ២៥៦ |
| ៣ | កំពង់ចាម | ២១៧,២៥៨ | ១៦ | ១៦០ | ១៦០ | ១៥៩ |
| ៤ | កំពង់ឆ្នាំង | ១២៦,៣៣៨ | ១៤ | ១៤០ | ១៤០ | ១៣៩ |
| ៥ | កំពង់ស្ពឺ | ១៩៥,៨៩៩ | ៥៤ | ៥៤០ | ៥៤០ | ៥៣៧ |
| ៦ | កំពង់ធំ | ១៦០,៨៦៩ | ១៨ | ១៨០ | ១៧៩ | ១៨០ |
| ៧ | កំពត | ១៤៣,៤៣៥ | ៧៨ | ៧៨០ | ៧៦៤ | ៧៤៣ |
| ៨ | កណ្ដាល | ២៦៦,២៧៦ | ១៨ | ១៨០ | ១៨០ | ១៧៥ |
| ៩ | កោះកុង | ២៨,០៣២ | ១៤ | ៦០ | ៥៩ | ៦០ |
| ១០ | ក្រចេះ | ៨៦,២២៤ | ២៤ | ១៤០ | ១៤០ | ១៤០ |
| ១១ | មណ្ឌលគីរី | ២០,៤០៩ | ៦ | ២៤០ | ២៣៧ | ២១៦ |
| ១២ | ភ្នំពេញ | ៤៩៩,៥២១ | ៣៦ | ៦០ | ៦០ | ៦០ |
| ១៣ | ព្រះវិហារ | ៥៦,៧៣៨ | ១៤ | ៦០ | ៥៩ | ៥៩ |
| ១៤ | ព្រៃវែង | ២៦៧,០៥៨ | ២០ | ២០ | ២០ | ២០ |
| ១៥ | ពោធិ៍សាត់ | ១០៣,៨៦៦ | ១២ | ៣៦០ | ៣៥៦ | ៣២៦ |
| ១៦ | រតនគីរី | ៤៩,៧៤១ | ១៤ | ២៦០ | ២៦០ | ២៥៩ |
| ១៧ | សៀមរាប | ២២៤,៧២០ | ២៦ | ១៦០ | ១៦០ | ១៦០ |
| ១៨ | ព្រះសីហនុ | ៤៧,៣៨៨ | ២៦ | ២០០ | ២០០ | ១៩៨ |
| ១៩ | ស្ទឹងត្រែង | ៣៥,៨៤២ | ១០ | ១២០ | ១១៩ | ១១៤ |
| ២០ | ស្វាយរៀង | ១៣២,៥៧៨ | ១២ | ១៤០ | ១៣៩ | ១៤០ |
| ២១ | តាកែវ | ២០៨,៨០១ | ១៤ | ២៦០ | ២៦០ | ២៦០ |
| ២២ | ឧត្ដរមានជ័យ | ៦០,៨៨៦ | ៦ | ១០០ | ៩៨ | ៩២ |
| ២៣ | កែប | ៩,៦១៣ | ៦ | ១០០ | ១០០ | ៩៨ |
| ២៤ | ប៉ៃលិន | ១៧,១៧៨ | ២ | ១៤០ | ១៣២ | ១២៥ |
| ២៥ | ត្បូងឃ្មុំ | ១៧៩,០៦៩ | ១២ | ១២០ | ១២០ | ១១៩ |
| សរុប | | ៣,៥៥៤,៦២៩ | ៥០០ | ៥,០០០ | ៤,៩៦១ | ៤,៨៧៣ |

ដើម្បីគិតគូរចំពោះប្រូបាបនៃការជ្រើសរើសខុសគ្នា មេគុណអង្កេត (sampling weights) ត្រូវបានគណនាសម្រាប់គ្រួសារនីមួយៗក្នុងគំរូ និងសម្រាប់អ្នកឆ្លើយតបជា បុរស និងស្ត្រី បានជ្រើសរើសដោយចៃដន្យ ។អង្កេតយេនឌ័រ និងបរិស្ថាន ឆ្នាំ២០២៤ នៅកម្ពុជា (GES) មេគុណអង្កេតត្រូវបានកែសម្រួលសម្រាប់ករណីដែលមិនឆ្លើយសំណួរ និងបានកែលំអដោយប្រើចំនួនគ្រួសារ និងចំនួនបុគ្គលតាមតំបន់ ដែលយកពីជំរឿនប្រជាជនកម្ពុជា ឆ្នាំ ២០១៩ (GPCC ២០១៩)។

# ប្រតិបត្តិការណ៍អង្កេត

ទិន្នន័យទាំងអស់ក្នុងអង្កេតយេនឌ័រ និងបរិស្ថានកម្ពុជាឆ្នាំ ២០២៤ ត្រូវបានប្រមូលដោយប្រើវិធីសម្ភាសផ្ទាល់ជាមួយកម្មវិធីជំនួយកុំព្យូទ័រ (CAPI) ដែលប្រើកម្មវិធី Survey Solutions របស់ធនាគារពិភពលោក។ ការប្រមូលទិន្នន័យត្រូវបានអនុវត្តដោយមន្ត្រីចុះស្រង់ទិន្នន័យ និងមន្ត្រីត្រួតពិនិត្យ ដែលបានបណ្តុះបណ្តាលពេញលេញ។ មន្ត្រីត្រួតពិនិត្យត្រូវបានជ្រើសរើសពីមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ (NIS)។ ចំណែកមន្ត្រីសម្ភាសន៍ក៏ត្រូវបាន ជ្រើសរើសពី NIS ដែលមានបទពិសោធន៍ជាមួយការចុះអង្កេតមុនៗរបស់ NIS។ មុនពេលចាប់ផ្តើមប្រមូលទិន្នន័យ មន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍ទាំងអស់បានចូលរួមបណ្តុះបណ្តាលរយៈពេលពីរសប្តាហ៍ បានគ្របដណ្តប់លើទ្រឹស្តីនិយមន័យ និងនីតិវិធីចុះស្រង់ទិន្នន័យ ។

មុនការចាប់ផ្តើមចុះអង្កេត វិទ្យាស្ថានជាតិស្ថិតិ NIS បានផ្ញើលិខិតជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាន ដើម្បីធានាថាគ្រប់សមាជិកគ្រួសារស្នាក់នៅផ្ទះកំឡុងពេលចុះសម្ភាសន៍។ ដោយសារតែមានការទំនាក់ទំនងជាមុន ទើបការណាត់គ្រួសារម្តងទៀតមានចំនួនតិចតួច និងអត្រាឆ្លើយតបមានខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ អាចមានការសម្ភាន៍មិនបានសម្រាប់ប្រជាជនដែលបានផ្លាស់ទីលំនៅដ្ឋាន ដោយសារតែគ្រោះមហន្តរាយ។

កម្មវិធី Survey Solutions ត្រូវបានប្រើសម្រាប់រៀបចំបែបបទសំណួរក្នុងការអង្កេត ដូចនេះការត្រួតពិនិត្យគុណភាពត្រូវបានអនុវត្តដោយប្រើមុខងារគ្រប់គ្រង ដែលមានស្រាប់នៅក្នុងកម្មវិធី។ របាយការណ៍ត្រូវបានត្រួតពិនិត្យដោយប្រើកម្មវិធីស្ថិតិ (R Program) នៅកម្រិតជាតិជារៀងរាល់ថ្ងៃ ដោយមន្ត្រីត្រួតពិនិត្យ ដើម្បីផ្តល់ព័ត៌មានអំពីស្ថានភាពសម្ភាសន៍ ការណាត់ជួបនៅសល់ និងករណីទិន្នន័យដែលមិនត្រឹមត្រូវ សម្រាប់ពិនិត្យ និងកែសម្រួល។ ការប្រមូលទិន្នន័យត្រូវបានធ្វើឡើងដោយប្រើម៉ាស៊ីនមេមួយ ដែលបានទិញដោយវិទ្យាស្ថានស្ថិតិជាតិ (NIS) ហើយដាក់ម៉ាស៊ីនមេនៅលើវេប Amazon Web Services (AWS)។

លោក **សុក កុសល** ជាអ្នកដឹកនាំប្រតិបត្តិការទាំងមូល ដឹកនាំក្រុមមន្ត្រីត្រួតពិនិត្យ និងមន្ត្រីប្រមូលទិន្នន័យ ។ មន្ត្រីត្រួតពិនិត្យត្រូវបានបែងចែកតាមសមាមាត្រនៃសំណុំគំរូ មានភារកិច្ចក្នុងការត្រួតពិនិត្យការសម្ភាសន៍ រៀបចំតាមដានពេលសម្ភាសន៍ និងពិនិត្យភាពត្រឹមត្រូវនៃចម្លើយ។ ការត្រួតពិនិត្យគុណភាពទិន្នន័យ ត្រូវបានអនុវត្តតាមនីតិវិធីដែលបង្ហាញក្នុងសៀវភៅណែនាំសម្រាប់ការអង្កេត។

អង្កេត GES ២០២៤ អត្រាឆ្លើតបសម្រាប់គ្រួសារ មានជិត ១០០% ។ ខណៈពេលដែល មន្ត្រីសម្ភាន៍ បានស្វែងរកគ្រួសារដែលបានផ្លាស់ទីលំនៅដោយសារគ្រោះធម្មជាតិ ក៏មានគ្រួសារខ្លះមិនអាចទាក់ទងបាន ទោះបីជាបានទៅរកជាបន្តបន្ទាប់។ គ្រួសារតិចតួចប៉ុណ្ណោះ រកមិនឃើញ ដោយគ្មានអ្នករស់នៅទៀតទេ។

## ដំណើរការវិភាគទិន្នន័យ

ការវិភាគទិន្នន័យសម្រាប់អង្កេតយេនឌ័រនិងបរិស្ថានឆ្នាំ ២០២៤ (GES) នៅកម្ពុជាត្រូវបានអនុវត្តដោយប្រើកម្មវិធីវិភាគស្ថិតិ R Program និង STATA។ បន្ទាប់ពីការសម្អាតទិន្នន័យ ការត្រួតពិនិត្យសុពលភាព រួចប្រើមេគុណអង្កេត (sampling weights) ដើម្បីធានាថាលទ្ធផលមានតំណាងត្រឹមត្រូវថ្នាក់ជាតិនិងតំបន់។ ការវិភាគនេះរួមបញ្ចូលទាំងវិភាគបែបពណ៌នា និង វិភាគបែបសន្និដ្ឋាន ដើម្បីវាយតម្លៃ ផលប៉ះពាល់បរិស្ថាន ការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយលើតំបន់ភូមិសាស្ត្រ និងក្រុមប្រជាជនផ្សេងៗ។

ដើម្បីធានាថាលទ្ធផលមានភាពជឿជាក់ និងអាចទុកចិត្តបាន ការត្រួតពិនិត្យភាពសមស្របពីរប្រភេទត្រូវបានអនុវត្តគឺការត្រួតពិនិត្យភាពស៊ីគ្នាខាងក្នុង (Internal coherence) ដើម្បីវាយតម្លៃភាពសមរម្យនៃទិន្នន័យខាងក្នុង និងការត្រួតពិនិត្យភាពស៊ីគ្នាខាងក្រៅ (External coherence) ដោយប្រៀបធៀបទិន្នន័យជាមួយស្ថិតិជាតិ និងការស្រាវជ្រាវដែលមានស្រាប់។

ការអនុវត្តន៍មេគុណអង្កេត (data weighting) ដើម្បីវិភាគនៃភាពស្មុគស្មាញ (complex survey design) ដែលធានាថាលទ្ធផលមានតំណាងត្រឹមត្រូវសម្រាប់កម្រិតជាតិ និងតំបន់។ ការយកចិត្តទុកដាក់ពិសេសបានផ្តល់ទៅលើកត្តាទំនាក់ទំនងគ្នារវាង យេនឌ័រនិងបរិស្ថាន ដើម្បីបង្កើតការយល់ដឹងអំពីឥទ្ធិពលដែលខុសគ្នានៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយលើក្រុមប្រជាជនងាយរងគ្រោះជាពិសេស។

## ចរិតលក្ខណៈទូទៅនៃប្រជាសាស្ត្រ

យោងតាមជំរឿនប្រជាជនទូទៅនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ (GPCC) មានគ្រួសារសរុបចំនួន ៣,៥៩៤,០៣១[២] មានប្រជាជនសរុបចំនួន ១៥,៥៥២,២១១ នាក់ ដែលក្នុងនោះ ៤៩ភាគរយជាបុរស និង៥១ភាគរយជាស្ត្រី[៣]។ លក្ខណៈទូទៅនៃប្រជាជនត្រូវបានបង្ហាញនៅក្នុងព័ត៌មានប្រជាសាស្ត្រទី១ (Infographic ១ ) ដែលជាឧបករណ៍ជំនួយបង្កើនការយល់ដឹងលើបណ្តាលទ្ធផលសំខាន់ៗដែលត្រូវបានដាក់បង្ហាញនៅក្នុងផ្នែកបន្ទាប់នៃរបាយការណ៍នេះ។

២ ជំរឿនប្រជាជន និងលំនៅឋានកម្ពុជាឆ្នាំ ២០១៩ បានបែងចែកគ្រួសារជា ៥ ប្រភេទ៖ គ្រួសារធម្មតា គ្រួសារតាមស្ថាប័ន គ្រួសារគ្មានផ្ទះសម្បែង គ្រួសារលើទូក និងគ្រួសារបណ្តោះអាសន្ន។ សូមមើលតារាង ១០.២.១ និង ១០.២.២ ។

៣ Ibid. សូមមើលតារាង ២.១.១.

## ព័ត៌មានប្រជាសាស្ត្រ១: ចរិតលក្ខណៈទូទៅនៃប្រជាជនកម្ពុជា




*ប្រភព៖ របាយការណ៍ចុងក្រោយនៃជំរឿនប្រជាជនកម្ពុជា ឆ្នាំ២០១៩ ដែលរៀបចំដោយក្រសួងផែនការ (របាយការណ៍ចុងក្រោយ) លើកលែងតែការប៉ាន់ស្មានទាក់ទងនឹងការអប់រំកម្រិតខ្ពស់ និងការបណ្តុះបណ្តាលបច្ចេកវិជ្ជា និងវិជ្ជាជីវៈ (TVET)ដែលបានយកចេញពីស្ថាប័នស្ថិតិអប់រំនៃអង្គការយូណេស្កូ (UNESCO Institute for Statistics) ដោយសារស្ថិតិទើបនឹងផ្សព្វផ្សាយថ្មី និងទុកចិត្តបាន។ ក្នុងរូបភាពនេះ ការអប់រំកម្រិតខ្ពស់ត្រូវបានបញ្ជាក់ថា មានន័យដល់ការអប់រំកម្រិតឧត្តមសិក្សា (tertiary education)*

ភាគច្រើនគ្រួសារនៅកម្ពុជា (៣០ ភាគរយ) គឺជាមនុស្សពេញវ័យ និង កុមារ។ តាមការប៉ាន់ស្មាននៅកម្ពុជាស្ត្រី ២ ភាគរយនៃគ្រួសារកម្ពុជាមានកូនក្នុងបន្ទុកដោយគ្មានប្តីរស់នៅជាមួយ ធៀបនឹងបុរស ០,៣ ភាគរយប៉ុណ្ណោះ ។ ក្នុងចំណោមមនុស្សពេញវ័យដែលជាមេម៉ាយ ឬពោះម៉ាយ  ស្ត្រី មានកូនច្រើននៅក្រោមការមើលថែរបស់គាត់ផងដែរ (ជាមធ្យម ១,៤៦ បើធៀបនឹង ១,១៥ ក្នុងករណីបុរស)។

ប្រជាជនកម្ពុជាច្រើនជ្រើសរើសការរស់នៅពឹងផ្អែកលើធនធានបរិស្ថាន។ វិស័យកសិកម្ម រួមទាំងការចិញ្ចឹមសត្វ គឺជារបរដែលពាក់ព័ន្ធនឹងបរិស្ថានដែលពេញនិយមបំផុតសម្រាប់បុរស និងស្ត្រី ដោយមាន ៨ នាក់ក្នុងចំណោម ១០ នាក់ ប្រកបមុខរបរវិស័យកសិកម្ម មិនថាសម្រាប់រកចំណូល  ការរស់នៅប្រចាំថ្ងៃ  ប្រពៃណី ការកម្សាន្ត ឬហេតុផលផ្សេងទៀត។ លើសពីកសិកម្ម បុរសជាច្រើនជាប់ពាក់ពន្ធ័នឹងការនេសាទ ខណៈដែលស្ត្រីភាគច្រើនពាក់ពន្ធ័នឹងការកែច្នៃអាហារ  ភេសជ្ជៈ និងការរក្សាទុក ។

## រូបភាព១៖សមាមាត្រប្រជាជនពេញវ័យដែលចូលរួមក្នុងការចិញ្ចឹមជីវិតដែលទាក់ទងនឹងបរិស្ថាន តាមភេទ (ភាគរយ)




*ចំណាំ៖ ភាពខុសគ្នារវាងស្ត្រី និងបុរស មិនមានភាពខុសគ្នាសម្រាប់ប្រភេទវារីវប្បកម្ម និងការប្រមូលផលរុក្ខជាតិព្រៃដែលមិនអាចបរិភោគបាន*

**ស្ទើរតែគ្រប់អ្នកឆ្លើយតបទាំងអស់បានជួបប្រទះនឹងការប្រែប្រួលអាកាសធាតុ និងយ៉ាងហោចណាស់គ្រោះមហន្តរាយមួយ។ ភាគច្រើនបានជួបប្រទះនឹងគ្រោះមហន្តរាយយ៉ាងហោចណាស់បួន។**

## រូបភាព២៖ផលប៉ះពាល់នឹងគ្រោះថ្នាក់អាកាសធាតុនៅកម្ពុជា




ចំណាំ៖ យោងតាម UNDRR គ្រោះថ្នាក់គឺជាដំណើរការ បាតុភូត ឬសកម្មភាពរបស់មនុស្សដែលអាចបណ្តាលឱ្យបាត់បង់ជីវិត របួស ឬផលប៉ះពាល់សុខភាពផ្សេងទៀត ការខូចខាតទ្រព្យសម្បត្តិ ការរំខានដល់សង្គម និងសេដ្ឋកិច្ច ឬការរិចរិលបរិស្ថាន។ គ្រោះថ្នាក់អាចជាធម្មជាតិ និរន្តរភាព ឬសង្គមដែលមានប្រភពដើម។ គ្រោះថ្នាក់ធម្មជាតិត្រូវបានផ្សារភ្ជាប់ជាចម្បងជាមួយនឹងដំណើរការ និងបាតុភូតធម្មជាតិ។ គ្រោះថ្នាក់ ឬ គ្រោះថ្នាក់ដែលបង្កឡើងដោយមនុស្ស ត្រូវបានបង្កឡើងទាំងស្រុង ឬលើសលប់ដោយសកម្មភាព និងជម្រើសរបស់មនុស្ស។ គ្រោះថ្នាក់ពីធម្មជាតិត្រូវបានផ្សារភ្ជាប់ជាមួយនឹងការរួមបញ្ចូលគ្នានៃកត្តាធម្មជាតិ និងកត្តាមនុស្សសាស្ត្រ រួមទាំងការរិចរិលបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។ នៅក្នុងរបាយការណ៍នេះ សេចក្តីយោងទៅលើគ្រោះថ្នាក់ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ សំដៅទៅលើគ្រោះថ្នាក់ធម្មជាតិ និរន្តរភាព ឬសង្គម-ធម្មជាតិដែលចាប់ផ្តើមយឺត ខណៈគ្រោះមហន្តរាយសំដៅទៅលើការកើតឡើងយ៉ាងឆាប់រហ័សពីធម្មជាតិ និរន្តរភាព ឬគ្រោះធម្មជាតិសង្គម ដែលបណ្តាលឱ្យមានការខូចខាតយ៉ាងច្រើន។

# លទ្ធផលនៃការរកឃើញ

## ផ្នែក I ការប្រឈមមុខនឹងគ្រោះមហន្តរាយ ការត្រៀមខ្លួន និងផលវិបាក

### ស្ទើរតែគ្រប់គ្នានៅក្នុងប្រទេសកម្ពុជារស់នៅក្នុងតំបន់ដែលមានហានិភ័យបរិស្ថានខ្ពស់

ប្រមាណជា ៨៧ ភាគរយនៃប្រជាជនកម្ពុជារស់នៅក្នុងតំបន់ដែលមានហានិភ័យបរិស្ថានខ្ពស់ (រូបភាពទី ២)។ កន្លែងគ្រោះថ្នាក់មួយចំនួននៅជិតលំនៅដ្ឋានរបស់គាត់ រួមមាន តំបន់ចរាចរណ៍យានយន្តញឹកញាប់ កន្លែងដុត ឬបូជាសព និងដីកសិកម្មខ្នាតមធ្យមទៅខ្នាតធំបានប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតនិងសារធាតុគ្រោះថ្នាក់ផ្សេងៗ ក្នុងចំណោមកន្លែងផ្សេងៗទៀត។ ទាំងនេះធ្វើឱ្យមនុស្សងាយរងគ្រោះខ្លាំងចំពោះគ្រោះមហន្តរាយ និងព្រឹត្តិការណ៍គ្រោះថ្នាក់ផ្សេងទៀត។ ប្រជាជននៅតំបន់ទីប្រជុំជនមានការប៉ះពាល់ច្រើន ៩០ភាគរយ គាត់រស់នៅក្នុងតំបន់គ្រោះថ្នាក់។ ស្ទើរតែមិនមានភាពខុសគ្នា នៃផលប៉ះពាល់ដោយផ្អែកលើទីកន្លែងត្រូវបានគេកំណត់អត្តសញ្ញាណរវាងស្ត្រី និងបុរសក៏ដោយ សមត្ថភាពរបស់ស្ត្រីក្នុងការទប់ទល់នឹងគ្រោះថ្នាក់ជាទូទៅមានកម្រិតទាប ដោយសារគាត់មានតិចជាងបុរសក្នុងការកាន់កាប់ទ្រព្យសម្បត្តិ ដើម្បីទទួលបានហិរញ្ញប្បទាន និងទទួលបានការងារដែលមានប្រាក់ចំណូលខ្ពស់។

រូបភាពទី២: សមាមាត្រ ប្រជាជនដែលមានលំនៅដ្ឋាន ឬដីធ្លីស្ថិតនៅក្នុងតំបន់ដែលមានហានិភ័យបរិស្ថានខ្ពស់ តាមភេទ និងទីកន្លែងរស់នៅ (ភាគរយ)




*ចំណាំ៖ ការរស់នៅក្បែរហានិភ័យបរិស្ថានខ្ពស់ សំដៅលើការរស់នៅក្នុងចម្ងាយ ២ គីឡូម៉ែត្រ ឬដើរតិចជាង ៣០ នាទីទៅកាន់ទីតាំងដែលអាចបង្កហានិភ័យដល់សុខភាព និងសុវត្ថិភាពមនុស្សតាមរយៈការប៉ះពាល់មិនសមាមាត្រទៅនឹងគ្រោះថ្នាក់។ ទាំងនេះរាប់បញ្ចូលទាំងឆ្នេរសមុទ្រ កន្លែងផលិតឧស្សាហកម្ម កន្លែងផលិតសិប្បករដែលប្រើប្រាស់ថ្នាំពណ៌ ថ្នាំលាប ប៉ូលា ឬសារធាតុគីមីផ្សេងទៀត ទីតាំងប្រេះ កន្លែងស្រង់ចេញ តំបន់ចរាចរណ៍រថយន្តខ្ពស់ កន្លែងចាក់សំរាម រោងចក្រថាមពល ឬខ្សែបណ្តាញតង់ស្យុងខ្ពស់ កន្លែងដុត ឬបូជាសព កន្លែងបន្ទោរបង់ពាសវាលពាសកាល កន្លែងទុកដាក់ថ្នាំសម្លាប់សត្វល្អិត កន្លែងទុកដាក់សំរាម។ កន្លែងផលិតសត្វកម្រិតឧស្សាហកម្ម កន្លែងស្តុកទុកសារធាតុគីមីថ្ម ឬវត្ថុដែលអាចបង្កគ្រោះថ្នាក់ផ្សេងទៀត តំបន់ទំនាប វាលភក់ ឬតំបន់ដែលងាយរងគ្រោះដោយទឹកជំនន់ ភ្នំភ្លើងសកម្ម ខ្សែផ្លូវខុស ឬតំបន់ដែលងាយនឹងរញ្ជួយដី ព្យុះស៊ីក្លូន ខ្យល់ព្យុះ ឬតំបន់ដែលងាយនឹងខ្យល់បក់ខ្លាំង ដីទំនាបទន្លេ ច្រាំងបឹង ច្រាំងទន្លេ និងតំបន់រងគ្រោះដោយគ្រោះរាំងស្ងួត។*

## ប្រជាជនភាគច្រើននៅកម្ពុជាបានជួបប្រទះគ្រោះមហន្តរាយក្នុងរយៈពេល ១២ខែចុងក្រោយ និងបានជួបប្រទះនឹងគ្រោះមហន្តរាយច្រើនមុខ

នៅចុងឆ្នាំ២០២៤ ស្ទើរតែ ១០០ ភាគរយនៃប្រជាជនកម្ពុជាបានជួបប្រទះនឹងគ្រោះមហន្តរាយយ៉ាងហោចណាស់មួយក្នុងរយៈពេល ១២ខែចុងក្រោយនេះ(រូបភាពទី៣)។ លើសពីនេះ ៧៥ភាគរយបានជួបប្រទះគ្រោះមហន្តរាយ ឬគ្រោះថ្នាក់ដែលពាក់ព័ន្ធចំនួនបី ឬច្រើនជាង។ ការកើនឡើងកំដៅខ្លាំង និងគ្រោះរាំងស្ងួត បានប៉ះពាល់ដល់ជីវភាពរស់នៅ និងសុខភាពផ្ទាល់ខ្លួនរបស់ប្រជាជនជាច្រើន។ ក្នុងខែមេសា សីតុណ្ហភាពខ្ពស់ខុសធម្មតា (៤២,៨ °C) ត្រូវបានរាយការណ៍នៅក្រុងព្រះវិហារ និងស្រុកស្វាយលើ[៤]។ នៅខែបន្ទាប់ ភ្នំពេញក៏មាន កំដៅក្តៅខ្លាំងដែរ ជាមួយនឹងសីតុណ្ហភាពខ្ពស់ដល់ទៅ ៤២,២°C នៅថ្ងៃទី១ ឧសភា បន្ទាប់ពីរយៈពេលជាង ៤0ថ្ងៃជាប់គ្នា ជាមួយនឹងសីតុណ្ហភាពមាន ៣៧°C។ ការធ្វើនគរូបនីយកម្មយ៉ាងឆាប់រហ័សដែលកើតឡើងនៅទូទាំងប្រទេស រួមទាំងជុំវិញទីក្រុងភ្នំពេញ បានបណ្តាលឱ្យមានសីតុណ្ហភាពក្នុងទីក្រុងឡើងដល់១,៣°C ខ្ពស់ជាងតំបន់ជាយក្រុង។ ព្រឹត្តិការណ៍កំដៅទាំងនេះជារឿយៗត្រូវបានអមដោយគ្រោះរាំងស្ងួត។

ខែមិថុនាឆ្នាំ ២០២៤[៥] រូបភាពពីផ្កាយរណបបានបង្ហាញពីទិដ្ឋភាពទឹកជុំវិញបឹងទន្លេសាប បង្ហាញពណ៌ខៀវស្រងាត់ដែលទំនងដោយសារតែការកើនឡើងនៃដីល្បាប់នៅពេលកម្រិតទឹកធ្លាក់ចុះ។ គ្រោះរាំងស្ងួតម្តងហើយម្តងទៀតបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ទិន្នផលកសិកម្ម រួមទាំងការបំផ្លាញផលិតកម្មម្រេចកំពតផងដែរ។

ព្យុះផ្គររន្ទះ និងការវាយប្រហារដោយផ្លេកបន្ទោរ បានប៉ះពាល់ដល់សុវត្ថិភាពរបស់ប្រជាជន និងរាំងកត្តាសំខាន់ៗមួយចំនួនក្នុងរយៈពេល១២ខែមុនអង្កេត ករណីជាច្រើន ត្រូវបានអមដោយខ្យល់បក់ខ្លាំង។ ជាឧទាហរណ៍ ក្នុងខែវិច្ឆិកា ព្យុះស៊ីក្លូនត្រូពិច បានប៉ះពាល់ដល់ខេត្តរតនគិរី និងស្ទឹងត្រែង។ ពេញមួយឆ្នាំ មានរន្ទះបាញ់ស្លាប់ជាច្រើនកន្លែងនៅទីតាំងផ្សេងៗគ្នា អង្កេតយេនឌ័រ និងបរិស្ថាន បានគូសបញ្ជាក់ផងដែរថា ខេត្តកណ្តាល កំពង់ចាម រាជធានីភ្នំពេញ កំពង់ស្ពឺ និងកំពង់ឆ្នាំង ឃើញថាមានចំនួន ប្រជាជនច្រើនជាងគេដែលរងផលប៉ះពាល់ដោយរន្ទះបាញ់។

---

៤ មើលកំណត់ត្រាសីតុណ្ហភាពប្រវត្តិសាស្ត្រនៅធនាគារពិភពលោក[World Bank](#).

៥ សូមមើល [NASA-MODIS](#).

**ភាពទី ៣. សមាមាត្រប្រជាជនដែលបានជួបប្រទះយ៉ាងហោចណាស់គ្រោះមហន្តរាយមួយ ឬច្រើន ឬគ្រោះថ្នាក់ដែលពាក់ព័ន្ធក្នុងរយៈពេល ១២ ខែកន្លងមកនេះ តាមភេទ (ភាគរយ)**




## គ្រោះមហន្តរាយបានបង្ហាញពីឧបសគ្គក្នុងការទទួលបានសេវាសុខភាព និងអនាម័យ ជាពិសេសសម្រាប់ស្ត្រីដែលផ្លាស់ទីលំនៅ

គ្រោះមហន្តរាយបានបណ្តាលឱ្យមនុស្សម្នាក់ក្នុងចំណោមប្រាំពីរនាក់ជួបប្រទះឧបសគ្គក្នុងការទទួលបានសេវាថែទាំសុខភាព និងផលិតផលអនាម័យ ឧទាហរណ៍ជាលទ្ធផលនៃការបិទផ្លូវ បញ្ហាផ្សារឬបញ្ហាតម្លៃ ។ ប្រជាជននៅជនបទបានជួបប្រទះនឹងបញ្ហាប្រឈមខ្ពស់ មានរហូតដល់ ១៣ ភាគរយបានកត់សម្គាល់ពីបញ្ហាប្រឈមទាំងនេះ បើធៀបនឹង ១១ ភាគរយនៅទីប្រជុំជន (រូបភាពទី៤)។ សម្រាប់អ្នកដែលត្រូវបានផ្លាស់ទីលំនៅដោយគ្រោះមហន្តរាយ មិនថាគាត់ត្រូវបានជម្លៀសជាបណ្តោះអាសន្ន ឬផ្លាស់ប្តូរទីលំនៅជាអចិន្ត្រៃយ៍ក៏ដោយ ឧបសគ្គទាំងនេះកាន់តែចោតខ្លាំង។ មានស្ត្រី១៩ ភាគរយ បានផ្លាស់ទីលំនៅ និង បុរស១៤ ភាគរយ មានការលំបាកក្នុងការទទួលបានសេវាថែទាំសុខភាព និងផលិតផលអនាម័យ (រូបភាពទី៥)។ ក្នុងចំណោមស្ត្រីមានកូនក្នុងបន្ទុកដោយមិនមានប្តីរស់នៅជាមួយ មានអត្រាខ្ពស់ជាងបុរសមានកូនក្នុងបន្ទុកដោយមិនមានប្រពន្ធរស់នៅជាមួយ នឹងបានផ្លាស់ទីលំនៅកាន់តែមានបញ្ហាប្រឈមបន្ថែមទៀតដើម្បីជម្នះឧបសគ្គក្នុងការទទួលបានការថែទាំសុខភាព និងផលិតផលអនាម័យ ។ កង្វះអនាម័យស្ត្រី និងសេវាថែទាំសុខភាពនៅក្នុងកន្លែងផ្លាស់ទីលំនៅ រួមទាំងស្ត្រីមានផ្ទៃពោះបានប្រឈមបញ្ហាឧបសគ្គកាន់តែច្រើន ។

រូបភាពទី ៤. សមាមាត្រ ប្រជាជនដែលប្រឈមនឹងគ្រោះថ្នាក់ក្នុងរយៈពេល ១២ ខែចុងក្រោយ បានជួបឧបសគ្គក្នុងការទទួលបានសេវាការថែទាំសុខភាព ឬផលិតផលអនាម័យ តាមភេទ និងទីកន្លែងរស់នៅ (ភាគរយ)




*ចំណាំ៖ នៅក្នុង GES Cambodia ឆ្នាំ ២០២៤ គ្រោះថ្នាក់មួយត្រូវបានកំណត់ថាជាដំណើរការ បាតុភូត ឬសកម្មភាពរបស់មនុស្សដែលបង្កការគំរាមកំហែងដល់អាយុជីវិត សុខភាព ទ្រព្យសម្បត្តិ ឬបរិស្ថាន។ ការប្រឈមនឹងគ្រោះថ្នាក់មានន័យថាបុគ្គលម្នាក់បាននៅក្នុងទីតាំងមួយដូចជាទីក្រុង ភូមិ ឬវាលស្រែ—ដែលពួកគេបានឃើញហេតុការណ៍ផ្ទាល់ខ្លួន។ ភាពខុសគ្នារវាងស្ត្រី និងបុរស គឺមិនសំខាន់តាមស្ថិតិនៅ α=0,0៥ ទេ។*

រូបភាពទី៥. សមាមាត្រ ប្រជាជនដែលប្រឈមនឹងគ្រោះថ្នាក់ក្នុងរយៈពេល១២ខែចុងក្រោយ បានជួបប្រទះឧបសគ្គក្នុងការទទួលបានការថែទាំសុខភាព ឬផលិតផលអនាម័យ តាមភេទ និងស្ថានភាពផ្លាស់ទីលំនៅ (ភាគរយ)




*ចំណាំ៖ ភាពខុសប្លែកគ្នារវាងស្ត្រី និងបុរសគឺមិនសំខាន់ជាស្ថិតិនៅ α=0,0៥ សម្រាប់អ្នកដែលមិនផ្លាស់ទីលំនៅនោះទេ។*

## ស្ទើរតែ ៨ នាក់ក្នុងចំណោម ១០ នាក់បានជួបប្រទះបញ្ហាសុខភាពផ្លូវចិត្ត បណ្តាលមកពីគ្រោះមហន្តរាយ

នៅពេលប្រឈមនឹងគ្រោះមហន្តរាយ ឬគ្រោះថ្នាក់ផ្សេងទៀត បុគ្គលម្នាក់ៗអាចជួបប្រទះបញ្ហាសុខភាពផ្លូវចិត្ត ដូចជា ស្ត្រេស ទុក្ខសោក ការធ្លាក់ទឹកចិត្ត (PTSD) ឬបញ្ហាថប់បារម្ភ រួមទាំងភាពមិនច្បាស់លាស់អំពីការបំពេញតម្រូវការមូលដ្ឋានសម្រាប់ចំណីអាហារ ទឹក ឬការថែទាំសុខភាព។ នៅកម្ពុជា ស្ត្រី ៧៦ភាគរយ និងបុរស៧៥ភាគរយដែលប្រឈមនឹងគ្រោះមហន្តរាយ និងគ្រោះថ្នាក់ដែលពាក់ព័ន្ធបានជួបប្រទះអារម្មណ៍បែបនេះ (រូបភាពទី ៦)។ គ្រោះថ្នាក់ត្រូវបានគេដឹងថាប៉ះពាល់ដល់ស្ត្រី និងបុរសខុសគ្នា ខណៈពេលមានអត្រាខ្ពស់ លើស្ត្រីមានការងារ

ក្រៅប្រព័ន្ធ និងឧបសគ្គជារួមចំពោះកម្មសិទ្ធិទ្រព្យសម្បត្តិរបស់ស្ត្រី ធ្វើឱ្យពួកគាត់កាន់តែងាយរងគ្រោះ និងមិនមានឧបករណ៍គ្រប់គ្រាន់ដើម្បីទប់ទល់នឹងផលប៉ះពាល់នៃគ្រោះមហន្តរាយលើជីវភាពរស់នៅរបស់គាត់។ ការចូលរួមមិនសមាមាត្ររបស់បុរសក្នុងប្រតិបត្តិការស្វែងរក និងជួយសង្គ្រោះធ្វើឱ្យជីវិតរបស់ពួកគាត់ប្រឈមនឹងគ្រោះថ្នាក់។ លើសពីនេះ ស្ត្រីជាធម្មតាត្រូវទទួលបន្ទុកក្នុងការថែទាំអ្នកជំងឺ ឬរបួសដោយសារគ្រោះមហន្តរាយ។ គ្រោះមហន្តរាយនៅកម្ពុជាក្នុងឆ្នាំ២០២៤ បានបណ្តាលឱ្យមានរបួស និងជំងឺជាច្រើនមុខ ជាឧទាហរណ៍ ប្រជាជនប្រមាណ ០,៩% ដែលជួបប្រទះនឹងគ្រោះទឹកជំនន់ បានរាយការណ៍ថា បានឈឺឬមានជំងឺ ខណៈដែល ស្ត្រី០,៤% និង បុរស០,៣% បានឆ្លងជំងឺដោយសារគ្លៀងអាស៊ីត។ ទឹកជំនន់ក៏បានធ្វើឱ្យមនុស្សជាច្រើនរងរបួសក្នុងឆ្នាំ ២០២៤ ដោយលទ្ធភាពនៃការរងរបួសរបស់ស្ត្រីមានចំនួនជិតទ្វេដងច្រើនជាងបុរស។

## រូបភាពទី៦. សមាមាត្រ ប្រជាជនដែលប្រឈមនឹងគ្រោះថ្នាក់ក្នុងរយៈពេល ១២ ខែចុងក្រោយ ដែលប៉ះពាល់ដល់សុខភាពផ្លូវចិត្ត តាមភេទ




## ការប្រឈមពីគ្រោះមហន្តរាយបានបង្កយ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី ដែលបានរងផលប៉ះពាល់យ៉ាងខ្លាំងក្នុងការបាត់បង់ដំណាំនិងសត្វចិញ្ចឹម

ប្រជាជនជាច្រើននៅកម្ពុជាពឹងផ្អែកភាគច្រើនលើសកម្មភាពទាក់ទងនឹងបរិស្ថានដែលជាប្រភពចំណូល គ្រោះមហន្តរាយឆ្នាំ ២០២៤ បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់គាត់ ។ ស្ត្រី ៥៣ ភាគរយ និងបុរស ៤២ ភាគរយ បានកត់សម្គាល់ថា ដំណាំដែលពួកគាត់ដាំត្រូវបានរងការខូចខាត ឬបំផ្លាញដោយគ្រោះមហន្តរាយ និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ។ មានស្ត្រី ២៩ ភាគរយ និង បុរស២៣ ភាគរយ បានឃើញថាសត្វចិញ្ចឹមរបស់គាត់បានឆ្លងជំងឺ ឬស្លាប់ដោយសារគ្រោះមហន្តរាយ ជាមួយគ្នានេះដែរ ស្ត្រី ក៏មានភាគរយខ្ពស់ជាងបុរសដែលរងផលប៉ះពាល់លើផលដំណាំ និងបសុសត្វ (រូបភាព៧) ដោយសារតែស្ត្រីបានប្រកបរបរកសិកម្មប្រភេទតូចៗច្រើន បើប្រៀបធៀបទៅនឹងបុរស និងមានអត្រាទាបការប្រើថ្នាំសម្លាប់សត្វល្អិត ថ្នាំជំរុញការលូតលាស់ និងការការពារផ្សេងៗទៀត។ ស្ត្រីមានភាគរយទាបជាងបុរស ដែលគ្រប់គ្រងលើហិរញ្ញវត្ថុផ្ទាល់ខ្លួន ដែលអាចជួយធានាប្រតិបត្តិការរបស់គាត់ ឬដាក់វិធានការការពារផ្សេងទៀត។ ដូចគ្នានេះផងដែរ ស្ត្រីតែងតែមានសត្វចិញ្ចឹមតិចជាង និងមានទំហំតូចជាងបុរស ជាមួយនឹងការវិនិយោគក្នុងហេដ្ឋារចនាសម្ព័ន្ធសត្វចិញ្ចឹម ថ្នាំបង្ការ ឬរ៉ាក់សាំងក៏មានតិចជាងផងដែរ។

ទោះយ៉ាងណាក៏ដោយ បុរសបានកត់សម្គាល់ឃើញថាប្រាក់ចំណូលផ្ទាល់ខ្លួនគាត់បានថយចុះដោយសារគ្រោះមហន្តរាយ ឬការប៉ះពាល់នឹងគ្រោះថ្នាក់ (ស្ត្រី៤០ភាគរយ និងបុរស៤៤ភាគរយ)។ នេះជាផ្នែកមួយដោយសារបុរសចូលរួមច្រើនក្នុង ដំណាំឧស្សាហកម្ម និងទម្រង់ផ្សេងទៀតនៃប្រតិបត្តិការកសិកម្មខ្នាតធំ ដើម្បីទទួលប្រាក់ខែ ឬប្រាក់ចំណេញ។ ជាលទ្ធផល បុរសនៅ ជនបទមានច្រើនបានបាត់បង់ប្រាក់ចំណូល (៤៦ភាគរយ) ខណៈដែលស្ត្រី ៤៥ ភាគរយបានបាត់បង់ប្រាក់ចំណូលផងដែរ (តារាង ២)។

បើទោះបីមានការបាត់បង់ចំណូលយ៉ាងច្រើនក៏ដោយ ជាពិសេសស្ត្រីដែលធ្វើកសិកម្ម និងចិញ្ចឹមសត្វអាចនឹងទទួលរងនូវផលវិបាកច្រើនជាងបុរស ដោយសារគាត់មិនសូវមានលទ្ធភាពបង្កើតប្រាក់ចំណូលពីប្រភពច្រើន ដូច្នេះនាំឱ្យមានការពឹងផ្អែកលើធនធានបរិស្ថានកាន់តែច្រើនដើម្បីចិញ្ចឹមជីវិត។ ក្នុងចំណោមស្ត្រី ៤៤ ភាគរយ ធៀបនឹងបុរស ៣៤ ភាគរយប៉ុណ្ណោះ ដែលដំណាំដាំដុះរបស់គាត់ត្រូវបានបំផ្លាញ ឬរងការខូចខាត (មើលរូប៨)។ ដើម្បីទប់ស្កាត់ការបាត់បង់ចំណូល គាត់អាចជ្រើសរើសការស្នើសុំប្រាក់កម្ចី ឬផ្លាស់ប្តូរការផ្គត់ផ្គង់ជីវភាពរបស់ខ្លួន ដូចជាការ ទិញគ្រាប់ពូជដែលធន់នឹងអាកាសធាតុ ឬសាងសង់កន្លែងចិញ្ចឹមសត្វដែលអាចការពារពីទឹកជំនន់។ ទោះយ៉ាងណាក្តី ស្ត្រីភាគច្រើនមានទ្រព្យសម្បត្តិដែលមានតម្លៃទាប និងមានឱកាសទទួលបានហិរញ្ញប្បទានតិចជាង បណ្តាលឱ្យលទ្ធភាពក្នុងការទប់ស្កាត់ និងជីវភាពមានការខ្សោយជាង។ឧទាហរណ៍ ស្ត្រីនៅកម្ពុជាមានអំណាចកាន់កាប់គ្រឿងចក្រ និងឧបករណ៍កសិកម្មធំៗតិចជាងបុរស។ ស្ត្រីក៏មានភាគរយតិចជាងបុរសជាម្ចាស់កម្មសិទ្ធិលើឧបករណ៍នេសាទធំៗ ឬទូកម៉ាស៊ីន ដែលអាចយកទៅធ្វើជាវត្ថុធានាសម្រាប់ទទួលបានកម្ចីបានផងដែរ (មើលរូបទី ៧២ និង ៧៣)។

ក្នុងចំណោមគ្រោះថ្នាក់ទាំងអស់ ព្រឹត្តិការណ៍កំដៅខ្លាំង និងគ្រោះរាំងស្ងួត គឺជាគ្រោះមហន្តរាយដែលបង្កការខូចខាតដល់ផលដំណាំ ឬសត្វពាហនៈខ្ពស់ ខណៈដែលកំដៅខ្លាំងបានធ្វើឱ្យបាត់បង់ការងារ និងប្រាក់ចំណូលច្រើនបំផុត។ គ្រោះមហន្តរាយជាច្រើនដែលបានប៉ះពាល់ដល់កម្ពុជា ក្នុងឆ្នាំ ២០២៤ បានធ្វើឱ្យប្រជាពលរដ្ឋ ៤ ភាគរយបន្ថែមទៀតគ្មានការងារធ្វើ និងប្រជាពលរដ្ឋជាច្រើនទៀតត្រូវផ្លាស់ប្តូរការងារ។ គ្រោះរាំងស្ងួតធ្ងន់ធ្ងរបានជំរុញឱ្យបាត់បង់ការងារ និងប្រាក់ចំណូលសម្រាប់ប្រជាជនជាច្រើនដែលប្រកបរបរកសិកម្មដំណាំដាំដុះ ដូចជា ស្រូវ ពោតស៊ូ ដំឡូងមីពោត និងសណ្តែក។ ដូចគ្នានេះដែរ ខ្យល់បក់ខ្លាំង និងព្យុះផ្គររន្ទះបានបណ្តាលឱ្យមានការបិទផ្លូវ និងគ្រោះថ្នាក់ទាក់ទងនឹងសុខភាព ដែលបណ្តាលមកពីផ្គរលាន់ និងភ្លៀងអាស៊ីត។ បន្ទុកការងារនិងការថែទាំក្នុងគ្រួសារកាន់តែធ្ងន់ធ្ងរឡើងដោយគ្រោះមហន្តរាយ ដូចជាតម្រូវការសម្អាតតំបន់លិចទឹក ឬការថែទាំអ្នករបួស ឬឈឺ អាចនឹងធ្វើឱ្យបាត់បង់ការងារនិងប្រាក់ចំណូលកាន់តែធ្ងន់ធ្ងរ។ ការខាតបង់ទាំងនេះគឺមានខ្ពស់ក្នុងចំណោមប្រជាជននៅជនបទ។

## រូបភាពទី៧៖ សមាមាត្រ ប្រជាជនដែលប្រឈមនឹងគ្រោះថ្នាក់ក្នុងរយៈពេល ១២ ខែចុងក្រោយ ដោយជីវភាពគាត់ត្រូវបានប៉ះពាល់ ឬខូចខាត តាមភេទ (ភាគរយ)




## រូបភាពទី៨. សមាមាត្រ ប្រជាជនដែលដំណាំ និងសត្វពាហនៈរបស់គាត់ ត្រូវបានខូចខាត ឬបំផ្លាញ ដែលទាំងនេះគឺជាប្រភពចំណូលចម្បងរបស់គាត់ បែងចែកតាមភេទ (ភាគរយ)




## តារាងទី ២. សមាមាត្រ ប្រជាជនបានជួបប្រទះការបាត់បង់ប្រាក់ចំណូលដោយសារគ្រោះមហន្តរាយ បែងចែកតាមភេទ ទីកន្លែងរស់នៅ ទម្រង់ការងារ និងអាយុ (ភាគរយ)

| | ទីប្រជុំជន | ជនបទ | ការងារក្នុងប្រព័ន្ធ | ការងារក្រៅប្រព័ន្ធ | អាយុក្រោម៣០ឆ្នាំ | អាយុ៣០ឆ្នាំឡើង |
|---|---|---|---|---|---|---|
| ស្ត្រី | ៣៥ | ៤៥ | ៣៨ | ៤៦ | ៣៦ | ៤២ |
| បុរស | ៣៨ | ៤៦ | ៣០ | ៤៩ | ៣៧ | ៤៤ |

## ស្ត្រី និងបុរសជាច្រើន បានផ្លាស់ទីលំនៅដោយសារគ្រោះមហន្តរាយផ្សេងៗនៅឆ្នាំ ២០២៤

គ្រោះរាំងស្ងួត ឡើងកំដៅខ្លាំង និងខ្យល់ព្យុះ នៅកម្ពុជាក្នុងឆ្នាំ ២០២៤ បណ្តាលឱ្យមានការបំផ្លិចបំផ្លាញយ៉ាងខ្លាំង។ ១១ ភាគរយបានរងការខូចខាតលំនៅដ្ឋានរបស់គាត់ ភាគច្រើនមកពីការកើនឡើងកំដៅខ្លាំង និង ស្ត្រី៣ ភាគរយ និងបុរស២ភាគរយ បានកត់សម្គាល់ថាផ្ទះរបស់ពួកគាត់ត្រូវបានបំផ្លាញ (រូបភាព១២ សូមមើលបន្ថែមខាងក្រោម)។ ការខូចខាតឬការបំផ្លិចបំផ្លាញផ្ទះសំបែងដោយការបាត់បង់មុខរបរចិញ្ចឹមជីវភាពអាចជំរុញឱ្យគាត់ធ្វើចំណាកស្រុក។ ការផ្លាស់ទីលំនៅបណ្តោះអាសន្ន (រួមទាំងការជម្លៀសទុកមុន) បានប៉ះពាល់ដល់ប្រជាជន ១៧ ភាគរយនៅកម្ពុជា និងមួយចំនួនទៀតបានផ្លាស់ប្តូរទីលំនៅអចិន្ត្រៃយ៍ទាំងក្នុង និងក្រៅប្រទេស (រូបភាពទី៩)។ ការផ្លាស់ទីលំនៅអាចនាំមកនូវផលវិបាកសេដ្ឋកិច្ច និងសុវត្ថិភាពសំខាន់ៗសម្រាប់ប្រជាជនជាច្រើន ជាពិសេសសម្រាប់ឪពុកម្តាយដែលពោះម៉ាយឬមេម៉ាយ ដែលបានភៀសខ្លួន ឬធ្វើចំណាកស្រុកជាមួយកូន។ ជាទូទៅបុរសមានច្រើនជាងស្ត្រីការធ្វើចំណាកស្រុកទៅកាន់តំបន់ភូមិសាស្ត្រផ្សេងទៀត ដើម្បីស្វែងរកឱកាសបង្កើតប្រាក់ចំណូល ដែលធ្វើឱ្យស្ត្រីជាច្រើនជាអ្នកទទួលបន្ទុកមើលថែទាំគ្រួសារ ។

**រូបភាពទី៩.សមាមាត្រ ប្រជាជនដែលប្រឈមនឹងគ្រោះថ្នាក់ក្នុងរយៈពេល ១២ ខែចុងក្រោយ បានធ្វើការផ្លាស់ទីលំនៅបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ តាមភេទ និងប្រភេទនៃការផ្លាស់ទីលំនៅ (ភាគរយ)**




*កំណត់សម្គាល់៖ ស្ត្រីប្រមាណ ៧ ភាគរយ និងបុរស ៤ ភាគរយបានកត់សម្គាល់ថាគ្មានជម្រកណាមួយត្រូវបានកំណត់អំឡុងពេលមានគ្រោះមហន្តរាយ។ ភាពខុសប្លែកគ្នារវាងស្ត្រី និងបុរសគឺមិនមានភាពខុសគ្នាទៅតាមលក្ខណៈស្ថិតិនៅ α=0,0៥ សម្រាប់ប្រភេទ "ទៅជ្រកកោនក្នុងជម្រកដែលបានបានរៀបចំរួច"។*

## គ្រោះមហន្តរាយបានបង្កផលអាក្រក់លើការថែទាំសុខភាព ឬការងារក្នុងគ្រួសារមិនទទួលបាន ប្រាក់កម្រៃ ត្រូវបានធ្លាក់បន្ទុកលើស្ត្រី

នៅកម្ពុជា បន្ទុកការងារ និងការថែទាំគ្រួសារដែលមិនទទួលបានសាច់ប្រាក់បានកើនឡើង បណ្តាលមកពីគ្រោះមហន្តរាយឆ្នាំ២០២៤ និងគ្រោះថ្នាក់ពាក់ព័ន្ធ ជាមួយនឹងការកើនឡើងហានិភ័យនៃជំងឺដាច់សរសៃឈាមខួរក្បាល និងជំងឺដែលឆ្លង ។ ឪពុកម្តាយ និងអ្នកថែទាំជាច្រើនមិនមានជម្រើសអ្វីក្រៅពីកាត់បន្ថយម៉ោងធ្វើការ និងវេលាផ្ទាល់ខ្លួន ដើម្បីផ្តល់ការថែទាំ និងមើលការខុសត្រូវលើសមាជិកគ្រួសារ។ ដោយសារប្រភពទឹកប្រើប្រាស់ និងការផ្គត់ផ្គង់ត្រូវបានអាក់ខានដោយការកើនឡើងកំដៅ គ្រោះរាំងស្ងួត និងខ្យល់ព្យុះ ប្រជាពលរដ្ឋជាច្រើនត្រូវចំណាយពេលវេលាបន្ថែមទៀតក្នុងការទិញអាហារ និងទឹក ហើយកែច្នៃវាសម្រាប់ការប្រើប្រាស់ប្រកបដោយសុវត្ថិភាព បន្ទុកកើនឡើងទាំងនេះត្រូវបាន ធ្លាក់លើស្ត្រី (រូបភាពទី១០) ។ ស្ត្រីប្រមាណ ២៦ភាគរយបានកត់សម្គាល់ឃើញថាមានបន្ទុកការងារថែទាំកូនៗមិនបានទទួលប្រាក់កម្រៃ បណ្តាលមកពីគ្រោះមហន្តរាយ បើទោះបីជាគាត់មានការងារភាគច្រើនរួចទៅហើយ មុនពេលគ្រោះមហន្តរាយកើតឡើងក៏ដោយ។ លើសពីនេះទៀត ១៩ ភាគរយនៃពួកគាត់បានកត់សម្គាល់ឃើញមានការកើនឡើងពេលវេលាដែលចំណាយលើការថែទាំមនុស្សពេញវ័យផ្សេងទៀត។ ដើម្បីទប់ទល់នឹងការកើនឡើងនៃបន្ទុកការងារដែលបណ្តាលមកពីការខូចខាតផ្ទះសម្បែងដែលទាក់ទងនឹងគ្រោះមហន្តរាយ ប្រភពទឹកប្រើប្រាស់ និងផលប៉ះពាល់លើការផ្គត់ផ្គង់ទឹក ស្ត្រី ២០ ភាគរយ និងបុរស ១៨ ភាគបានចំណាយពេលវេលាច្រើនជាងមុនលើការងារផ្ទះ រួមទាំងការចម្អិនអាហារ ការកែច្នៃទឹកសម្រាប់ប្រើប្រាស់ និងការលាងសម្អាត (ជាធម្មតាធ្វើឡើងដោយស្ត្រី) ការជួសជុលផ្ទះ ឬជួសជុលជម្រកសត្វដែលសកម្មភាពជារឿយៗធ្វើឡើងដោយបុរស) ។

រូបភាពទី១០. សមាមាត្រ ប្រជាជនដែលប្រឈមនឹងគ្រោះថ្នាក់ក្នុងរយៈពេល ១២ ខែចុងក្រោយ បានចំណាយវេលាកើនឡើងលើការថែទាំ និងការងារផ្ទះមិនទទួលបានកម្រៃ តាមភេទ និងប្រភេទការងារ (ភាគរយ)



ស្ត្រី ៥ភាគរយ និងបុរស ៦ ភាគរយ រងផលប៉ះពាល់ដល់ប្រភពទឹកប្រើប្រាស់បង្កដោយគ្រោះមហន្តរាយ  ស្ត្រី១១ ភាគរយ និង បុរស១៤ភាគរយ បានកត់សម្គាល់ថាមាន កង្វះខាតទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារគាត់ ។ លទ្ធផលទាំងនេះបណ្តាលឱ្យស្ត្រី ១៣ ភាគរយ និងបុរស ១៦ ភាគរយ បានចំណាយពេលវេលាកើនឡើងជាងមុនដើម្បីទៅយកទឹកមកប្រើប្រាស់ (រូបភាពទី១១)។ ការទៅយកទឹកនេះអាចបង្កជាបញ្ហាសុខភាព និងសុវត្ថិភាព ដូចជាមានទម្ងន់ធ្ងន់  និងការដើរផ្លូវឆ្ងាយតែម្នាក់ឯង។ ក្នុងករណីខ្លះទឹកអាចត្រូវការធ្វើកែច្នៃមុនពេលទទួលទាន ដែលជាបន្ទុកបន្ថែមពេលវេលាដែលស្ត្រីតែងតែអនុវត្ត។

វិបត្តិឆ្នាំ ២០២៤ នៅកម្ពុជាក៏បានជះឥទ្ធិពលដល់ការប្រើប្រាស់ឥន្ធនៈស្អាតផងដែរ។ ប្រមាណ ៣ ភាគរយត្រូវប្តូរទៅប្រភពឥន្ធនៈមិនស្អាតសម្រាប់បំភ្លឺ ឬចម្អិនអាហាររយៈពេលជាងពីរសប្តាហ៍បន្ទាប់ពីគ្រោះមហន្តរាយ។ នេះអាចបណ្តាលមកពីបញ្ហាដំណើរការផ្គត់ផ្គង់ឥន្ធនៈ  ដូចគ្នានេះ ការប្រែប្រួលនៃតម្លៃ និងបរិមាណចំណាយក៏ជាកត្តាដែលធ្វើឱ្យ ប្រជាពលរដ្ឋជាច្រើនមិនអាចទិញប្រេងឬឧស្ម័នស្អាតប្រើប្រាស់ផងដែរ។ ការប្រើប្រាស់ឥន្ធនៈតម្លៃថោក ដូចជាធ្យូង អុស និងប្រេងកាត ធ្វើឱ្យគុណភាពខ្យល់ក្នុងផ្ទះកាន់តែអាក្រក់ និងចំណាយពេលវេលាច្រើនជាងមុន រួមទាំងបង្កហានិភ័យខ្ពស់នៃជំងឺផ្លូវដង្ហើម និងសរសៃឈាមបេះដូងជាពិសេសលើស្ត្រី និងកុមារ ។ បើទោះបីជាការចំណាយពេលទៅយកទឹកកើនឡើងត្រូវបានទទួលខុសត្រូវជាចម្បងដោយបុរសក៏ដោយ  ប៉ុន្តែស្ត្រី និងបុរសភាគច្រើនមានឱកាសស្មើគ្នាដែលបានចំណាយពេលវេលា សម្រាប់ទៅយក ឬទៅរកឥន្ធនៈ ក៏បានកើនឡើងដោយសារគ្រោះមហន្តរាយ ឬហានិភ័យពាក់ព័ន្ធ។

### រូបទី ១១.  ភាគរយ ប្រជាជនដែលបានជួបគ្រោះមហន្តរាយក្នុងរយៈពេល ១២ ខែចុងក្រោយ និងបានចំណាយពេលវេលាកើនឡើង សម្រាប់ទៅប្រមូលទឹក និងឥន្ធនៈ បែងចែកតាមភេទ (ភាគរយ)




*ចំណាំ៖ ភាពខុសគ្នារវាងស្ត្រី និងបុរស មិនមានន័យខុសគ្នាបែបស្ថិតិនៅកម្រិត α = ០,០៥ សម្រាប់ប្រភេទ "ពេលវេលាកើនឡើងសម្រាប់ប្រមូលឥន្ធនៈ និងអុសទេ"*

## ការខូចខាតរចនាសម្ព័ន្ធ ផ្ទះសម្បែង ផ្លូវ និងបណ្ដាញអគ្គិសនី បានបន្ថយនូវសុវត្ថិភាពរបស់ស្ត្រី

គ្រោះមហន្តរាយក្នុងឆ្នាំ ២០២៤ បានបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរដល់ផ្ទះសម្បែង និងរចនាសម្ព័ន្ធសាធារណៈ។ ប្រជាពលរដ្ឋ ១១ ភាគរយ បានឆ្លើយថាផ្ទះរបស់ខ្លួនរងការខូចខាត ខណៈដែលស្ត្រីប្រហែល ៣ ភាគរយ និងបុរស ២ ភាគរយបានខូចខាតផ្ទះទាំងស្រុង (មើលរូបទី១២)។ បាតុភូតខ្យល់កន្ត្រាក់ ទឹកជំនន់ និងព្យុះ គឺជាបាតុភូតដ៏សំខាន់បង្កឱ្យមានការខូចខាតកម្រិតនេះ ។ ក្រៅពីនេះ ក៏មានប្រជាពលរដ្ឋច្រើនជាង ៥ ភាគរយ បានសម្គាល់ឃើញថា ប្រភពទឹកសម្រាប់បរិភោគរបស់ពួកគាត់ត្រូវបានរងប៉ះពាល់ និងប្រមាណ ៣ភាគរយ ត្រូវប្រើប្រាស់ឥន្ទនៈមិនស្អាតរយៈពេលច្រើនជាងពីរសប្តាហ៍ផងដែរ ប្រព័ន្ធអនាម័យក៏ត្រូវប៉ះពាល់ផងដែរ។ ប្រជាពលរដ្ឋ ៥ ភាគរយ បានចាប់ផ្តើមប្រើប្រាស់បង្គន់រួមជាមួយគ្រួសារផ្សេងទៀត ខណៈដែល ១ភាគរយត្រូវប្រែទៅប្រើប្រាស់បង្គន់មិនកែលម្អ រួមមាន បង្គន់សាធារណៈ ឬបន្ទោរបង់ពាសវាលពាសកាល។ ការប្រើប្រាស់បង្គន់រួម មិនមានភ្លើងបំភ្លឺគ្រប់គ្រាន់ ឬមិនមានសោរចាក់ត្រឹមត្រូវ គឺជាកត្តាដែលបង្កហានិភ័យខ្ពស់ចំពោះសុវត្ថិភាពជាពិសេសលើស្ត្រី។ បញ្ហាអំពីសុវត្ថិភាពនេះអាចបង្កកាន់តែធ្ងន់ធ្ងរ ដោយសារការខ្វះខាតអគ្គិសនីដែលបណ្តាលមកពីគ្រោះមហន្តរាយ។ នៅកម្ពុជា ច្រើនជាង ៤០ភាគរយនៃអគ្គិសនីផលិតចេញពីវ៉ារីអគ្គិសនី បាតុភូតរាំងស្ងួតខ្លាំង អាចបានបណ្តាលឱ្យមានការខ្វះខាតអគ្គិសនី និងកាត់ផ្តាច់ចរន្តអគ្គិសនីនៅឆ្នាំ ២០២៤។ ការខ្វះខាតការផ្គត់ផ្គង់ចរន្តអគ្គិសនី និងភ្លើងបំភ្លឺសាធារណៈបានបន្ថែមភាពមិនប្រាដកប្រជាផ្នែកសេដ្ឋកិច្ច និងសម្ពាធផ្សេងៗដែលបណ្តាលមកពីគ្រោះមហន្តរាយ និងបង្កឱ្យមានបទឧក្រិដ្ឋ និងកាត់បន្ថយសុវត្ថិភាពសធារណៈ។ តាមការប៉ាន់ស្មាន ប្រហែល ៣ ភាគរយនៃប្រជាជនបានរាយការណ៍ថា មានអំពើឧក្រិដ្ឋកម្មកើនឡើង ខណៈដែល ២ ភាគរយបាននិយាយថា គាត់បានស្គាល់នរណាម្នាក់ដែលបានជួបប្រទះអំពើហិង្សាបន្ទាប់ពីគ្រោះមហន្តរាយ (មើលរូបទី១៣)។

**រូបភាពទី១២៖ សមាមាត្រ ប្រជាជនបានរងគ្រោះថ្នាក់ក្នុងរយៈពេល ១២ ខែចុងក្រោយ ដែលផ្ទះសម្បែងរបស់គាត់បានរងប៉ះពាល់ខូចខាត ឬបំផ្លាញ បែងចែងតាមភេទ និងកម្រិតនៃការខូចខាត (ជាភាគរយ)**




ចំណាំ៖ មិនមានភាពខុសប្លែកគ្នារវាងស្ត្រី និងបុរស បែបតាមស្ថិតិនៅ α=0,0៥ សម្រាប់ប្រភេទ "លំនៅដ្ឋានត្រូវបានខូចខាត"

### រូបភាពទី១៣៖ សមាមាត្រ ប្រជាជនបានរងគ្រោះថ្នាក់ក្នុងរយៈពេល ១២ខែចុងក្រោយ ដែលបានបញ្ជាក់ថា មានបទឧក្រិដ្ឋកម្ម ឬអំពើហឹង្សាធ្ងន់ធ្ងរ បន្ទាប់ពីមានគ្រោះថ្នាក់ បែងចែកតាមភេទ និងប្រភេទនៃហេតុការណ៍ (ឧក្រិដ្ឋកម្ម/អំពើហឹង្សា) (ជាភាគរយ)




ចំណាំ៖ មិនភាពខុសគ្នារវាងស្ត្រី និងបុរសគឺក្នុងន័យស្ថិតិនៅ α=០,០៥ សម្រាប់ប្រភេទទាំងពីរនៃប្រភេទទាំងពីរនោះទេ។

ការខូចខាតហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវបានប៉ះពាល់ដល់ប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដោយប្រជាជន ២ភាគរយបាត់បង់ឱកាសប្រើប្រាស់សេវារថយន្តសាធារណៈ ដោយសារគ្រោះមហន្តរាយ និងគ្រោះថ្នាក់ផ្សេងៗ។ ស្ត្រីមានអត្រាតិចជាងបុរសការប្រើប្រាស់យានយន្តផ្ទាល់ខ្លួន (មើលរូបទី ៨៥ ដល់ ៨៨) ការខ្វះសេវាដឹកជញ្ជូនសាធារណៈអាចធ្វើឱ្យគាត់ប្រឈមនឹងបញ្ហាសុវត្ថិភាពកាន់តែខ្ពស់។ បន្ទាប់ពីមានគ្រោះមហន្តរាយ តំបន់ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរមួយចំនួន ក៏អាចប្រឈមនឹងការទទួលបានសេវាសុខាភិបាល និងសេវាសាធារណៈផ្សេងទៀតផងដែរ។ ការបាត់បង់ឱកាសប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈអាចបង្កហានិភ័យខ្លាំងសម្រាប់អ្នកជំងឺ និងអ្នករងរបួស មនុស្សចាស់ និងស្ត្រីមានផ្ទៃពោះ។

## ការទទួលបានការព្រមានអំពីគ្រោះថ្នាក់សម្រាប់ការត្រៀមខ្លួនទុកជាមុនសម្រាប់ការឆ្លើយតប

ប្រមាណពីរនាក់ក្នុងចំណោមប្រាំនាក់ (៤២ភាគរយ) បានទទួលព័ត៌មាន អំពីការកើនឡើងកំដៅ ដែលបានជួយគាត់ក្នុងការត្រៀមខ្លួនជាមុនសម្រាប់ហេតុការណ៍នេះ។ ប៉ុន្តែព័ត៌មានអំពីគ្រោះរាំងស្ងួតដែលបានវាយប្រហារ ទូទាំងប្រទេសក្នុងរយៈពេលមួយឆ្នាំ មិនទាន់បានផ្សព្វផ្សាយយ៉ាងទូលំទូលាយនោះទេ ដោយមានប្រជាជនតែ ២៦ភាគរយប៉ុណ្ណោះ បានទទួលព័ត៌មាននេះ ជាពិសេសតាមរយៈអ៊ីនធឺណិត (មើលរូបភាព១៤a និង១៤b)។ កង្វះខាតការផ្សព្វផ្សាយនេះអាចជាបញ្ហាសម្រាប់ការត្រៀមខ្លួនជាមុនក្នុងការទប់ស្កាត់គ្រោះថ្នាក់នេះ ដែលមានផលប៉ះពាល់ធ្ងន់ធ្ងរជាងគេក្នុងចំណោមគ្រោះមហន្តរាយឆ្នាំ ២០២៤ ដោយបានបង្កការប៉ះពាល់ដល់ជីវភាព (ប្រាក់ចំណូល និងផលដំណាំ) និងប៉ះពាល់ដល់សុខភាពផ្លូវចិត្តរបស់ប្រជាជនផងដែរ។

នៅកម្ពុជា មានភាពខុសគ្នារវាងប្រជុំជន និងជនបទ ដែលបានទទួលព័ត៌មានព្រមានជាមុន ដោយប្រជាជននៅទីប្រជុំជនមានឱកាសទទួលបានព័ត៌មានច្រើនជាង។ មានភាពខុសគ្នាផងដែរ ការប្រើប្រាស់ប្រភពព័ត៌មាននានា

សម្រាប់ការព្រមានជាមុន ដោយបុរសមានច្រើនជាងស្ត្រី បានប្រើប្រាស់អ៊ីនធឺណិត ដោយឡែកស្ត្រីមានច្រើនជាងបុរសដោយពឹងផ្អែកលើសមាជិកគ្រួសារ មិត្តភក្តិ និងសមាជិកផ្សេងទៀតក្នុងសហគមន៍ (មើលរូបភាពទី១៥)។ ដោយសារប្រជាជនភាគច្រើននៅកម្ពុជាទទួលបានព័ត៌មានព្រមានជាមុនពីអ៊ីនធឺណិត (រួមទាំងបណ្ដាញសង្គម) ការពង្រឹងការចូលប្រើអ៊ីនធឺណិតអាចជួយដល់ការត្រៀមខ្លួនឱ្យប្រសើរឡើង។ ១៨ភាគរយនៃគ្រួសារ មិនបានប្រើប្រាស់អ៊ីនធឺណិតទាក់ទងនឹងគ្រោះមហន្តរាយ។ ជារួម ប្រជាជននៅជនបទមានឱកាសទាប ការប្រើឧបករណ៍អេឡិចត្រូនិចមួយចំនួនដើម្បីទទួលបានព័ត៌មានព្រមានជាមុន ខណៈប្រជាជននៅទីប្រជុំជន ប្រហែល ៩៤ ភាគរយមានឧបករណ៍ទំនើបទាំងនេះ និងមានប្រមាណ ៨៩ភាគរយ អ្នកនៅជនបទប៉ុណ្ណោះដែលមានមានឧបករណ៍ទំនើប (មើលរូបភាពទី ១៦)។

**រូបភាពទី ១៤៖ សមាមាត្រនៃចំនួនប្រជាជនដែលប្រឈមនឹង (ក) កំដៅខ្លាំង ឬ (ខ) គ្រោះរាំងស្ងួតក្នុងរយៈពេល ១២ ខែចុងក្រោយនេះ ដែលបានទទួលបានព័ត៌មានព្រមានជាមុន តាមភេទ ទីតាំង (ភាគរយ)**




ចំណាំ៖ មិនមានភាពខុសគ្នារវាងស្ត្រី និងបុរស ក្នុងន័យស្ថិតិនៅ α=0,0៥ សម្រាប់ប្រភេទ "ព័ត៌មានព្រមានជាមុនមានប្រយោជន៍" ក្នុងតំបន់ទីប្រជុំជនសម្រាប់ កំដៅខ្លាំង និងទាំងទីប្រជុំជន និងជនបទសម្រាប់គ្រោះរាំងស្ងួត។

### រូបភាពទី ១៥៖ សមាមាត្រប្រជាជនដែលប្រឈមនឹងគ្រោះថ្នាក់ក្នុងរយៈពេល ១២ខែចុងក្រោយ ដែលទទួលបានប្រភពព័ត៌មានការព្រមានជាមុនសម្រាប់ការកើនឡើងកម្ដៅខ្លាំង តាមភេទ និងប្រភព (ភាគរយ)




ចំណាំ៖ មិនមានភាពខុសគ្នារវាងស្ត្រី និងបុរសក្នុងន័យស្ថិតិនៅ α=០,០៥ សម្រាប់ប្រភេទ "ទូរទស្សន៍", "ទូរស័ព្ទ" និង "ផ្សេងទៀត", ក្រាហ្វនេះសំដៅទៅលើការកើនឡើងកំដៅខ្លាំងជាពិសេស ប៉ុន្តែការបែងចែកគឺស្រដៀងគ្នាសម្រាប់គ្រោះថ្នាក់ផ្សេងទៀតទាំងអស់។

### រូបភាពទី១៦៖ សមាមាត្រប្រជាជនដែលរស់នៅក្នុងគ្រួសារដែលមានគ្រឿងអេឡិចត្រូនិចជាមូលដ្ឋានសម្រាប់ការទទួលបានព័ត៌មានព្រមានជាមុន តាមភេទ និងទីតាំង




សម្គាល់៖ មិនមានភាពខុសគ្នារវាងស្ត្រី និងបុរសគឺក្នុងន័យស្ថិតិនៅ α=០,០៥

## នៅផ្ទះ៖ ស្ត្រីមាននិន្នាការចូលរួមក្នុងការត្រៀមខ្លួនចំពោះគ្រោះមហន្តរាយច្រើនជាងបុរស

ដើម្បីត្រៀមខ្លួនសម្រាប់គ្រោះថ្នាក់នឹងកើតមាន ស្ត្រី និងបុរស បានចំណាយពេលវេលា និងកម្លាំងក្នុងការរក្សាទុកទំនិញចាំបាច់ និងប្រមូលសម្ភារៈ រៀបចំផ្ទះសម្បែងអោយរឹងមាំ និងត្រៀមខ្លួនដើម្បីចាកចេញពីផ្ទះដើម្បីស្វែងរកជម្រកពីគ្រោះមហន្តរាយកើតមានខាងមុខ។ ស្ត្រីមាននិន្នាការខ្ពស់ជាងបុរសក្នុងការរៀបចំទុកដាក់ទាំងនេះ (មើលរូបភាពទី ១៧)។

ជារឿយៗបទដ្ឋានសង្គម បានកំណត់ពីប្រភេទនៃសកម្មភាពដែលស្ត្រី និងបុរសអាចធ្វើបាន រួមទាំងកិច្ចការដែលទាក់ទងនឹងការត្រៀមខ្លួននេះ។ គម្លាតយេនឌ័រដ៏ធំបំផុតក្នុងការត្រៀមលក្ខណៈទាក់ទងនឹងការរក្សាទឹក អាហារ និងថ្នាំពេទ្យ  កិច្ចការប្រុងប្រយ័ត្នដែលធ្វើឡើងដោយស្ត្រីនៅទូទាំងប្រទេស ព្រោះជាធម្មតាគាត់ទទួលខុសត្រូវលើការចម្អិនអាហារ និងការថែទាំសមាជិកគ្រួសារដែលឈឺ។ ម៉្យាងវិញទៀត បុរសជាអ្នកទទួលខុសត្រូវលើការថែរក្សាគ្រាប់ពូជ និងសម្ភារៈដាំដុះ ដោយសារគាត់ធ្វើកសិកម្មញឹកញាប់ជាងស្ត្រី ។ ជារួម វិធានការត្រៀមលក្ខណៈទូទៅច្រើនបំផុតចំនួនពីរមានទាំងបុរស និងស្ត្រី គឺស្នាក់នៅក្នុងផ្ទះ និងរក្សាទុកទឹកសម្រាប់ផឹក ដើម្បីត្រៀមក្នុងការឆ្លើយតបនឹងការកើនឡើងកម្ដៅ និងស្ថានភាពរាំងស្ងួត ដែលកើតមានជារឿយៗ។

**រូបភាពទី១៧៖ សមាមាត្រប្រជាជនប្រឈមនឹងគ្រោះថ្នាក់ក្នុងរយៈពេល ១២ ខែចុងក្រោយ ដាក់វិធានការប្រុងប្រយ័ត្នសម្រាប់ការរៀបចំគ្រោះមហន្តរាយ តាមភេទ និងប្រភេទវិធានការ (ភាគរយ)**




សម្គាល់៖ ក្រាហ្វបង្ហាញភាគរយជាមធ្យមសម្រាប់គ្រោះមហន្តរាយទាំងអស់ និងគ្រោះថ្នាក់ដែលទាក់ទងនឹងគ្រោះមហន្តរាយ មិនមានភាពខុសគ្នារវាងស្ត្រី និងបុរសក្នុងន័យស្ថិតិនៅ α=0,0៥ សម្រាប់ប្រភេទ "ពង្រឹងសម្ភារៈសាងសង់ជម្រកសត្វ" និង "ប្រមូលផល ឬរក្សាទុកដំណាំ"។

## ផ្នែកទី ២ .យុទ្ធសាស្ត្រ និងការទប់ទល់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

### ការប្រែប្រួលអាកាសធាតុបានជះឥទ្ធិពលដល់មនុស្សគ្រប់រូបនៅកម្ពុជាភាគច្រើន គេកត់សម្គាល់ឃើញតាមរយៈការកើនឡើងសីតុណ្ហភាព រលកកំដៅ និងគ្រោះរាំងស្ងួត

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុកើតមានឡើងគ្រប់តំបន់នៅកម្ពុជា។ ស្ទើរតែគ្រប់អ្នកផ្តល់ចម្លើយ បានកត់សម្គាល់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងជីវិតប្រចាំថ្ងៃរបស់គាត់។ ខុសពីព្រឹត្តិការណ៍គ្រោះមហន្តរាយដែលបានបង្ហាញនៅផ្នែកទី១ នៃរបាយការណ៍នេះ ការប្រែប្រួលអាកាសធាតុគឺជាគ្រោះថ្នាក់ដែលកើតឡើងយឺតៗ ហើយមានផលប៉ះពាល់រាលដាលជាយូរអង្វែងក្នុងពេលកន្លងមក។ ឧទាហរណ៍ មានប្រហែល ៧៣ ភាគរយនៃប្រជាជនបានអារម្មណ៍ពីផលប៉ះពាល់ផ្ទាល់ខ្លួន មានការកើនឡើងជាប់លាប់នៃកម្តៅ ៦៨ ភាគរយបានប្រឈមមុខរលកកំដៅខ្លាំង និង ៦២ ភាគរយបានសម្គាល់ឃើញមានការធ្លាក់ចុះនៃទឹកភ្លៀង។ ផលប៉ះពាល់ជាច្រើនទាំងនេះពាក់ព័ន្ធនឹងបាត់បង់ព្រៃឈើយ៉ាងច្រើននៅទូទាំងប្រទេស ដែលធ្វើឱ្យមានការរាំងស្ងួតឡើងយ៉ាងឆាប់រហ័ស និងការប្រែប្រួលអាកាសធាតុ។ នៅកម្ពុជា បានបាត់បង់ព្រៃឈើធម្មជាតិ ចំនួន ១,៤៤លានហិកតា ចាប់តាំងពីឆ្នាំ ២០០២ (៣៤ ភាគរយ) ដែលភាគច្រើនបណ្តាលមកពីការកាប់បំផ្លាញព្រៃឈើសម្រាប់ពាណិជ្ជកម្ម និងបន្តិចបន្តួចទៀតក៏មកពីភាពបត់បែនវិស័យព្រៃឈើ និងភាពបត់បែននៃកសិកម្ម[៦]។ ការបាត់បង់ព្រៃឈើនេះប៉ះពាល់ដល់ការប្តូរប្រព័ន្ធសំណើមរវាងដី និងបរិយាកាស ហើយនាំឱ្យមានការស្ងួតឡើង។ បន្ថែមលើសពីនេះទៅទៀត ការថយចុះគម្របព្រៃឈើ សមត្ថភាពនៃការស្រូបកាបូនឌីអុកស៊ីតក៏កាន់តែធ្លាក់ចុះផងដែរ ដែលបណ្តាលឱ្យមានការកើនឡើងកម្តៅ។ ទាំងនេះរួមជាមួយនឹងការកើនឡើងដល់ប្រាំមួយដងនៃការបញ្ចេញឧស្ម័នកាបូនឌីអុកស៊ីតចន្លោះឆ្នាំ ២០០៥ ដល់ ២០២៣ បានធ្វើឱ្យកម្តៅកាន់តែខ្លាំង និងធ្វើឱ្យកម្រិតទឹកភ្លៀងកាន់តែពិបាកព្យាករណ៍បាន[៧]។

ការប្រែប្រួលអាកាសធាតុបាននាំមកនូវការរីករាលដាលជាច្រើននៃសត្វល្អិតបំផ្លាញដំណាំ និងជម្ងឺរាលដាលដោយសត្វល្អិតតាមតំបន់នៅកម្ពុជា។ ជាង ៤០ភាគរយ ប្រជាជនបានរងផលប៉ះពាល់ពីសត្វល្អិតបំផ្លាញដំណាំ និងប្រហែល ៣៣ភាគរយបានរងផលប៉ះពាល់ពីជម្ងឺរាលដាលដោយសត្វល្អិត។ សត្វល្អិតដូចជា សត្វរុយស ពពួកសត្វដង្កូវ និងដង្កូវម្ទេស្លឹក និងសត្វស៊ីស្លឹកស្រូ បានប៉ះពាល់ដល់ដំណាំនៅក្នុងខេត្តជាច្រើន រួមមាន កណ្តាល ព្រៃវែង ស្វាយរៀង តាកែវ និងត្បូងឃ្មុំ។ ម្យ៉ាងទៀត ជំងឺរាលដាលតាមសត្វល្អិតដូចជា ជំងឺគ្រុនឈាម ក៏កំពុងកើនឡើងផងដែរ ដោយមានករណីកើនឡើងជាងពីរដងបន្ទាប់ពីឆ្នាំ ២០០២។[៨] ការប្រើប្រាស់ជីសារធាតុគីមីលើសកម្រិតក្នុងវិស័យកសិកម្ម បានជួយជំរុញឱ្យសត្វល្អិតរីករាលដាលយ៉ាងលឿន ខណៈដែលមានការបាត់បង់ព្រៃឈើ និងការអភិវឌ្ឍន៍ទីក្រុងយ៉ាងរហ័ស ក៏អាចជាហេតុនាំឱ្យជំងឺគ្រុនឈាមរីករាលដាលផងដែរ។ ផលប៉ះពាល់ជាក់លាក់របស់សត្វល្អិត និងជំងឺទាំងនេះលើស្ត្រី និងបុរស រួមមាន៖ ការធ្លាក់ចុះសុខភាព ការបាត់បង់ចំណូល ការចំណាយពេលធ្វើការច្រើនជាងមុន និងការកើនឡើងការងារផ្ទះ និងថែទាំគ្រួសារ។

[៦] Global Forest Watch, ២០២៥, Dashboard: Cambodia (accessed ៩ April ២០២៥).

[៧] Our world in data, ២០២៤.

[៨] វិទ្យាស្ថានជាតិសុខភាពសាធារណៈ, ២០២៣.

## រូបភាព១៨៖ ភាគរយ ប្រជាជនបានជួបប្រទះនឹងហានិភ័យពាក់ព័ន្ធការប្រែប្រួលអាកាសធាតុមួយឬច្រើន តាមភេទ




ដាក់ចេញវិធានការការពារ ការប្រែប្រួលអាកាសធាតុគឺសំខាន់ណាស់សម្រាប់ការប្រឈមមុខនឹងផលប៉ះពាល់ ការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងណាក៏ដោយ មិនមែនគ្រប់គ្នាសុទ្ធតែអាចទទួលបានព័ត៌មានត្រឹមត្រូវ និងទាន់ពេលវេលាទាក់ទងនឹងអាកាសធាតុនោះទេ។ ខណៈពេលដែលព័ត៌មានអំពីគ្រោះថ្នាក់អាកាសធាតុមួយចំនួន ដូចជាការកើនឡើងជានិរន្តរភាពនៃសីតុណ្ហភាព និងរលកកំដៅ មាន ១៤ ភាគរយប៉ុណ្ណោះដែលបានឮអំពីផលប៉ះពាល់នៃសត្វល្អិតបំផ្លាញដំណាំ និង ២០ភាគរយដឹងអំពីជំងឺដែលបណ្ដាលមកពីសត្វល្អិត។ ប្រភពព័ត៌មានដែលទទួលបានមានភាពខុសៗគ្នាតាមការគ្រោះថ្នាក់។ ប្រភពព័ត៌មានច្រើនដែលទទួលបានច្រើនជាង គឺការកើនឡើងសីតុណ្ហភាព រលកកំដៅ និងកង្វះទឹកភ្លៀងគឺតាមរយៈអ៊ីនធឺណិត(រូបភាព១៩ក)។ ប្រព័ន្ធ និងសេវាផ្សព្វផ្សាយបានគ្របដណ្ដប់លើសីតុណ្ហភាព និងទម្រង់នៃទឹកភ្លៀង ប្រជាជនអាចទទួលបានព័ត៌មាននេះតាមរយៈអ៊ីនធឺណិតទូរទស្សន៍ និងប្រភពផ្សេងៗទៀត។ សម្រាប់ព័ត៌មានស្ដីពីសត្វល្អិតបំផ្លាញដំណាំ និងជំងឺបង្កឡើងដោយសត្វល្អិតប្រជាពលរដ្ឋភាគច្រើនពឹងផ្អែកលើសហគមន៍ និងមិត្តភក្តិរបស់ពួកគេ ជាពិសេសស្ត្រី ៤២ភាគរយ បានឮអំពីជំងឺដែលបង្កឡើងដោយសត្វល្អិត បើធៀបនឹងបុរស៤០ភាគរយ។ ករណីជំងឺដែលបង្កឡើងដោយសត្វល្អិត ខណៈដែលសហគមន៍គឺជាប្រភពព័ត៌មានសំខាន់សម្រាប់ទាំងស្ត្រី និងបុរស ព័ត៌មាននៅមូលដ្ឋានបានដើរតួនាទីយ៉ាងសំខាន់ផងដែរ៖ ស្ត្រី ១៩ភាគរយ និងបុរស ២៥ ភាគរយបានទទួលព័ត៌មានទាំងនេះ (រូបភាព១៩ខ)។មានភាពខុសគ្នាផ្នែកយេនឌ័រ ការទទួលព័ត៌មានសំខាន់ៗសម្រាប់រៀបចំខ្លួនដើម្បីប្រឈមមុខនឹងការប្រែប្រួលអាកាសធាតុ និងអនុវត្តវិធានការទប់ស្កាត់ផលប៉ះពាល់របស់វា។ ជាទូទៅ បុរសមានច្រើនជាងស្ត្រី ទទួលបានព័ត៌មានតាមអ៊ីនធឺណិត ខណៈស្ត្រីវិញអះអាងថាពួកគាត់ពឹងផ្អែកលើមិត្តភក្តិ គ្រួសារ ឬសហគមន៍ច្រើនជាងបុរស។ ដូចជាករណីហានិភ័យដែលបង្កដោយសត្វល្អិតដែលបានលើកឡើងខាងលើ សម្រាប់ការទទួលបានព័ត៌មាននៅសហគមន៍បុរសមាននិន្នាការច្រើនជាងស្ត្រី។ យើងអាចពន្យល់ពីភាពខុសគ្នានៃអត្រាអក្ខរភាព (ស្ត្រីមានអត្រាអក្ខរភាពជាងបុរស) និងការប្រើប្រាស់ ទូរស័ព្ទដៃ កុំព្យូទ័រ និងអ៊ីនធឺណិតតិចជាងបុរសផងដែរ (បុរស មានច្រើនជាងស្ត្រីដែល

មានទូរស័ព្ទដៃ[៩] )។

**រូបភាពទី១៩៖ ភាគរយ ប្រជាជន ទទួលបានព័ត៌មានអំពីផលប៉ះពាល់នៃ (ក) ការថយចុះចំនួនទឹកភ្លៀង និង (ខ) ជំងឺ ឆ្លងដោយសត្វល្អិត បែងចែកតាមភេទ និងប្រភពព័ត៌មាន (ភាគរយ)**




៩ យោងតាមមូលដ្ឋានទិន្នន័យ SDG សកល ៧០.៩ ភាគរយនៃបុរស និង ៧២.៣ ភាគរយនៃស្ត្រីជាម្ចាស់ទូរស័ព្ទចល័តក្នុងឆ្នាំ ២០១៩ ។

## ស្ត្រីមាននិន្នាការលះបង់អាហារូបត្ថម្ភរបស់ខ្លួន ដើម្បីឆ្លើយតបនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ

ដោយសារគ្រោះមហន្តរាយនៃការប្រែប្រួលអាកាសធាតុ ស្ត្រី ១២ភាគរយ និងបុរស ៩ភាគរយ បានបរិភោគអាហារតិចជាងមុន ពីព្រោះខ្វះអាហារឬប្រាក់ចំណូលដើម្បីទិញ (រូបទី ២០)។ វិធីសាស្ត្រដោះស្រាយបែបនេះបង្កឱ្យមានការព្រួយបារម្ភខ្ពស់ចំពោះសុខភាព ដោយសារពលរដ្ឋទូទៅនិយមកាត់បន្ថយបរិមាណអាហារជាជម្រើសចុងក្រោយ បន្ទាប់ពីព្យាយាមដោះស្រាយដោយការជ្រើសរើសអាហារដែលមានតម្លៃថោក ដែលមានគុណភាពនិង អាហារូបត្ថម្ភទាប។ បុរស ឬស្ត្រី ពោះម៉ាយ ឬមេម៉ាយមានកូននៅក្នុងបន្ទុកភាគច្រើនគាត់បានកាត់បន្ថយអាហាររបស់ខ្លួនដើម្បីផ្តល់ឱ្យកូន (២០ ភាគរយបានប្រើវិធីសាស្ត្រនេះ)។ នៅក្នុងគ្រួសារដែលមានមនុស្សពេញវ័យពីរនាក់ ស្ត្រីតែងតែជាអ្នកកាត់បន្ថយអាហាររបស់ខ្លួនសម្រាប់សមាជិកគ្រួសារផ្សេងទៀត ជាញឹកញាប់ជាងបុរស ស្ត្រី( ១២ ភាគរយ បើប្រៀបធៀបនឹង បុរស៩ ភាគរយ)។ យុទ្ធសាស្ត្រដោះស្រាយផ្សេងទៀត ត្រូវបានអនុវត្តន៍ រួមមានការរក្សាទុកអាហារដោយសារតែអាហារមានកំណត់ និងការស្វែងរកប្រភពចំណូលបន្ថែម។ ខណៈពេលដែលស្ត្រីជាទូទៅភាគច្រើនបានលះបង់អាហារ និងរក្សាអាហារដើម្បីទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ចំណែកបុរសបានស្វែងរកប្រភពចំណូលបន្ថែម (រូបភាពទី ២១)។

រូបភាពទី២០: សមាមាត្រ ប្រជាជន បានកាត់បន្ថយការទទួលទានអាហារ បណ្តាលមកពីការប្រែប្រួលអាកាសធាតុ តាមភេទ និងសមាសភាពគ្រួសារ (ភាគរយ)




រូបភាពទី២១៖ សមាមាត្រ ប្រជាជនដែលជួបប្រទះការខ្វះខាត (ប្រាក់ចំណូល និង/ឬអាហារ) បណ្តាលមកពីការប្រែប្រួលអាកាសធាតុ តាមភេទ និងប្រភេទ (ភាគរយ)



## ការប្រែប្រួលអាកាសធាតុបានធ្វើឱ្យសុខភាពរបស់មនុស្ស ចំនួនបួននាក់ក្នុងចំណោមប្រាំនាក់រងផលប៉ះពាល់ធ្ងន់ធ្ងរ និងបន្ថែមបន្ទុកដល់ស្ត្រី លើការងារថែទាំដោយគ្មានប្រាក់កម្រៃ

ផលប៉ះពាល់ការប្រែប្រួលអាកាសធាតុបានប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅ ជាពិសេសសម្រាប់អ្នកមានការងារផ្អែកលើកសិកម្ម នេសាទ និងមុខរបរផ្សេងទៀតទាក់ទងនឹងបរិស្ថាន។ លើសពីផលប៉ះពាល់នៃគ្រោះមហន្តរាយលើសុខភាពផ្លូវចិត្ត (ដូចដែលបានបង្ហាញក្នុងផ្នែកទី១) អស្ថិរភាពសេដ្ឋកិច្ចដែលទាក់ទងនឹងអាកាសធាតុ និងអសន្តិសុខស្បៀង គួបផ្សំនឹងការផ្លាស់ទីលំនៅ និងការព្រួយបារម្ភអំពីសុវត្ថិភាព បានជះឥទ្ធិពលបន្ថែមទៀតដល់សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ប្រជាពរដ្ឋ។ ប្រមាណជា ៧៧ ភាគរយ ឬបួននាក់ក្នុងចំណោមប្រាំនាក់ បានបញ្ជាក់ថា គ្រោះមហន្តរាយនៃការប្រែប្រួលអាកាសធាតុ បានប៉ះពាល់ដល់សុខភាពផ្លូវចិត្តរបស់គាត់ (ដូចបានបង្ហាញក្នុងរូប២២)។ លើសពីនេះ ស្ត្រី៤៨ ភាគរយ និង បុរស៤៥ ភាគរយ បានបង្ហាញថាការប្រែប្រួលអាកាសធាតុ បានប៉ះពាល់ដល់សុខភាពរាងកាយរបស់គាត់ផងដែរ។ ចាប់ពីជម្ងឺផ្លូវដង្ហើមដែលកើតឡើងដោយករណីកើនឡើងការឆេះព្រៃ ជម្ងឺទាក់ទងនឹងប្រព័ន្ធរំលាយអាហារ ដែលបណ្ដាលមកពីការរីរាលដាលនៃភ្នាក់ងារបង្កជំងឺកាន់តែអាក្រក់ ដែលបង្កឡើងដោយការមិនព្យាករណ៍បាននូវទឹកភ្លៀង និងបញ្ហាបេះដូងដែលបង្កឡើងដោយកម្ដៅខាងក្រោមមានជាច្រើនប្រភេទផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើសុខភាពរាងកាយរបស់មនុស្ស។ នៅកម្ពុជា ការកើនឡើងសីតុណ្ហភាព រលកកម្ដៅ និងការធ្លាក់ចុះចំនួនទឹកភ្លៀង គឺជាប្រភេទគ្រោះមហន្តរាយដែលភាគច្រើននៃអ្នកឆ្លើយតប ថាមានទំនាក់ទំនងនឹងសុខភាពរបស់គាត់។ ជាទូទៅស្ត្រីមានអត្រាខ្ពស់ជាងបុរសដែលប៉ះពាល់ដល់សុខភាពរបស់ខ្លួនដោយផ្ទាល់។

**រូបភាពទី ២២.ភាគរយ ប្រជាជនមានជំងឺទាក់ទងសុខភាព អាចបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ បែងចែកតាមភេទ និងប្រភេទជំងឺ(ភាគរយ)**




សម្គាល់៖ មិនមានភាពខុសគ្នារវាងស្ត្រី និងបុរសក្នុងន័យស្ថិតិនៅកម្រិត α = ០.០៥ សម្រាប់សុខភាពផ្លូវចិត្ត

ពេលសមាជិកគ្រួសារមានជំងឺ ជាធម្មតាស្ត្រីជាអ្នកទទួលខុសត្រូវក្នុងការថែទាំគាត់។ យោងតាមទិន្នន័យនៅឆ្នាំ ២០២៣ ស្ត្រីបានចំណាយពេល៩ដង ច្រើនជាងបុរស លើការងារថែទាំសុខភាព និងកិច្ចការផ្ទះដែលមិនទទួលបានប្រាក់កម្រៃ នេះមានន័យថាស្ត្រីជាមនុស្សសំខាន់បំផុតក្នុងការផ្ដល់អាហារ សម្អាត និងផ្ដល់ការថែទាំផ្នែករាងកាយ

និងសុខភាពដល់កុមារ មនុស្សចាស់ និងមនុស្សពេញវ័យផ្សេងទៀត។[១០] ដើម្បីឆ្លើយតបនឹងកើនឡើងបន្ទុកការងារថែទាំសុខភាព ដោយសារការប្រែប្រួលអាកាសធាតុ ប្រហែល ស្ត្រី៣១ភាគរយ និង បុរស២៨ភាគរយ បានចំណាយពេលច្រើនជាងមុនក្នុងការថែទាំសមាជិកគ្រួសារ (រូបភាពទី២៣)។ ដូចដែលបានដឹង ស្ត្រីភាគច្រើនត្រូវបានទទួលបន្ទុកការងារទាំងនេះជាស្រេចរួចហើយ ការបន្ថែមការងារ បង្ហាញថា ការប្រែប្រួលអាកាសធាតុកំពុងធ្វើឱ្យមានភាពមិនស្មើគ្នាកាន់តែច្រើនក្នុងវិស័យនេះ។

ស្ត្រីក៏បានប្រឈមនឹងការកើនឡើងពេលវេលាដែលគាត់ចំណាយលើកិច្ចការងារផ្ទះ ដូចជា ចម្អិនម្ហូបអាហារ បោសសម្អាតផ្ទះ និងចេញទៅទិញទំនិញសម្រាប់គ្រួសារ។ ប្រមាណ ស្ត្រី១៨ ភាគរយ និង បុរស១៦ ភាគរយ កិច្ចការងារផ្ទះបានកើនឡើង។ ភាពខុសគ្នារវាងភេទមិនច្រើនប៉ុន្មានសម្រាប់កិច្ចការផ្ទះនេះ ពីព្រោះបុរសមួយចំនួនក៏បានចូលរួមធ្វើការងារផ្ទះផងដែរ ដូចជា ការជួសជុល ឬពង្រឹងរចនាសម្ព័ន្ធផ្ទះ ដើម្បីការពារផ្ទះពីបាតុភូតអាកាសធាតុ ដូចជាខ្យល់ខ្លាំង ឬកំដៅខ្លាំង។ ឧទាហរណ៍៖ ប្រហែល ២ ភាគរយនៃបុរស បានបង្ហាញថា គាត់ជួសជុល ឬផ្លាស់ប្តូរផ្ទះរបស់ខ្លួន ដើម្បីឆ្លើយតបនឹងបញ្ហាការប្រែប្រួលអាកាសធាតុដែលកើតឡើង ប្រៀបធៀបនឹងស្ត្រីគឺមានតែ១ភាគរយប៉ុណ្ណោះ។[១១] ប៉ុន្តែការចម្អិនម្ហូបអារហារ និងសម្អាតផ្ទះ នៅតែជាកិច្ចការដែលស្ត្រីទទួលខុសត្រូវជាចម្បង តម្រូវការទាំងនេះកាន់តែបន្ថែមឡើង ក្នុងស្ថានភាពការខ្វះខាតអាហារ និងជំងឺឆ្លងតាមទឹកកើនឡើង។ ដូច្នេះស្ត្រីក៏នៅតែប្រឈមនឹងផលប៉ះពាល់នេះជាបន្តទៀត។

### រូបភាពទី ២៣. ភាគរយ ប្រជាជនដែលចំណាយពេលថែទាំ (ខាងឆ្វេង) ឬកិច្ចការផ្ទះ (ខាងស្តាំ) បានកើនឡើងដោយសារការប្រែប្រួលអាកាសធាតុ បែងចែកតាមភេទ (ភាគរយ)




១០ UN Women, ២០២៣, ការព្យាករណ៍ពេលវេលាចំណាយលើការថែទាំដែលមិនមានប្រាក់ខែ និងការងារផ្ទះ.
១១សំដៅលើផលប៉ះពាល់ខ្លាំងបំផុតទាំងប្រាំ។

## ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើជីវភាពរស់នៅ ដោយការប្រែប្រួលអាកាសធាតុ ជាពិសេសការផ្សារភ្ជាប់ទៅនឹងវិស័យកសិកម្ម ការចិញ្ចឹមសត្វ ឬសកម្មភាពបរិស្ថានផ្សេងទៀត

ការប្រែប្រួលអាកាសធាតុបន្តផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជនរាប់លាននាក់នៅកម្ពុជា។ គុណភាព និងលទ្ធភាពទទួលបានធនធានធម្មជាតិកាន់តែយ៉ាប់យ៉ឺន ទាក់ទងនឹងអាកាសធាតុ និងការប្រែប្រួលនៃលក្ខខណ្ឌឧតុនិយមបានរួមចំណែកដល់ការផ្លាស់ប្តូរការងាររបស់ប្រជាជន ជាពិសេសអ្នកដែលចូលរួមក្នុងវិស័យទេសចរណ៍ កសិកម្ម ការចិញ្ចឹមសត្វ នេសាទ ឬសកម្មភាពទាក់ទងនឹងបរិស្ថានផ្សេងទៀត។ ជាលទ្ធផលនៃការប្រែប្រួលអាកាសធាតុ ស្ត្រី ១ ភាគរយ និងបុរស ៣ ភាគរយបានផ្លាស់ប្តូរការងារ ខណៈដែលស្ត្រី ៣ ភាគរយ និង បុរស៦ភាគរយបានបាត់បង់ការងាររបស់គាត់ (រូបភាព ២៤)។ តួរលេខទាំងនេះមិនរាប់បញ្ចូលចំនួនដែលដូចបានរៀបរាប់ខាងលើទាំងនេះសបញ្ជាក់ថាគ្រោះមហន្តរាយពិតជាមានផលប៉ះពាល់លើការងាររបស់ពួកគាត់។

បុរសមានអត្រាច្រើជាងស្ត្រីដែលបាត់បង់ការងារដោយសារការប្រែប្រួលអាកាសធាតុ (ស្ត្រី ៣ភាគរយធៀបនឹងបុរស ៦ ភាគរយ)។ នៅកម្ពុជា បុរសមានការងារធ្វើច្រើនបើធៀបនឹងស្ត្រី ប៉ុន្តែស្ត្រីបានចូលរួមក្នុងការងារវិស័យក្រៅផ្លូវការមិនសមាមាត្រ (យោងទៅតាមអង្កេតកម្លាំងពលកម្ម LFS ឆ្នាំ ២០១៩ ប្រមាណ ៨៨ភាគរយនៃអ្នកធ្វើការងារក្រៅប្រព័ន្ធគឺជាស្ត្រី) ដែលងាយរងគ្រោះបាត់បង់ការងារដោយសារ កង្វះសន្តិសុខសង្គម និងអត្ថប្រយោជន៍សម្រាប់មិនមានការងារធ្វើ។ តារាងទី ៣ បង្ហាញថាប្រជាជននៅទីប្រជុំជន មានច្រើនជាងតិចតួចដែលបាត់បង់ការងារ (ច្រើនជាង ៥ភាគរយធៀបនឹងជាង ៤ភាគរយនៅតំបន់ជនបទ)។ ស្រដៀងគ្នានេះដែរ សម្រាប់យុវជនវ័យក្មេង ក៏បានបាត់បង់ការងារដោយសារការប្រែប្រួលអាកាសធាតុផងដែរ បើទោះបីជាមានភាពខុសគ្នាមានតិចតួច។ តាមការប៉ាន់ស្មាន ស្ត្រី៤ ភាគរយ និង បុរស៦ភាគរយ មានអាយុក្រោម ៣០ឆ្នាំបានបាត់បង់ការងារដោយសារការប្រែប្រួលអាកាសធាតុនេះដែរ។

### រូបទី២៤៖ សមាមាត្រប្រជាជនបានផ្លាស់ប្តូរការងារ ឬបាត់បង់ការងារ ដោយសារការប្រែប្រួលអាកាសធាតុ តាមភេទ



**តារាង៣៖ សមាមាត្រប្រជាជនដែលបាត់បង់ការងារដោយសារការប្រែប្រួលអាកាសធាតុ តាមភេទ ទីកន្លែងរស់នៅ និងអាយុ (ភាគរយ)**

| | ទីប្រជុំជន | ជនបទ | អាយុក្រោម៣០ឆ្នាំ | អាយុ៣០ឆ្នាំឡើង |
|---|---|---|---|---|
| ស្ត្រី | ៣,២ | ៣,១ | ៤ | ៣ |
| បុរស | ៦ | ៥ | ៦ | ៦ |

ប្រជាជនប្រកបរបរដាំដំណាំ ឬចិញ្ចឹមសត្វ បានជួបប្រទះនឹងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ។ ស្ត្រី ៦៦ ភាគរយ និង បុរស៦៥ ភាគរយ ដែលពាក់ព័ន្ធនឹងសកម្មភាពទាំងនេះ (មិនថាសម្រាប់ជាសាច់ប្រាក់ឬប្រាក់ចំណេញ ឬសម្រាប់គោលបំណងផ្សេងៗដូចជា សម្រាប់ប្រើប្រាស់ ការកំសាន្ត ប្រពៃណី សាសនា ឬមូលហេតុផ្សេងទៀត) មានការធ្លាក់ចុះទិន្នផលកសិកម្ម ឬចិញ្ចឹមសត្វ ដោយសារការប្រែប្រួលអាកាសធាតុក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ (រូបភាពទី ២៥)។ ការបាត់បង់នេះអាចធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ដល់ជីវភាពរបស់គាត់ ព្រោះភាគច្រើន ការដាំដុះ និងចិញ្ចឹមសត្វគឺជាប្រភពចំណូលសំខាន់បំផុតរបស់គាត់ (៣៨ ភាគរយនៃកសិករបានឱ្យដឹងថា ទិន្នផលរបស់គាត់បានធ្លាក់ចុះ)។ ការធ្លាក់ចុះនៃទិន្នផលគឺជាលទ្ធផលអាក្រក់បំផុតមួយ ដែលកើតឡើងដោយសារប្រើថ្នាំកំចាត់សត្វល្អិតច្រើន ការប្រើប្រាស់ដីគីមី ឬការចំណាយពេលច្រើនសម្រាប់សកម្មភាពនោះ មិនអាចបន្ថយឥទ្ធិពលការប្រែប្រួលអាកាសធាតុបាន។ ដូច្នេះ ប្រជាជនជាច្រើន ដែលធ្វើកសិកម្ម និងចិញ្ចឹមសត្វបានរងផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុ ទោះបីគាត់អាចចៀសផុតពីការធ្លាក់ចុះនៃទិន្នផលបានក៏ដោយ។

**រូបភាពទី ២៥៖ សមាមាត្រអ្នកប្រើប្រាស់ដី ឬចិញ្ចឹមសត្វ ដែលបានបញ្ជាក់ថា មានការធ្លាក់ចុះនៃទិន្នផលដោយសារការប្រែប្រួលអាកាសធាតុ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ បែងចែកតាមភេទ និងថា តើកសិកម្មគឺជាប្រភពចំណូលចម្បងរបស់គាត់ឬអត់ (ភាគរយ)**



## កសិករនៅតែអនុវត្តយុទ្ធសាស្ត្រផ្សេងៗដើម្បីសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ រួមទាំងការរក្សាបម្រុងទុកគ្រាប់ពូជ គួរត្រូវលើកទឹកចិត្ត

ដើម្បីកាត់បន្ថយផលប៉ះពាល់ខ្លះៗពីការប្រែប្រួលអាកាសធាតុទៅលើការដាំដុះ និងចិញ្ចឹមសត្វ កសិករបានបង្កើនការខិតខំរក្សាគ្រាប់ពូជ និងសម្ភារៈដាំដុះផ្សេងៗ ឬស្វែងរកជម្រើសផ្សេងៗ ដូចជា ប្តូរទៅដាំដំណាំដែលអាចធន់នឹងការប្រែប្រួលអាកាសធាតុ ឬផ្លាស់ទីកន្លែងការចិញ្ចឹមសត្វរបស់គាត់ (រូបភាពទី២៦)។ តំបន់ខ្លះ នៅកម្ពុជា ដែលមានការប្រែប្រួលអាកាសធាតុធ្ងន់ធ្ងរទៅលើកសិកម្ម ដូចជា ការជួបប្រទះកម្ដៅខ្លាំង ភ្លៀងធ្លាក់តិច ឬមានការបំពុលបរិស្ថាន ឬបាត់បង់ធនធានធម្មជាតិទៀត កសិករជាច្រើនត្រូវបានបង្ខំឱ្យផ្លាស់ទីសកម្មភាពកសិកម្មរបស់គាត់។ ការផ្លាស់ទីនេះ ជាទូទៅ ស្ត្រីមានខ្ពស់ជាងបុរសបន្តិច (ក្នុងចំណោមស្ត្រី មាន ៤ ភាគរយបានផ្លាស់ទីការចិញ្ចឹមសត្វ និង ២ ភាគរយបានរកដីកសិកម្មថ្មី ប្រៀបធៀបនឹងបុរស មាន ៣ភាគរយ និង ១ ភាគរយតែប៉ុណ្ណោះ)។ ដោយសារស្ត្រីភាគច្រើនមានប្រភពចំណូលតិចជាងបុរស ការរស់នៅដោយពឹងផ្អែកលើការធ្វើកសិកម្មតែមួយអាចជាហេតុធ្វើឱ្យស្ត្រីជាច្រើនត្រូវផ្លាស់ទីទៅកន្លែងថ្មី។ យុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់ផ្សេងទៀត ដូចជា ការប្តូរមុខដំណាំផ្សេងៗ ឬការរក្សាគ្រាប់ពូជ និងសម្ភារៈដាំដុះ ដើម្បីទប់ស្កាត់ភាពខ្វះខាតនាពេលអនាគត ត្រូវបានអនុវត្តស្មើគ្នារវាងស្ត្រី និងបុរស។ ការរក្សាគ្រាប់ពូជ និង សម្ភារៈដាំដុះផ្សេងទៀត គឺជាអនុវត្តន៍ធម្មតានៅកម្ពុជា ហេតុនេះវាក៏បានក្លាយជាយុទ្ធសាស្ត្រដ៏ពេញនិយមបំផុតដែលកសិករប្រើវា ដើម្បីកាត់បន្ថយផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ ដោយ ១៧ ភាគរយនៃអ្នកធ្វើកសិកម្ម និងចិញ្ចឹមសត្វបានអនុវត្តការរក្សាទុកគ្រាប់ពូជនិងដំណាំដាំដុះ។ ការអនុវត្តន៍នេះមានសារៈសំខាន់សម្រាប់ជីវភាព រួមទាំងការជ្រើសរើសគ្រាប់ពូជ ដើម្បីបង្កើតលក្ខណៈពិសេសមួយចំនួនក្នុងដំណាំដូចជាការធន់នឹងការប្រែប្រួលអាកាសធាតុ។ ទោះបីកម្ពុជាមានក្របខ័ណ្ឌច្បាប់ត្រួតពិនិត្យ និងគ្រប់គ្រងការបំលែងគ្រប់ពូជ (GMOs) ក៏ដោយ ក៏ប្រទេសជាសមាជិកអាស៊ានជាច្រើនកំពុងពង្រីកការប្រើគ្រាប់ពូជ ដើម្បីបង្កើនការការពារពីសត្វល្អិត និងបង្កើនផលផលិត។ គ្រាប់ពូជទាំងនេះភាគច្រើនមានកម្មសិទ្ធិបញ្ញាឯកជន ដែលអាចបង្កើនការពឹងផ្អែករបស់កសិករលើក្រុមហ៊ុនមួយចំនួន។ ដូច្នេះ ការរក្សា និងប្រើគ្រាប់ពូជធម្មជាតិនៅតែជាចាំបាច់ ដើម្បីការពារជីវភាពកសិករ និងចៀសវាងការពឹងផ្អែកលើគ្រាប់ពូជថ្លៃៗដែលមានសិទ្ធិបញ្ញា។

**រូបភាពទី ២៦៖ សមាមាត្រនៃអ្នកប្រើប្រាស់ដី ឬបសុសត្វ ដែលបានបំរុងទុកគ្រាប់ពូជ ផ្លាស់ប្តូរដំណាំ ឬផ្លាស់ប្តូរទីតាំង ដើម្បីដោះស្រាយផលវិបាកនៃការប្រែប្រួលអាកាសធាតុ តាមភេទ និងសកម្មភាព (ភាគរយ)**



## ស្ទើរតែមួយភាគបួននៃកសិករ បច្ចុប្បន្នបានប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងថ្នាំប្រឆាំងមេរោគបន្ថែមទៀត ដើម្បីទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ដែលរួមចំណែកបន្ថែមទៀតដល់ការរិចរិលបរិស្ថាន

ការកើនឡើងសីតុណ្ហភាព ការបាត់បង់ប្រព័ន្ធអេកូឡូស៊ី ទម្រង់ទឹកភ្លៀងមិនអាចទាយទុកជាមុនបាន និងគ្រោះថ្នាក់ជាច្រើនផ្សេងទៀតដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុធ្វើឱ្យសកម្មភាពកសិកម្មប្រឈមមុខនឹងបញ្ហា។ សម្រាប់ស្ត្រី និងបុរសដែលដាំដំណាំ ឬចិញ្ចឹមសត្វ យន្តការទប់ទល់អាចជាការបង្កើនការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ឬថ្នាំអង់ទីប៊ីយោទិចក្នុងប្រតិបត្តិការរបស់គាត់។ ទាំងនេះរួមចំណែកដល់ការបំផ្លាញបរិស្ថានបន្ថែមទៀត ជាពិសេសចាប់តាំងពីការកើនឡើងនៃសីតុណ្ហភាពរួមចំណែកដល់ការបំរែបំរួលថ្នាំសម្លាប់សត្វល្អិត អត្រាកំណើននៃបាក់តេរី និងការរីករាលដាលកាន់តែខ្លាំងនៃមីក្រូសរីរាង្គដែលធន់នឹងថ្នាំអង់ទីប៊ីយោទិច។ ជាងនេះទៅទៀត គ្រោះថ្នាក់ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដូចជាព្រឹត្តិការណ៍ភ្លៀងខ្លាំង ត្រូវបានគេដឹងថាមានផ្ទុកថ្នាំសម្លាប់សត្វល្អិតទៅក្នុងផ្លូវទឹក និងបង្កើនហានិភ័យនៃការប៉ះពាល់សម្រាប់មនុស្ស សត្វ និងប្រព័ន្ធអេកូឡូស៊ីទាំងមូល។

នៅកម្ពុជាអ្នកដាំដំណាំ ស្ត្រីប្រមាណ ២៤% និងបុរស ២៣% បានបង្កើនការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតដោយសារការប្រែប្រួលអាកាសធាតុ និងស្ត្រី ៧% និងបុរស១០% នៃអ្នកចិញ្ចឹមសត្វ បានបង្កើនការប្រើប្រាស់ថ្នាំអង់ទីប៊ីយោទិច (រូបភាព ២៧)។ ទាំងនេះគឺជានិន្នាការដ៏គួរឱ្យព្រួយបារម្ភ ដោយសារការប្រើប្រាស់សារធាតុទាំងនេះកំពុងរីករាលដាលនៅទូទាំងប្រទេស (ជាងពាក់កណ្តាលនៃកសិករដាំស្រូវ ពោត ឬដំឡូងមី ប្រើថ្នាំសម្លាប់សត្វល្អិត[១២])។ ការរិចរិលផ្នែកកសិកម្ម កំពុងបង្កបញ្ហាជាច្រើន ដោយសារថ្នាំសម្លាប់សត្វល្អិតមានកំហាប់ខ្ពស់ក្នុងគំរូដី និងទឹកនៅទូទាំងប្រទេស ដែលខ្លះបង្កហានិភ័យខ្ពស់ដល់សារពាង្គកាយក្នុងទឹកក្នុងទន្លេមេគង្គ ដែលជាប្រភពអាហារសំខាន់សម្រាប់ប្រជាជនកម្ពុជាជាច្រើននាក់។ ដូចជា ចិន ថៃ និងវៀតណាម។ ជាឧទាហរណ៍ កសិករកម្ពុជាជាច្រើនមិនបានធ្វើតាមការណែនាំស្លាកសញ្ញា ឬសម្អាតឧបករណ៍ថ្នាំសម្លាប់សត្វល្អិតឱ្យបានត្រឹមត្រូវ (សូមមើលផ្នែកទី III)។ សំណល់កសិកម្ម និងចិញ្ចឹមសត្វ កំពុងបង្កបញ្ហាធ្ងន់ធ្ងរ ដោយសារតែរកឃើញសារធាតុពុលកម្ចាត់សត្វល្អិតក្នុងដី និងទឹកនៅតាមតំបន់ផ្សេងៗ។ សារធាតុទាំងនេះ ខ្លះគំរាមកំហែងដល់សត្វទឹកក្នុងទន្លេមេគង្គ ដែលជាប្រភពអាហារសំខាន់សម្រាប់ប្រជាជនកម្ពុជា។[១៣] ផ្នែកមួយនៃបញ្ហានេះកើតឡើង ពី ការប្រើប្រាស់មិនត្រឹមត្រូវនៃសារធាតុពុល ដោយសារតែ អ្នកលក់ និងកសិករជាច្រើនមិនយល់សេចក្តីណែនាំសុវត្ថិភាព ដែលភ្ជាប់ជាមួយផលិតផលនាំចូលពីប្រទេសជិតខាងដូចជា ចិន ថៃ និងវៀតណាម។ ឧទាហរណ៍ មានកសិករជាច្រើន មិនអាន ឬមិនអនុវត្តតាមស្លាកសញ្ញា ហើយក៏ មិនលាងឧបករណ៍បាញ់ថ្នាំសារធាតុពុលអោយបានស្អាតត្រឹមត្រូវផងដែរ (សូមមើលផ្នែកទី ៣)។

១២ របាយការណ៍អង្កេត ពាក់កណ្តាលជំរឿនកសិកម្ម ឆ្នាំ២០១៩
១៣ ការត្រួតពិនិត្យសារធាតុពុលសកម្មប្រឆាំងសត្វល្អិតនៅក្នុងទឹក និងលើដីជាប់មាត់ទន្លេមេគង្គក្នុងប្រទេសកម្ពុជា

រូបទី២៧៖ សមាមាត្រអ្នកប្រើប្រាស់ជី ឬសត្វចិញ្ចឹម ដែលបានបង្កើនប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត (pesticides) ឬ ថ្នាំអង់ទីប៊ីយូទិច (antibiotics) ដោយសារការប្រែប្រួលអាកាសធាតុ តាមភេទ និងប្រភេទផលប៉ះពាល់ (ភាគរយ)




## ការប្រែប្រួលអាកាសធាតុ បណ្តាលឱ្យចំណាយកើនឡើងក្នុងការថែរក្សា និងរបរដែលពាក់ព័ន្ធនឹងបរិស្ថាន

ការប្រែប្រួលអាកាសធាតុកំពុងប៉ះពាល់ដល់បរិមាណទឹកភ្លៀង និងធ្វើឱ្យសីតុណ្ហភាពកាន់តែក្តៅ ។ សម្រាប់ស្ត្រី និងបុរសដែលជីវភាពពឹងផ្អែកលើការធ្វើកសិកម្ម ឬចិញ្ចឹមសត្វ មានផលប៉ះពាល់យ៉ាងខ្លាំង ដោយសារតែគាត់ចាំបាច់ត្រូវចំណាយពេល និងធនធានច្រើនជាងមុន ដើម្បីរក្សាទិន្នផល ។ ជាង ១៥ ភាគរយនៃអ្នកចិញ្ចឹមសត្វ បច្ចុប្បន្នបានចំណាយពេលច្រើនក្នុងការថែរក្សាសត្វ ដោយសារការប្រែប្រួលអាកាសធាតុ រួមទាំងរួមទាំងការថែទាំកន្លែងឃុំឃាំងសត្វ ដើម្បីអាចគ្រប់គ្រងសីតុណ្ហភាពបាន និងការផ្លាស់ទីសត្វទៅកន្លែងមានសុវត្ថិភាព (មើលរូបភាព២៨)។ ដូចគ្នានេះផងដែរ ប្រមាណជិត ១០ ភាគរយនៃអ្នកធ្វើកសិកម្មបានបញ្ជាក់ថា គាត់ត្រូវចំណាយពេលច្រើនជាងមុនសម្រាប់ការធ្វើកសិកម្ម ដោយសារត្រូវតែដំឡើងរបងការពារតំបន់បែបធម្មជាតិ ឬប្រព័ន្ធគ្រប់គ្រងទឹកដើម្បីគ្រប់គ្រងសីតុណ្ហភាពសំណើម និងលើកកម្ពស់សមត្ថភាពធន់នៃដំណាំ។

ការប្រែប្រួលអាកាសធាតុ ក៏កំពុងប៉ះពាល់ដល់ការតម្រូវបាន និងគុណភាពប្រភពទឹកផងដែរ ហើយសម្រាប់អ្នកដែលគ្មានទឹកស្អាតប្រើនៅផ្ទះ មានការកើនឡើងយ៉ាងខ្លាំងលើចំណាយពេលវេលាសម្រាប់ទៅយកទឹក (ជាង ១០ ភាគរយ មានការកើន បន្ថែមលើ ប្រភពទឹកដែលបំផ្លាញដោយគ្រោះមហន្តរាយ ដូចបានរៀបរាប់ក្នុងផ្នែក I ខាងលើ)។ ដូចគ្នានេះ សម្រាប់ឥន្ធនៈ និងអុស ការប្រែប្រួលអាកាសធាតុអាចធ្វើឱ្យអ្នកប្រើឥន្ធនៈស្អាត ដូចជាការប្រើអគ្គិសនី មិនអាចទិញបានដោយសារតម្លៃខ្ពស់។ ទោះបីជាការកើនឡើងនៃបន្ទុកការប្រមូលទឹក និងឥន្ធនៈត្រូវបានទទួលភារកិច្ចមិនស្មើគ្នាចំពោះបុរសនៅកម្ពុជា តែការងារដាំដំណាំ រួមទាំងការបំលែងកែច្នៃផលិតផលស្តុកទុក និងប្រើប្រាស់បានយូរ ត្រូវធ្លាក់បន្ទុកលើស្ត្រី។ ស្ត្រីក៏មានបន្ទុកការងារច្រើនទាក់ទងនឹងការគ្រប់គ្រងកាកសំណល់ដោយសារគ្រោះថ្នាក់អាកាសធាតុផងដែរ។

ការប្រែប្រួលអាកាសធាតុក៏បានបណ្តាលឱ្យចំណាយពេលវេលាកើនឡើងផងដែរ សម្រាប់ការនេសាទ ការចិញ្ចឹម និងដលផល បុរសមានបន្ទុកការងារនេះច្រើនជាងស្ត្រី ដោយសារតែបុរសធ្វើការនេសាទសម្រាប់រកចំណូលជាញឹក

ញាប់ជាងស្ត្រី។ ស្ត្រីជាច្រើនបានចូលរួមក្នុងវិស័យនេះ ត្រូវទទួលខុសត្រូវលើការកែច្នៃ និងរៀបចំដំណើរការមុន និងបន្ទាប់ពីការប្រមូលផល។ ក្នុងចំណោមស្ត្រីទាំងនោះ ប្រហែល ៤ ភាគរយបានបញ្ជាក់ថា គាត់ចំណាយពេលវេលាបន្ថែមសម្រាប់ការកែច្នៃត្រី ដោយសារការប្រែប្រួលអាកាសធាតុ។ ការកើនឡើងនេះអាចមានទាក់ទងនឹងការញែកត្រី ចេញពីសត្វសមុទ្រផ្សេងៗដែលមិនចង់បាន ការបំបែកចេញពីជីវរុក្ខជាតិ ឬសារធាតុផ្សេងៗដែលកើនឡើងបន្តិចបន្តួច ដោយសារការប្រែប្រួលសីតុណ្ហភាព និងអាស៊ីដនៃទឹកសមុទ្រ ឬត្រូវកែច្នៃបន្ថែម ដូចជា បកសំបក សម្អាត កាត់បំបែក និងសម្ងួត ដោយសារការប្រែប្រួលបរិស្ថានដូចជា អាស៊ីដក្នុងសមុទ្រ ភ្លៀងអាស៊ីដ និងភាពលើសជាតិជីក្នុងទឹក ដែលប៉ះពាល់ដល់សំបក និងសុខភាពសត្វ និងសត្វសមុទ្រផ្សេងៗ។ ដោយសារការប្រែប្រួលអាកាសធាតុបណ្តាលឱ្យមានអាកាសធាតុមិនទៀងទាត់ បាត់បង់ជីវចម្រុះ ជំងឺ និងកម្រនូវធនធាន គ្មានជម្រើសផ្សេងក្នុងការរក្សាទិន្នផល ត្រូវចំណាយពេលវេលាបន្ថែមសម្រាប់បំពេញភារកិច្ចទាំងនេះ។ គ្រោះមហន្តរាយអាកាសធាតុខុសៗគ្នាក៏អាចបង្កឱ្យមានបន្ទុកពេលវេលាផ្សេងៗគ្នា។ ឧទាហរណ៍ ការផ្លាស់ប្តូរសីតុណ្ហភាពគឺជាឧប្បត្តិហេតុដែល បណ្តាលឱ្យមានការកើនឡើងយ៉ាងច្រើនបំផុតនៃពេលវេលា សម្រាប់ការកែច្នៃអាហារ និងការធ្វើកសិកម្ម។

**រូបទី២៨៖ សមាមាត្រនៃប្រជាជនបានចំណាយពេលវេលាកើនឡើងលើការផលិតទំនិញបរិស្ថាន ដោយសារការប្រែប្រួលអាកាសធាតុ តាមភេទ និងប្រភេទ (ជាភាគរយ**




ចំណាំ៖ មិនមានភាពខុសគ្នារវាងស្ត្រី និងបុរស ក្នុងន័យស្ថិតិនៅ α=0,0៥ សម្រាប់ប្រភេទ "ការប្រមូលធនធានធម្មជាតិ"

## ការកើនឡើងបទឧក្រិដ្ឋកម្ម និងអំពើហិង្សា ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ នៅកម្ពុជា

សម្ពាធសេដ្ឋកិច្ចដែលបានរៀបរាប់ខាងលើ រួមជាមួយនឹងការខ្វះខាតធនធនធានបរិស្ថានដែលកើតឡើងកាន់តែខ្លាំង ដោយសារការប្រែប្រួលអាកាសធាតុ អាចនឹងធ្វើឱ្យមានវិសមភាព និងអារម្មណ៍នៃការថប់បារម្ភ និងភាពតានតឹងកាន់តែខ្លាំងឡើង ដែលជាកត្តាជំរុញនៃបទឧក្រិដ្ឋកម្ម និងអំពើហិង្សា។ នៅពេលសួរថា តើគាត់បានកត់សម្គាល់ឃើញបទឧក្រិដ្ឋកម្មកាន់តែអាក្រក់នៅក្នុងតំបន់ដែលគាត់រស់នៅ ឬកន្លែងធ្វើការដែរឬទេ ២ ភាគរយនៃប្រជាជនកម្ពុជាបានកត់សម្គាល់ថា ឧក្រិដ្ឋកម្មបានកើនឡើង និងមានភាគរយដូចគ្នា បានឮថាមានអ្នកជួបប្រទះអំពើហិង្សាកាន់តែច្រើនដោយសារបម្រែបម្រួលអាកាសធាតុ (រូបភាព ២៩)។ការវាស់វែងអត្រាបទឧក្រិដ្ឋ និងអំពើហិង្សាដោយភាពត្រឹមត្រូវ តម្រូវអោយមានការអង្កេតជាពិសេសសម្រាប់ទទួលបានចម្លើយដោយស្មោះត្រង់លើប្រធានបទសើបមួយនេះ។ សំណួរទូទៅនៅក្នុងការអង្កេតបម្រើគោលបំណងច្រើនតែងនាំឱ្យមានការប៉ាន់ប្រមាណអត្រាទាបជាងជាក់ស្តែង ដូច្នេះភាគរយទាំងនេះមិនគួរត្រូវគិតថាជាអត្រាបទឧក្រិដ្ឋកម្ម និងអំពើហិង្សាទេ។ ទោះជាយ៉ាងណា វាក៏បង្ហាញពីការកើនឡើងនៃអំពើឧក្រិដ្ឋ និងអំពើហិង្សាដោយសារការប្រែប្រួលអាកាសធាតុ ដែលជាប្រធានបទមួយដែលត្រូវការការស្រាវជ្រាវបន្ថែម។

**រូបទី២៩៖ សមាមាត្រប្រជាជនដែលឃើញថា មានការកើនឡើងនៃអំពើឧក្រិដ្ឋ និងអំពើហិង្សា ដោយសារការប្រែប្រួលអាកាសធាតុ តាមភេទ (ភាគរយ)**




សម្គាល់៖ មិនមានភាពខុសគ្នារវាងស្ត្រី និងបុរសក្នុងន័យស្ថិតិសំខាន់នៅកម្រិត α = 0.05 ទេ។

## ផ្នែកទី៣៖ ការបាត់បង់ធនធានធម្មជាតិ ជីវចំរុះ និងជីវភាពរស់នៅដែលពាក់ព័ន្ធនឹងបរិស្ថាន

### ប្រជាជនភាគច្រើននៅកម្ពុជា បានពឹងផ្អែកលើធនធានធម្មជាតិ បង្ហាញថាមានការបំផ្លាញបរិស្ថាន អាចមានផលប៉ះពាល់ធ្ងន់ធ្ងរ

ការពឹងផ្អែកយ៉ាងខ្លាំងលើធនធានបរិស្ថានធ្វើឱ្យប្រជាជននៅកម្ពុជាមានភាពងាយរងគ្រោះចំពោះការ ប្រែប្រួលអាកាសធាតុនិងការបំផ្លាញបរិស្ថាន។ តាមការប៉ាន់ស្មាន ៨៦ ភាគរយនៃប្រជាជនកម្ពុជាពឹងផ្អែកលើសកម្មភាពបរិស្ថានយ៉ាងតិចមួយសម្រាប់ជីវភាពរស់នៅរបស់គាត់ ដែលភាគច្រើនទៅលើសកម្មភាពកសិកម្មប្រមាណជា ៨០ ភាគរយ (រូបទី៣០)។ ស្ត្រីម្នាក់ក្នុងចំណោមប្រាំនាក់ពឹងផ្អែកលើការរកអុស ឈើ ឬឥន្ទនៈ សម្រាប់ជីវភាពរស់នៅដែលជាសកម្មភាពទីពីររបស់គាត់។ ទន្លេមេគង្គ និងបឹងទន្លេសាប មានតួនាទីសំខាន់ក្នុងប្រព័ន្ធអេកូឡូស៊ី ដែលជាអាងស្តុកត្រីសម្រាប់ការនេសាទដ៏ធំនៅកម្ពុជា។ ទោះបីជាបុរសមានភាគរយខ្ពស់ជាងស្ត្រីចំពោះការនេសាទ តែស្ត្រីមានភាគរយខ្ពស់ជាងបុរសលើផ្នែកកែច្នៃត្រី និងប្រតិបត្តិការនៅទីផ្សារ។

ប្រជាជនកម្ពុជាជាច្រើនមានប្រភពចំណូលច្រើនបែប ប៉ុន្តែសកម្មភាពពាក់ព័ន្ធនឹងបរិស្ថាននៅតែជាប្រភពចំណូលមួយយ៉ាងសំខាន់ មាន២៤ ភាគរយសម្រាប់ស្ត្រី និងបុរស ២៨ ភាគរយ (រូបភាពទី ៣១)។ ការពឹងផ្អែកនេះបង្កើនភាពងាយរងគ្រោះ និងបណ្តាលឱ្យមានផលប៉ះពាល់មួយចំនួនៗដែលបានបង្ហាញនៅក្នុងផ្នែកមុនៗ ដូចជាចំណាយពេលវេលាច្រើនជាងមុនទៅលើសកម្មភាពកសិកម្ម និងការប៉ះពាល់ដល់សុខភាពផ្លូវចិត្តនៅពេលមានការបាត់បង់ឬ ខូចខាត។ ការពឹងផ្អែកយ៉ាងខ្លាំងលើធនធានធម្មជាតិបង្ហាញពីសារៈសំខាន់នៃការអភិរក្សធនធានធម្មជាតិ ដើម្បីធានាឱ្យបាននូវសុខុមាលភាពរបស់ប្រជាជន និងប្រព័ន្ធអេកូឡូស៊ី។

## រូបភាពទី ៣០: សមាមាត្រ ប្រជាជនដែលពឹងផ្អែកលើធនធានធម្មជាតិសម្រាប់ជីវភាពរស់នៅ បែងចែងតាមភេទ និងប្រភេទ (ជាភាគរយ)




សម្គាល់៖ មិនមានភាពខុសគ្នារវាងស្ត្រី និងបុរស ក្នុងន័យស្ថិតិនៅ α=0,0៥ សម្រាប់ប្រភេទ "វារីវប្បកម្ម" និង "ប្រមូលផលផលិតផលរុក្ខជាតិព្រៃដែលមិនអាចបរិភោគបាន"

## រូបភាពទី៣១៖ សមាមាត្រ ប្រជាជនដែលមានប្រភពចំណូលចម្បងទាក់ទងនឹងបរិស្ថាន តាមភេទ (ភាគរយ)




ភាគច្រើនអ្នកប្រកបរបរពឹងផ្អែកលើធនធានធម្មជាតិ នៅតែអាស្រ័យលើផ្នែកការងារតូចៗ។ ឧទាហរណ៍ ៩៩% នៃអ្នកប្រមូលផលពីព្រៃ សម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ និង ៨៨% នៃអ្នកនេសាទក៏ធ្វើការនេសាទខ្នាតតូច សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន (រូបទី៣២)។ មានការចូលរួមតិចតួច ក្នុងការងារខ្នាតធំដែលពឹងផ្អែកលើធនធានធម្មជាតិ វាជាសញ្ញាវិជ្ជមានមួយសម្រាប់ការអភិរក្សនិងគ្រប់គ្រងធនធានបរិស្ថាន ប៉ុន្តែវាក៏បញ្ជាក់បន្ថែមផងដែរថា មានភាពងាយរងគ្រោះខ្ពស់ចំពោះបរិស្ថាន បន្ថែមពីភាពចាំបាច់នៃការពារធនធានព្រៃឈើ និងប្រព័ន្ធអេកូប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងទឹកសាប ដើម្បីធានាបរិស្ថានប្រកបដោយចីរភាព។ ករណីវិស័យកសិកម្ម ជាទូទៅផ្នែកកសិឧស្សាហកម្មបានចូលរួមចំណែកខ្ពស់។ មានតែ ៦៣ភាគរយនៃស្ត្រី និង បុរស៥៩ភាគរយប៉ុណ្ណោះបានធ្វើកសិកម្មសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។ ការពឹងផ្អែកលើផ្នែកកសិឧស្សាហកម្ម កំពុងបង្កការគំរាមកំហែងដល់ប្រព័ន្ធអេកូឡូស៊ីនៅកម្ពុជា ដោយសារការប្រើប្រាស់ធនធានលើសកម្រិតនិងបំផ្លាញបរិស្ថានយ៉ាងឆាប់រហ័ស។ ការប្រើប្រាស់សារធាតុពុលសម្លាប់សត្វល្អិត និង ជីកសិកម្ម ក៏ជាធាតុធ្វើឱ្យខូចគុណភាពដី បំពុលទឹក និងប៉ះពាល់ដល់សុខភាពមនុស្ស ព្រមទាំងបរិស្ថានផងដែរ (មើលផ្នែកទី IV)។

## រូបភាព ៣២៖ សមាមាត្រប្រជាកសិករជាអ្នកដាំដុះ នេសាទ បរបាញ់ និងអ្នកប្រមូលផលព្រៃឈើ សម្រាប់ជីវភាពប្រចាំថ្ងៃ បែងចែកតាមភេទ (ភាគរយ)



## ប្រមាណ៦៤ ភាគរយនៃប្រជាជន ដែលកាន់កាប់ដីផ្ទាល់ខ្លួនប្រើសម្រាប់ធ្វើកសិកម្មនេះបង្ក ឱ្យមានភាពងាយរងគ្រោះ និងពិបាកចូលរួមក្នុងការអភិរក្សធនធានធម្មជាតិ

នៅកម្ពុជា ប្រជាកសិករមានតិចជាងពីរនាក់ក្នុងចំណោមបីនាក់ មានសិទ្ធិកាន់កាប់ដីផ្ទាល់ខ្លួនប្រើប្រាស់សម្រាប់ធ្វើកសិកម្ម (រូបភាព៣៣)។ នេះមានន័យថា មួយភាគបីនៃប្រជាជនជាកសិករ អាចបាត់បង់ឱកាសប្រើប្រាស់ដីសម្រាប់ជីវភាពគាត់ ។ បើគ្មានប័ណ្ណកម្មសិទ្ធិដីធ្លី ឬសិទ្ធិកាន់កាប់ទេ នោះឱកាសក្នុងការទទួលបានប្រាក់កម្ចីមានកម្រិត ដោយសារដីអាចប្រើជាវត្ថុបញ្ចាំ និងទម្រង់ហិរញ្ញប្បទានផ្សេងទៀត ដើម្បីទប់ទល់នឹងគ្រោះមហន្តរាយ និងការខាតបង់ទាក់ទងនឹងអាកាសធាតុ។ វាងយេនឌ័រ  ចំពោះកម្មសិទ្ធិដីធ្លីមិនមានភាពខុសគ្នាខ្លាំងសម្រាប់ជនជាតិខ្មែរនោះទេ  តែមានខ្ពស់ចំពោះជនជាតិដទៃទៀតនៅកម្ពុជា។ ក្នុងចំណោមអ្នកមិនមានអត្តសញ្ញាណជាខ្មែរ បុរសមានសិទ្ធិកាន់កាប់ដី ឬមានសិទ្ធិកាន់កាប់ដីកសិកម្មដែលខ្លួនប្រើប្រាស់ច្រើនជាងស្ត្រី (រូបភាពទី៣៤)។

ឧបសគ្គមួយចំនួនដែលអាចរួមចំណែកដល់ការកាន់កាប់ដីធ្លី មានកំណត់របស់ស្ត្រីមិនមែនជាខ្មែរបើធៀបនឹងបុរស រួមមានស្ត្រីមានលទ្ធភាពទទួលបានហិរញ្ញវត្ថុតិចជាង បទដ្ឋានសង្គមដែលកំណត់ថាការចុះបញ្ជីដីធ្លី ឬការទទួលមរតកធ្វើឡើងក្រោមសមាជិកគ្រួសារបុរស ក៏ដូចជាដែនកំណត់ដែលទាក់ទងនឹងកម្មសិទ្ធិលើដីសហគមន៍ ឬសិទ្ធិទទួលបានដីមរតកជាពិសេសសម្រាប់ស្ត្រីជនជាតិដើមភាគតិចនៅភាគខាងជើងនៃប្រទេស ខេត្តរតនគិរី និងមណ្ឌលគិរី ស្ត្រីមានអត្រាទាបបំផុតដែលកាន់កាប់សិទ្ធិផ្ទាល់ខ្លួន ។

បទដ្ឋានសង្គម និងកម្រិតភាពជាម្ចាស់នៃដីកសិកម្ម ប្រែក្លាយទៅជាឧបសគ្គកាន់តែខ្ពស់សម្រាប់ការសម្រេចចិត្តរបស់ស្ត្រីទាក់ទងនឹងការគ្រប់គ្រងដីធ្លី ដោយសារស្ត្រីមានអត្រាតិចជាងបុរសក្នុងការប្រើថ្នាំសម្លាប់សត្វល្អិត និងសារធាតុគ្រោះថ្នាក់ផ្សេងទៀត វាអាចបង្កគ្រោះថ្នាក់ដល់ការអភិរក្សបរិស្ថាន។ ស្ត្រីជនជាតិខ្មែរ ប្រមាណ ៩៦ភាគរយ ជាម្ចាស់ដីកសិកម្មផ្ទាល់ខ្លួន បានធ្វើការសម្រេចចិត្តទាក់ទងនឹងការទិញកសិកម្ម និងកសិផល បើធៀបនឹងបុរស ៩៧ភាគរយ (រូបភាព៣៥) ។ គម្លាតយេនឌ័រ បង្ហាញកាន់តែច្បាស់ក្នុងចំណោមអ្នកដែលមិនមានកម្មសិទ្ធិដីធ្លី ដែលស្ត្រីមិនមែនជនជាតិខ្មែរ ៩៤ ភាគរយ និងបុរសមិនមែនខ្មែរ ៨៥ ភាគរយអាចធ្វើការសម្រេចចិត្តដោយខ្លួនឯងបាន។ ការសម្រេចចិត្តលើការគ្រប់គ្រងដីធ្លីលើដីរបស់ខ្លួន បានរួមចំណែកដល់ការពង្រឹងការអនុវត្តការអភិរក្ស។ នៅកម្ពុជាម្ចាស់កម្មសិទ្ធិដីផ្ទាល់ខ្លួន មានអត្រាច្រើនជាង ដែលមិនមែនជាម្ចាស់ដីដើម្បីធ្វើការសម្រេចចិត្តដោយខ្លួនឯងពីរបៀបគ្រប់គ្រងដីដែលប្រើប្រាស់ រួមទាំងថាតើពួកគេប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ជី ប្រព័ន្ធធារាសាស្ត្រ ឬដំណោះស្រាយដីដែលបានអនុវត្ត។ ទោះជាយ៉ាងណាក៏ដោយ ម្ចាស់កម្មសិទ្ធិដីជាស្ត្រី ជាទូទៅមានតិចជាងម្ចាស់ដីជាបុរសក្នុងការសម្រេចចិត្តដោយខ្លួនឯង។ ភាពខុសគ្នានេះក៏មានផងដែររវាងប្រជាជនខ្មែរ និងប្រជាជនមិនមែនខ្មែរ។ ប្រជាពលរដ្ឋដែលមិនមែនជាជនជាតិខ្មែរ ដែលមិនមានប័ណ្ណកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់លើដីធ្លី គឺជាក្រុមដែលមានសិទ្ធិតិចតួចបំផុតដែលអាចធ្វើការសម្រេចចិត្តដោយខ្លួនឯងពីដីដែលគាត់ប្រើប្រាស់។

## រូបភាពទី ៣៣៖ សមាមាត្រ ប្រជាជនធ្វើកសិកម្មសរុបដែលមានប័ណ្ណកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់លើដីកសិកម្ម បែងចែកតាមភេទ




សម្គាល់៖ មិនមានភាពខុសគ្នារវាងស្ត្រី និងបុរសក្នុងន័យស្ថិតិនៅ α=0,0៥ សម្រាប់តំបន់ទីប្រជុំជន

## រូបភាពទី ៣៤៖ សមាមាត្រប្រជាជនធ្វើកសិកម្មសរុបដែលមានប័ណ្ណកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់លើដីកសិកម្ម បែងចែក តាមភេទ និងជនជាតិ (ភាគរយ)




សម្គាល់៖ គ្មានបុគ្គលណាម្នាក់ដែលបានយកអង្កេត នេះ បានកត់សម្គាល់ថាពួកគេមានជនជាតិចិន

## រូបភាពទី ៣៥៖ សមាមាត្រ ប្រជាជនដែលជាធម្មតាសម្រេចចិត្តតែម្នាក់ឯង ឬរួមគ្នាទាក់ទងនឹងការទិញ និងលក់ផលិតផលកសិកម្ម និងសត្វចិញ្ចឹម បែងចែកតាមភេទ



## កសិករជាងពាក់កណ្តាលបានកត់សម្គាល់ឃើញថាមានការកើនឡើងខូចគុណភាពដី និងការខ្វះទឹក

ការខូចគុណភាពដីត្រូវបានផ្សារភ្ជាប់ជាមួយនឹងការប្រែប្រួលអាកាសធាតុ ដូចជាការបំពុល និងការបាត់បង់ជីវៈចម្រុះ។ កសិករនៅកម្ពុជា បានសម្គាល់ឃើញថាកើតមានកាន់តែខ្លាំងឡើងការខូចគុណភាពដីបន្តិចម្តងៗ សម្រាប់ដីកសិកម្ម និងការចិញ្ចឹមសត្វ (៥៥ ភាគរយ)។ ការកត់សម្គាល់សំខាន់ៗ នៃការខូចគុណភាពដីរួមមានការថយចុះនៃជីជាតិ ការប្រែប្រួលជីអាស៊ីត ភាពងាយរងគ្រោះនៃសំណឹកដី ការកើនឡើងនិងបង្កជាសត្វល្អិត ការបាត់បង់សារធាតុសរីរាង្គ និងការបាត់បង់ជីវចម្រុះទាំងមូល។ ទាំងនេះអាចជះឥទ្ធិពលយ៉ាងខ្លាំងទៅលើទិន្នផលកសិកម្ម បសុសត្វ ព្រមទាំងសុខភាព គុណភាពនៃផលិតផលកសិកម្ម និងបសុសត្វ។ បុរសនៅកម្ពុជាមានច្រើនជាងស្ត្រីបានធ្វើការងារកសិកម្មធំៗ បានប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងជីគីមី (ស្ត្រី ៧០ ភាគរយ បើធៀបនឹងបុរស ៧២ ភាគរយ) ពួកគាត់បានកត់សម្គាល់ឃើញថាមានខូចគុណភាពដីច្រើនផងដែរ (ស្ត្រី ៦៥ ភាគរយ និងបុរស ៦៦ ភាគរយបានកត់សម្គាល់ឃើញ)។ សរុបមក កសិករដែលប្រើប្រាស់សារធាតុទាំងនេះបានកត់សម្គាល់ឃើញថា មានការខូចគុណភាពដីច្រើនជាងកសិករដែលមិនបានប្រើប្រាស់ ដោយបង្ហាញពីផលប៉ះពាល់នៃការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងជីកសិកម្មនៅលើដី និងប្រព័ន្ធអេកូឡូស៊ីនៅក្បែរៗនោះ (រូបភាព ៣៦)។

កសិករជាច្រើនបានកត់សម្គាល់ឃើញថា មានការខ្វះខាតទឹកសម្រាប់ស្រោចស្រព ដោយសារការប្រែប្រួលអាកាសធាតុ (ស្ត្រី ៣៤ភាគរយ និង បុរស ៣៧ភាគរយ)។ នៅកម្ពុជា ទឹកសាបលើដី និងទឹកភ្លៀងគឺជាប្រភពទឹកចម្បងសម្រាប់ស្រោចស្រពដីដាំដុះ (រូបភាពទី៣៧)។ កសិករស្ត្រីដែលប្រើប្រព័ន្ធស្រោចស្រព បានកត់សម្គាល់ឃើញថាភាគច្រើន មានការខ្វះខាតទឹក ការបំពុលទឹក និងការប្រើប្រាស់លើសកម្រិតបានធ្វើឱ្យមានការខ្វះខាតទឹកនៅកម្ពុជា។ ប្រមាណជាពីរ ក្នុងចំណោម ប្រាំនាក់ បានកត់សម្គាល់ឃើញថាមានការខ្វះខាតទឹកភ្លៀងសម្រាប់ស្រោចស្រពផងដែរ (រូបភាព ៣៨)។ ប្រជាពលរដ្ឋ ៤១ភាគរយ អាស្រ័យលើទឹកភ្លៀងសម្រាប់ស្រោចស្រព គាត់ត្រូវបង្កើនការប្រមូល និងរក្សាទុកទឹកភ្លៀង ដើម្បីរក្សាកម្រិតស្រោចស្រពអោយមានប្រសិទ្ធភាព ។

### រូបភាពទី ៣៦៖ សមាមាត្រប្រជាជនបានប្រើប្រាស់ដីសម្រាប់ធ្វើកសិកម្ម ឬចិញ្ចឹមសត្វ ដែលប្រើថ្នាំពុលសម្លាប់សត្វល្អិត ឬជីគីមី បែងចែកតាមការយល់ដឹងអំពីការការខូចគុណភាពដី និងតាមភេទ (ភាគរយ)




សម្គាល់៖ គ្មានភាពខុសគ្នារវាងស្ត្រី និងបុរសក្នុង ន័យស្ថិតិសំខាន់នៅកម្រិតជឿជាក់ α = 0.0៥ សម្រាប់ប្រភេទ "ការប្រើប្រាស់ជី" និង "ការប្រើប្រាស់សារធាតុពុលសកម្មប្រឆាំងសត្វល្អិត" ក្នុងករណីរបស់មនុស្សដែលបានរាយការណ៍ដីខូចគុណភាព។

### រូបភាពទី ៣៧៖ សមាមាត្រប្រជាជនបានប្រើប្រាស់ដីសម្រាប់កសិកម្ម ឬចិញ្ចឹមសត្វ ដែលប្រើប្រាស់ទឹកសម្រាប់ស្រោចស្រព បែងចែកតាមភេទ និងប្រភពទឹក (ភាគរយ)




សម្គាល់៖ គ្មានទិន្នន័យសម្រាប់ស្ត្រី និងបុរសដែលប្រើទឹកសំណល់ និងទឹកចេញពីផ្ទះបាយ សម្រាប់ស្រោចទឹកនៃដំណាំទេ។ គ្មានភាពខុសគ្នារវាងស្ត្រី និងបុរសក្នុងន័យស្ថិតិសំខាន់នៅកម្រិតជឿជាក់ α = 0.0៥ សម្រាប់ប្រភេទ "ផ្សេងទៀត"។

រូបភាពទី ៣៨៖ សមាមាត្រប្រជាជនដែលបានអះអាងថា មានការធ្លាក់ចុះនៃប្រភេទទឹកសម្រាប់ស្រោចស្រព បែងចែកតាមភេទ និងប្រភពទឹក (ភាគរយ)




សម្គាល់៖ ប្រភេទទឹកសំណល់ និងទឹកកាកសំណល់ចេញពីផ្ទះបាយមិនត្រូវបានបង្ហាញទេព្រោះប្រភពទឹកទាំងនេះមិនត្រូវបានប្រើប្រាស់ជាទូទៅនៅក្នុងប្រទេសកម្ពុជា។

## ស្ត្រីងាយរងគ្រោះចំពោះការបាត់បង់ព្រៃឈើ ព្រៃធម្មជាតិ និងដីព្រៃដែលមិនទាន់មានការអភិវឌ្ឍ

តំបន់ព្រៃឈើ ដូចជា ព្រៃធម្មជាតិ ព្រៃវាលស្មៅធម្មជាតិ ព្រៃកោងកាង ឬដីព្រៃប្រភេទផ្សេងៗ គឺមានសារៈសំខាន់ក្នុងការអភិរក្សជីវចម្រុះ។ តំបន់ព្រៃធម្មជាតិរួមមាន ប្រភេទជីវចម្រុះ ដូចជា ដើមឈើ រុក្ខជាតិ បក្សី សត្វស្លាប និងថនិកសត្វផ្សេងៗ តំបន់ព្រៃទាំងនេះ គឺជាប្រភពចំបងនៃអាហារ ដើមឈើ អុស និងសម្ភារៈសម្រាប់សាងសង់។

ព្រៃឈើ វាលស្មៅធម្មជាតិ ដីព្រៃ និងព្រៃកោងកាងក៏ផ្តល់តួនាទីយ៉ាងសំខាន់ ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងរួមចំណែករក្សាលំនឹងប្រព័ន្ធអេកូឡូស៊ី។ នៅកម្ពុជា បុរសមានការចូលរួមក្នុងសកម្មភាពទាក់ទងនឹងព្រៃឈើ ប្រើប្រាស់ព្រៃឈើច្រើនជាងស្ត្រី (ស្ត្រី ២ ភាគរយបើធៀបនឹងបុរស ៤ ភាគរយ)។ អ្នកប្រកបរបរបរបាញ់សត្វ ឬប្រមូលផលពីព្រៃឈើគឺពឹងផ្អែកយ៉ាងខ្លាំងលើព្រៃឈើធម្មជាតិ (ស្ត្រីមាន១១ភាគរយ និងបុរស៨ ភាគរយ ដែលអនុវត្តការបរបាញ់សត្វ ឬប្រមូលផលពីព្រៃឈើ ព្រៃធម្មជាតិធម្មជាតិ) (មើលរូបភាព៣៩)។ ដោយសារស្ត្រីជាទូទៅមានប្រភពចំណូលតិចជាងបុរស ការធ្លាក់ចុះព្រៃឈើឬជីវចម្រុះ អាចមានឥទ្ធិពលលើស្ត្រី ខ្លាំងជាងបុរស។ ឧទាហរណ៍ ស្ទើរតែពាក់កណ្តាលនៃស្ត្រីដែលប្រកបរបរចិញ្ចឹមសត្វ ដោយពឹងផ្អែកលើព្រៃធម្មជាតិសម្រាប់ចំណូលចម្បងរបស់គាត់។ ដូច្នេះស្ត្រីទាំងនេះគឺងាយរងគ្រោះខ្លាំងចំពោះការបាត់បង់ព្រៃធម្មជាតិ។

## រូបភាពទី ៣៩៖ សមាមាត្រប្រជាជនដែលប្រកបរបរ កាប់ឈើ បរបាញ់សត្វ ឬចិញ្ចឹមសត្វ ដែលប្រើប្រាស់ព្រៃធម្មជាតិ ឬវាលស្មៅធម្មជាតិ បែងចែកតាមភេទ (ភាគរយ)




*សម្គាល់៖គ្មានភាពខុសគ្នារវាងស្ត្រីនិងបុរសក្នុងន័យស្ថិតិនៅកម្រិតជឿជាក់α=0.០៥"ការរកឈើអុសឬឥន្ធនៈពីរុក្ខជាតិព្រៃផ្សេងទៀត"។ជីវភាពរស់នៅ (Livelihoods) មានន័យថា សកម្មភាពសេដ្ឋកិច្ច សកម្មភាពជីវភាពផ្ទាល់ខ្លួន ឬសកម្មភាពផ្សេងទៀត ដូចជាសម្រាប់កម្សាន្ត ប្រពៃណី សាសនា ឬគោលបំណងផ្សេងៗ។ការអង្កេតនេះមិនបានប្រមូលព័ត៌មានអំពីសកម្មភាពណាខ្លះដែលបានអនុវត្តនៅក្នុងព្រៃព្រៃទេបើប្រៀបធៀបនឹងព្រៃដែលមិនមែនជាព្រៃទេ។ដូច្នេះគ្រោងក្រាហ្វនៃទិន្នន័យបង្ហាញអំពីសមាមាត្រនៃមនុស្សដែលអនុវត្តសកម្មភាពទាំងនេះ និងក្នុងនោះ មានអ្នកដែលពឹងផ្អែកលើព្រៃព្រៃយ៉ាងហោចណាស់សម្រាប់សកម្មភាពមួយក្នុងចំណោម ៖ ការប្រមូលអាហារ ឈើ បាញ់សត្វ ឬចិញ្ចឹមសត្វក្នុងព្រៃ។*

## ការព្រួយបារម្ភ អំពីស្ថានភាពកើនឡើងនៃការបំផ្លិចបំផ្លាញព្រៃឈើ ដែលភាគច្រើនស្ត្រីជាអ្នកទទួលរងផលប៉ះពាល់

បច្ចុប្បន្ននេះ ដោយសារការប្រែប្រួលនៃការប្រើប្រាស់ដី និងបំរែបំរួលអាកាសអាតុ បណ្ដាលឱ្យ ទំហំ និងសមាសភាពតំបន់ព្រៃឈើមានការផ្លាស់ប្ដូរទូទាំងសាកល។ តំបន់ព្រៃឈើសរុប កំពុងមានការធ្លាក់ចុះជាបន្តបន្ទាប់ (នៅកម្ពុជាមានការបាត់បង់ដីព្រៃជាង ៨០០,០០០ ហិកតា ពីឆ្នាំ ២០១៥ ដល់ ២០២០[១៤]) បន្ទាប់ពីដីព្រៃត្រូវបានអភិវឌ្ឍផ្នែកខ្លះ ឬទាំងស្រុង ចំនួនប្រភេទសត្វ និងរុក្ខជាតិដែលរស់នៅក្នុងព្រៃក៏កំពុងធ្លាក់ចុះយ៉ាងឆាប់រហ័ស ទាំងនេះបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ និងសកម្មភាពរបស់មនុស្ស មានឥទ្ធិពលយ៉ាងខ្លាំងដល់ផលិតភាពនៃប្រព័ន្ធអេកូឡូស៊ី មានការកត់សម្គាល់ឃើញថាស្ត្រីមានផលប៉ះពាល់ច្រើនជាងបុរស ព្រោះស្ត្រីគាត់ពឹងផ្អែកលើព្រៃធម្មជាតិច្រើនសម្រាប់ប្រកពចំណូលរបស់គាត់។ មានស្ត្រីច្រើនជាងបីនាក់ក្នុងចំណោមប្រាំនាក់ បានកត់សម្គាល់ឃើញមានការបាត់បង់តំបន់ព្រៃឈើដែលគាត់អាស្រ័យផល (រូបភាព៤០)។ ការធ្លាក់ចុះនៃផ្ទៃដីព្រៃឈើសរុបគេសង្កេតឃើញមានទំនាក់ទំនងខ្លាំងជាមួយនឹងការផ្លាស់ប្ដូរពីដីព្រៃទៅជាដីសម្រាប់កសិកម្ម ឬការចិញ្ចឹមសត្វចំណែកឯ ការបាត់បង់ដីវចម្រុះ ដែលជារឿយៗពាក់ព័ន្ធនឹងការប្រើសារធាតុពុលនិងថ្នាំសម្លាប់សត្វល្អិត ការគ្រប់គ្រងព្រៃមិនមានប្រសិទ្ធភាព កំណើននគរូបនីយកម្ម និងភាពរាំងស្ងួត (រូបភាព៤១)។

[១៤] សូមមើលក្នុងមូលដ្ឋានទិន្នន័យអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) សកល។

រូបភាព ៤០៖ ភាគរយ អ្នកអាស្រ័យផលលើព្រៃឈើ បានសង្កេតឃើញមានការបាត់បង់តំបន់ព្រៃឈើ រួមទាំងការធ្លាក់ចុះនៃផ្ទៃដីសរុប និងការបាត់បង់ជីវចម្រុះ បែងចែកតាមភេទ (ភាគរយ)




រូបភាព ៤១៖ ភាគរយអ្នកអាស្រ័យផលលើព្រៃឈើ ដែលបានសង្កេតឃើញមានការបាត់បង់តំបន់ព្រៃឈើ បែងចែកតាមភេទ និងប្រភេទការបាត់បង់ (ភាគរយ)



## ការធ្លាក់ចុះបរិមាណត្រី ត្រូវបានកត់សម្គាល់ដោយប្រជានេសាទ សម្រាប់ប្រជានេសាទជាស្ត្រីមានបញ្ហាប្រឈម ធាបជាងបុរស

ស្ត្រីម្នាក់ក្នុងចំណោមប្រាំនាក់ (ប្រហែល ២០ភាគរយ) បានចូលរួមក្នុងការនេសាទ ឬប្រមូលផលសមុទ្រ បានជួបប្រទះនឹងការថយចុះនៃផលនេសាទ រយៈពេល ១០ឆ្នាំចុងក្រោយ អត្រានេះ ទាបជាងបន្តិចសម្រាប់បុរស (១៨ ភាគរយ) ប៉ុន្តែបញ្ហានេះនៅតែមានភាពគួរឱ្យព្រួយបារម្ភ (រូបភាពទី៤២)។ ស្ត្រីមានអត្រាខ្ពស់ជាងបុរសធ្វើការនេសាទនៅតាមមាត់ច្រាំង និងប្រមូលជីវចម្រុះ តាមទន្លេឬសមុទ្រដោយដៃ ដោយប្រើប្រាស់កន្ត្រកឈ្នៀងតូចៗជាដើម គាត់កម្រក្នុងការផ្លាស់ទីទៅកន្លែងផ្សេងៗជាងបុរសដើម្បីរក្សាទិន្នផលនេសាទ។ មានប្រមាណ ១៥ភាគរយនៃស្ត្រី និង បុរស២៦ភាគរយ បានផ្លាស់ទីតាំងនេសាទក្នុងរយៈពេល ១០ឆ្នាំចុងក្រោយ។

ការធ្លាក់ចុះបរិមាណត្រីគឺជាមូលហេតុចម្បងនៃការផ្លាស់ទីតាំងនេសាទថ្មី មានស្ត្រី ១៨ភាគរយ និងបុរស ២៩ ភាគរយ (រូបភាពទី៤៣)។ បុរសមានអត្រាខ្ពស់ជាងស្ត្រី ដែលបានលើកឡើងពីការបាត់បង់ធនធានជលផលជាហេតុផលសម្រាប់ការស្វែងរកទីតាំងនេសាទថ្មី។ ទន្ទឹមនឹងនេះ ស្ត្រី មានការប៉ះពាល់ខ្លាំងជាងបុរសដោយបញ្ហាបំពុលបរិស្ថាន និងការផ្លាស់ប្តូរច្បាប់ ឬបទបញ្ញត្តិ ដែលធ្វើឱ្យគាត់មិនអាចបន្តប្រមូលផលនៅទីតាំងមុនបានទៀត ដូចជាការកំណត់តំបន់ការពារសត្វទន្លេ ឬសមុទ្រដើម្បីជួយឱ្យប្រភេទសត្វមានឱកាសស្តារឡើងវិញ។ដើម្បីរក្សាបរិមាណទិន្នផលនេសាទ ដែលមិនអាចប្តូរទីតាំងថ្មីបាន គាត់ត្រូវបង្កើនពេលវេលាពេលនេសាទ ឬប្រមូលផលដោយដៃច្រើនជាងមុន។ តាមការប៉ាន់ស្មាន មានស្ត្រីប្រមាណជា ៤ ភាគរយ និង បុរស៧ ភាគរយ លើកឡើងថាពេលវេលានេសាទរបស់គាត់ បានអូសបន្លាយវែងយូរជាងមុន។ សម្រាប់ស្ត្រី មិនមានវិធីដោះស្រាយណាមួយឡើយ គាត់គ្រាន់តែឃើញផលប៉ះពាល់ទៅលើបរិមាណនេសាទគាត់តែប៉ុណ្ណោះ។

គួរឱ្យព្រួយបារម្ភ (ស្ត្រី១៨ ភាគរយ និងបុរស១៦ ភាគរយ) ក៏បានកត់សម្គាល់ឃើញ មានការកើនឡើងការនេសាទដោយស្ត្រីមានអត្រាខ្ពស់ជាងបុរសបន្តិចដោយសារតែការចូលរួមមិនសមាមាត្ររបស់គាត់នៅក្នុងសកម្មភាពញែក និងការសម្អាតក្រោយការប្រមូលផល ដែលផ្តល់ការមើលឃើញកាន់តែច្រើននៃការកើនឡើងបរិមាណត្រីដែលមិនចង់បាន ខណៈពេលត្រីដែលចង់បានមានការធ្លាក់ចុះ។ ត្រីដែលមិនចង់បានក៏ត្រូវបានចាប់ដែរ ដែលប្រើប្រាស់ឧបករណ៍នេសាទធំៗ(ដូចជា អួនអូសក្រោមសមុទ្រ សំណាញ់អួនអូស[១៥] និង លប ជាដើម) បានធ្វើឱ្យមានការកើនឡើងផលនេសាទត្រីមិនចង់បាន នេះបង្ហាញយ៉ាងច្បាស់លាស់នៃការបាត់បង់ជីវចម្រុះ។

១៥ purse seine គឺជាសំណាញ់លាន់លើផ្ទៃទឹក ដែលត្រូវបានប្រើសម្រាប់លើផ្ទៃសមុទ្រធំៗ ដើម្បីនេសាទសត្វទឹកជាច្រើនក្នុងពេលតែមួយ។

រូបភាពទី ៤២៖ សមាមាត្រ ចំនួនប្រជានេសាទ/អ្នកប្រមូលផលតាមសមុទ្រ បានកត់សម្គាល់ពីផលប៉ះពាល់នៃការវិចវិលបរិស្ថាន និងការបាត់បង់ជីវចម្រុះ បែងចែកតាមភេទ (ភាគរយ)




រូបភាព ៤៣៖ សមាមាត្រប្រជានេសាទ បានផ្លាស់ប្តូរទីតាំងនេសាទ/ប្រមូលផល នៅក្នុងរយៈពេល ១០ឆ្នាំចុងក្រោយ ដោយសារតែការវិចវិលបរិស្ថាន ឬការបាត់បង់ជីវចម្រុះ តាមភេទ និងមូលហេតុ (ជាភាគរយ)




សម្គាល់៖គ្មានភាពខុសគ្នារវាងស្ត្រី និងបុរសក្នុងន័យស្ថិតិ សម្រាប់ប្រភេទ "ច្បាប់និងបទបញ្ញត្តិធ្វើអោយខ្ញុំមិនអាចធ្វើនេសាទនៅទីនោះបាន"។

## ការបាត់បង់ជីវចម្រុះកំពុងជម្រុញឱ្យកសិករ ប្រជានេសាទ អ្នកបរបាញ់សត្វ និងអ្នកប្រមូលធនធានធម្មជាតិ ផ្លាស់ប្តូរវិធីសាស្ត្រដើម្បីរក្សាទិន្នផល

ការប្រែប្រួលគុណភាពដី បរិមាណ ចំនួនធនធានត្រី និង ទំហំព្រៃឈើ បានប៉ះពាល់ដល់ជីវភាពរបស់ប្រជាជនជាច្រើន។ ដើម្បីរក្សាបរិមាណទិន្នផល គាត់មិនអាចប្រកាន់ខ្ជាប់ចំពោះវិធានការទប់ស្កាត់ផ្សេងៗ ដូចជា ការប្រើសារធាតុពុលលើសកម្រិត ការប្តូរឧបករណ៍កសិកម្ម និងនេសាទ ឬធ្វើការផ្លាស់ទីតាំង។ អត្រាផ្លាស់ទីតាំងថ្មី គឺមើលឃើញបានយ៉ាងច្បាស់ ជាពិសេសចំពោះអ្នកនេសាទ និងអ្នកប្រមូលធនធានពីព្រៃ ដូចជា ដើមឈើ ស្មៅ ផ្សិត និងធនធានព្រៃផ្សេងៗទៀត ដែលជាសញ្ញាបង្ហាញពីភាពបន្ទាន់នៃការអនុម័តច្បាប់ស្តីពីការ ការពារបរិស្ថាននៅក្នុងអាងទឹក និងព្រៃឈើ (រូប៤៤)។ ជារួម  នៅកម្ពុជា បុរសមានភាគរយខ្ពស់ជាងស្ត្រី  ដែលបានផ្លាស់ប្តូរទីតាំងថ្មីដើម្បីរក្សាទិន្នផល ដោយសារស្ត្រីមានធនធានតិចជាង ការងារតិចជាង និងទំនួលខុសត្រូវក្នុងគ្រួសារកាន់តែច្រើនដែលអាចរារាំងក្នុងការផ្លាស់ប្តូរទីតាំងថ្មី។

សម្រាប់អ្នកធ្វើការងារកសិកម្ម ការផ្លាស់ប្តូរទីតាំងគឺមានការពិបាក ដោយសារគាត់ចាំបាច់ត្រូវពឹងផ្អែកលើដីដែលជាកម្មសិទ្ធិផ្ទាល់ខ្លួន  ជួល ឬមានសិទ្ធិប្រើប្រាស់។ ក្នុងករណីនេះ វិធានការប្រយុទ្ធមួយដែលគេប្រើគឺប្តូរជាប្រភេទដំណាំដែលមានភាពធន់ជាមួយអាកាសធាតុ និងសត្វល្អិត។ ស្ត្រី ២,៨ ភាគរយ និង បុរស ២,៥ ភាគរយ មានរបរខាងកសិកម្ម បានប្រើប្រាស់វិធានខាងលើ (រូបភាព៤៥)។ ឧទាហរណ៍ មានការកើនឡើងប្រើប្រាស់ពូជស្រូវ  ពោតដែលអាចធន់នឹងសីតុណ្ហភាព  ទឹកប្រៃ  ភាពរាំងស្ងួត ការលិចលង់រយៈពេលយូរ។

**រូបភាពទី ៤៤៖ សមាមាត្រនៃប្រជានេសាទ អ្នកបរបាញ់  និងអ្នកប្រមូលអនុផលព្រៃឈើ  ដែលបានប្តូរទីតាំងដោយសារការប្រែប្រួលអាកាសធាតុ តាមភេទ (ភាគរយ)**



រូបភាពទី ៤៥៖ សមាមាត្រកសិករ ដែលបានប្តូរដំណាំដាំដុះ បណ្តាលមកពីការប្រែប្រួលអាកាសធាតុ តាមភេទ (ភាគរយ)




## ការគ្រប់គ្រងកាកសំណល់ប្រកបដោយប្រសិទ្ធភាព មានសារៈសំខាន់ណាស់ក្នុងការបញ្ឈប់ការរីករាលដាលនៃការបំពុល និងការបាត់បង់ជីវៈចម្រុះ ទោះបីជាស្ត្រីមានច្រើនបានចូលរួមក៏ដោយ

នៅកម្ពុជា ស្ត្រី និងបុរស ៦ ភាគរយ បានចូលរួមក្នុងការគ្រប់គ្រងកាកសំណល់ (នៅខាងក្រៅគ្រួសារ)។ សកម្មភាពទាំងនេះរួមមានការប្រមូល ការញែក ការសម្អាត និងការនាំយកកាកសំណល់ទៅកែច្នៃ និងប្រើប្រាស់ឡើងវិញ វាមានសារៈសំខាន់ណាស់ក្នុងការដោះស្រាយការបំពុល ដែលជាកត្តារួមចំណែកដ៏សំខាន់ដល់វិបត្តិទាំងបីយ៉ាង។ ស្ត្រីប្រមាណ ២៦ ភាគរយ និង បុរស៣០ ភាគរយ ដែលចូលរួមក្នុងការគ្រប់គ្រងកាកសំណល់បានកត់សម្គាល់ថាពួកគាត់ធ្វើវាដោយគ្មានប្រាក់កម្រៃ (រូបភាព ៤៦)។ នេះប្រហែលជាដោយសារពួកគាត់បំពេញកិច្ចការទាំងនេះដើម្បីជួយអ្នកដទៃ ឬអាចមកភាពលំអៀង។ ជាឧទាហរណ៍ ស្ត្រីប្រមាណ ២០ ភាគរយ និងបុរស ៣០ ភាគរយបានរាយការណ៍ថា មានមនុស្សផ្សេងទៀតទទួលប្រាក់ឈ្នួលខ្ពស់ជាងគាត់ សម្រាប់ការញែក និងធ្វើការលក់បន្តសម្ភារៈដូចគ្នា (រូបភាព ៤៧)។

បុរសជាច្រើនបានធ្វើការប្រមូលកាកសំណល់ មានអារម្មណ៍ថា ស្ត្រីទទួលប្រាក់ឈ្នួលខ្ពស់ជាងគាត់ សម្រាប់ការញែក និងកែច្នៃឡើងវិញ។ នៅកម្ពុជា ស្ត្រីគឺជាពលកម្មសំខាន់បំផុតក្នុងការប្រមូលសំណល់ដែលអាចកែច្នៃ ឬប្រើប្រាស់ឡើងវិញបាន។ ស្ត្រីដែលធ្វើការពាក់ព័ន្ធនឹងវិស័យនេះ គេស្គាល់ថាជា "អេតចាយ" ដែលភាគច្រើនបានធ្វើចំណាកស្រុកពីពីជនបទចូលមកតំបន់ទីក្រុង ដើម្បីស្វែងរកការងារ ប៉ុន្តែអាចរកបានតែការងារដែលមានប្រាក់ឈ្នួលទាប បណ្តាលឱ្យគាត់ធ្វើការប្រមូលសំណល់ដើម្បីបន្ថែមចំណូល ជាពិសេសសម្រាប់បង់ថ្លៃសិក្សារបស់កូនៗ និងផ្ញើប្រាក់មកគ្រួសារ ពោលគឺដោយសារស្ត្រីមានចំនួនច្រើនជាងបុរសក្នុងវិស័យប្រមូលសំណល់នៅកម្ពុជា គាត់ក៏មានឱកាសខ្ពស់ជាងបុរសក្នុងការចាត់ចែងសម្ភារៈមានតម្លៃខ្ពស់ ដូចជា ដែក និងអាលុយមីញ៉ូម ខណៈពេលដែលបុរសមានច្រើនជាងស្ត្រី ផ្តោតលើ កេសក្រដាស ប្លាស្ទិច ឬសម្ភារៈផ្សេងៗដែលមានតម្លៃទាប (រូបភាព ៤៨)។

ផ្ទុយទៅវិញ បុរសបានចូលរួមការគ្រប់គ្រងកាកសំណល់ច្រើនជាង ក្នុងការប្រើប្រាស់រទេះ ឬកង់សម្រាប់ប្រតិបត្តិការទាំងនេះ (ស្ត្រី ៣ភាគរយ និង បុរស១១ភាគរយ) ដែលអាចជួយបង្កើនប្រសិទ្ធភាពពេលវេលា និងការខិតខំប្រឹងប្រែងរបស់គាត់។ ពួកគាត់ជាច្រើនបានប្រើឧបករណ៍ការពារផងដែរ ដែលជួយការពារការរងរបួស និងការឆ្លងមេរោគ (រូបភាពទី ៥០)។

**រូបភាពទី ៤៦៖ សមាមាត្រ ប្រជាជនដែលចូលរួមក្នុងការគ្រប់គ្រងកាកសំណល់ (ឆ្វេង) និងចូលរួមចំណែក ការគ្រប់គ្រងកាកសំណល់ទទួលបានប្រាក់ចំណូល/ទទួលបានទឹកប្រាក់ (ស្តាំ) បែងចែកតាមភេទ (ភាគរយ)**




**រូបភាពទី ៤៧៖ សមាមាត្រប្រជាជនដែលចូលរួមក្នុងការគ្រប់គ្រងកាកសំណល់និងទទួលបានភាពអយុត្តិធម៌(មិនស្មើគ្នា) បែងចែកតាមភេទ (ភាគរយ)**



រូបភាពទី ៤៨៖ សមាមាត្រប្រជាជនដែលចូលរួមក្នុងការគ្រប់គ្រងសំណល់ដែលមានតម្លៃខ្ពស់ ឬទាប បែងចែកតាមភេទ និងប្រភេទសម្ភារៈ (ភាគរយ)




សម្គាល់: មិនមានភាពខុសគ្នារវាងស្ត្រី និងបុរសក្នុងន័យស្ថិតិកម្រិតជឿជាក់ α=0,05 ក្នុងប្រភេទ ទាំងមានតម្លៃខ្ពស់ និងទាប

## របរចិញ្ចឹមជីវិតដែលពាក់ព័ន្ធនឹងបរិស្ថានខ្លះ មានហានិភ័យខ្ពស់ចំពោះសុខុមាលភាព រួមទាំងការទទួលរងជំងឺ បទឧក្រិដ្ឋកម្ម និងអំពើហិង្សា

មុខរបរខ្លះៗដែលពាក់ព័ន្ធនឹងបរិស្ថានអាចបង្កើនហានិភ័យដល់សុខភាពបាន។ ឧទាហរណ៍ នៅកម្ពុជា ស្ត្រីប្រហែល ៦ភាគរយ និងបុរស១១ភាគរយ បានធ្វើការងារជាមួយការគ្រប់គ្រងសំណល់ បានជួបប្រទះជំងឺដែលកើតចេញពីការងារនេះ (រូបភាពទី៤៩)។ ការខ្វះឧបករណ៍ការពារនិងសម្ភារៈសុវត្ថិភាពបានធ្វើឱ្យគាត់ក្លាយជាពលកម្មដែលងាយរងគ្រោះ។ មានតែ ស្ត្រី៧ភាគរយ និងបុរស៩ភាគរយ ប៉ុណ្ណោះ ដែលប្រើប្រាស់ឧបករណ៍ ការពារ សម្រាប់ការគ្រប់គ្រងនិងប្រមូលកាកសំណល់ (រូបភាពទី៥០)។ សម្ភារៈដែលត្រូវបានប្រើប្រាស់ជាញឹកញាប់ក្នុងការគ្រប់គ្រងកាកសំណល់គឺ បាវ ឬ កាបូប និងកន្ត្រកកញ្ចែ ដែលមានស្ត្រី ៩២ភាគរយ និងបុរស ៩០ភាគរយ ប្រើប្រាស់វា។

បន្ថែមពីនេះទៅទៀត ស្ត្រី ១៦ភាគរយ និង បុរស២១ភាគរយ ដែលបានចូលរួមក្នុងការគ្រប់គ្រងសំណល់ បានរាយការណ៍ថា គាត់មានអារម្មណ៍មិនមានសុវត្ថិភាព ខណៈពេលកំពុងប្រមូល ការញែក ឬការកែច្នៃ(រូបភាពទី៤៩)។ ភាពមិនមានសុវត្ថិភាពនេះអាចពាក់ព័ន្ធនឹងការសាយភាយនៃជំងឺ និងការរងរបួស ព្រមទាំង ហានិភ័យនៃអំពើហិង្សា ក្នុងបរិបទនៃការគ្រប់គ្រងសំណល់ ដូចជា ករណីប្រកួតប្រជែងគ្នាដើម្បីយកសំណល់អេតចាយ ការចរចាជាក់លាក់សម្រាប់ប្រាក់ឈ្នួលនៅកន្លែងញែកសំណល់ បំពេញការងារដោយឡែកនៅពេលយប់ ឬនៅតំបន់មិនមានសុវត្ថិភាព។ ភាគច្រើននៃអ្នកប្រមូលសំណល់បានប្រមូលជាមួយប្ដី ប្រពន្ធ ឬសមាជិកគ្រួសារផ្សេងទៀត ប៉ុន្តែមានរហូតដល់ ៤៤ភាគរយនៃស្ត្រីបានប្រមូលតែឯង (រូបភាពទី៥១)។ ទោះជាយ៉ាងណាក៏ដោយ ហានិភ័យសុវត្ថិភាពខ្ពស់បំផុតត្រូវបានឃើញមានដោយអ្នកដែលប្រមូលសំរាមតែម្នាក់ឯង។

ដូចគ្នានេះដែរ ក្នុងចំណោមអ្នកដែលចូលរួមក្នុងការប្រមូលទឹក និងឥន្ទនៈ ស្ទើរតែ ២០ ភាគរយ មានអារម្មណ៍ថា មិនមានសុវត្ថិភាពយ៉ាងហោចណាស់ម្តង (រូបភាព ៤៩) ។ នៅកម្ពុជា បុរសទំនងជាទទួលខុសត្រូវលើការប្រមូលទឹកសម្រាប់គ្រួសារ (សូមមើលផ្នែកទី IV) ប៉ុន្តែស្ត្រីនៅតែមានអារម្មណ៍មិនមានសុវត្ថិភាពខ្ពស់នៅពេលបំពេញការងារទាំងនេះ តាមទីប្រជុំជន និងភូមិនានា ដែលជារឿយៗដោយសារតែហានិភ័យនៃការប្រឈមមុខនឹងអំពើហិង្សា ឬឧក្រិដ្ឋកម្មផ្សេងៗនៅតាមដងផ្លូវ (រូបភាព ៥២) ។

### រូបភាពទី ៤៩៖ សមាមាត្រប្រជាជនដែលមានអារម្មណ៍ថាមិនមានសុវត្ថិភាពក្នុងការគ្រប់គ្រងកាកសំណល់ ការប្រមូលទឹក ឬឥន្ទនៈ ការរើស/ញែកកាកសំណល់ ឬធ្លាប់មានជំងឺ/របួស បែងចែកតាមភេទ (ភាគរយ)




### រូបភាពទី ៥០៖ សមាមាត្រប្រជាជនដែលចូលរួមក្នុងការគ្រប់គ្រងកាកសំណល់ដែលប្រើប្រាស់ឧបករណ៍ បែងចែកតាមភេទ (ភាគរយ)



### រូបភាពទី ៥១៖ សមាមាត្រ ប្រជាជនដែលចូលរួមក្នុងការគ្រប់គ្រងកាកសំណល់ដែលធ្វើសកម្មភាពទាំងនេះតែម្នាក់ឯង/រួមគ្នា និងធ្លាប់មានអារម្មណ៍ថាមិនមានសុវត្ថិភាព បែងចែកតាមភេទ




### រូបភាពទី៥២៖ សមាមាត្រប្រជាជនដែលពាក់ព័ន្ធនឹងការប្រមូលទឹក ដែលបានមានអារម្មណ៍ថាមិនមានសុវត្ថិភាព បែងចែកតាមភេទ ចម្ងាយទៅកាន់ប្រភពទឹក និងទីតាំង (ជាភាគរយ)



## ផ្នែកទី៤៖ ការអភិរក្សបរិស្ថាន ការរិចរិល និងការធ្វើសេចក្ដីសម្រេចចិត្ត

### ការប្រើប្រាស់ជី ថ្នាំសម្លាប់សត្វល្អិត ដែលបំផ្លាញបរិស្ថាន កំពុងតែជម្រុញការរីករាលដាល និងភាពខុសគ្នាផ្នែកយេនឌ័រ សម្រាប់ការយល់ដឹង និងកាត់បន្ថយហានិភ័យ

ការយល់ដឹងអំពីសារៈសំខាន់ បម្រែបម្រួល និងកម្រិតនៃអន្តរកម្មរបស់មនុស្សជាមួយបរិស្ថាន គឺមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការទទួលស្គាល់ពីតួនាទីសំខាន់ៗដែលបុរស និងស្ត្រីអាចមានសកម្មភាពក្នុងការអភិរក្សបរិស្ថាន ឬផ្ទុយទៅវិញក្នុងការបង្កការបំផ្លិចបំផ្លាញបរិស្ថានបន្ថែម។ ភាពខុសគ្នារវាងយេនឌ័រ បុរស និងស្ត្រីមានឥទ្ធិពលលើការចូលរួមដំណើរការផលិតផលបរិស្ថាននានា និងសកម្មភាពដែលពាក់ព័ន្ធ ហើយបញ្ជាក់អំពីអាកប្បកិរិយារបស់គាត់ក្នុងការអភិរក្ស ឬបំផ្លិចបំផ្លាញធនធានធម្មជាតិ។

ក្នុងចំណោមអ្នកដាំដុះដំណាំ ឬចិញ្ចឹមសត្វ បុរសមានច្រើនជាងស្ត្រី បានប្រើប្រាស់សារធាតុបាញ់សម្លាប់សត្វល្អិត និងសារធាតុជម្រុញការលូតលាស់ (synthetic) (រូបភាពទី៥៣) ស្ថានភាពនេះអាចបណ្ដាលមកពីបុរសអាចមានលទ្ធភាពទិញបានជាងស្ត្រី និងការចូលរួមរបស់បុរសលើវិស័យកសិកម្មធំៗ។ ការប្រើប្រាស់សារធាតុទាំងនេះអាចបណ្ដាលឱ្យមានការបាត់បង់ជីវចម្រុះ ការបំពុល និងបញ្ហាសុខភាពមនុស្ស ដូចជារលាកប្រព័ន្ធប្រសាទ និងបញ្ហាប្រព័ន្ធបន្តពូជ ដូច្នេះការដោះស្រាយ និងការគ្រប់គ្រងវាគួរត្រូវធ្វើដោយប្រុងប្រយ័ត្ន។ ត្រូវមានវិធានការដើម្បីកាត់បន្ថយហានិភ័យទាំងនេះ ប៉ុន្តែមិនមែនគ្រប់គ្នាធ្វើតាមនីតិវិធីសមរម្យទេ និងមានភាពខុសគ្នារវាងបុរសនិងស្ត្រីក្នុងឥរិយាបថនេះផងដែរ។ ឧទាហរណ៍ ដើម្បីការពារសុខភាព បុរសមានអត្រាខ្ពស់ជាងស្ត្រីដែលអនុវត្តន៍ និងធ្វើតាមសេចក្ដីណែនាំលើស្លាកផលិតផល (ស្ត្រី៥៣ភាគរយ និងបុរស៥៨ភាគរយ) ប៉ុន្តែមានតិចជាង ៣០ភាគរយប៉ុណ្ណោះ ដែលលាងសំអាត និងថែទាំឧបករណ៍ការពារ បន្ទាប់ពីប្រើប្រាស់ ដែលអាចបង្កឱ្យមានការបំពុល (រូបភាពទី៥៤)។

បុរសហាក់បីដូចជា មិនសូវបានរៀបចំទុកដាក់ដបសារធាតុបាញ់សត្វល្អិត ឬឧបករណ៍ពាក់ព័ន្ធដោយសុវត្ថិភាពនោះទេ។ មានតែ១៦ភាគរយនៃស្ត្រី និងបុរស១១ភាគរយ ដែលប្រើប្រាស់សារធាតុទាំងនេះ បានរៀបចំទុកដាក់វាដោយសុវត្ថិភាព តែភាគច្រើនបានរៀបចំទុកដាក់ជាមួយសំរាមគ្រួសារ នៅកន្លែងដុតសំរាម ឬក្បែរទីតាំងប្រើប្រាស់ (ឧទាហរណ៍ វាលកសិកម្ម ឬជាប់នឹងប្រភពទឹក) ដែលអាចបង្កការបំពុលរយៈពេលវែង ហើយបង្កការខូចខាតយូរអង្វែងដល់ប្រព័ន្ធទឹក និងដីនៅជិតកន្លែងបោះចោល។

ទោះបីមានជឿជាក់ពីអ្នកប្រើថ្នាំបាញ់សម្លាប់សត្វល្អិត ប្រហែលជាពាក់កណ្ដាល គាត់បានគ្រប់គ្រងសារធាតុទាំងនេះបានត្រឹមត្រូវដើម្បីការពារបរិស្ថាន និងសុខភាពផ្ទាល់ខ្លួន (ដោយធ្វើតាមសេចក្ដីណែនាំលើស្លាកផលិតផល) ការយល់ដឹងអំពីវាមិនបានពេញលេញ និងត្រឹមត្រូវជានិច្ចនោះទេ។ នៅពេលសួរថា សារធាតុដែលគាត់ប្រើប្រាស់មានហានិភ័យចំពោះសុខភាពមនុស្ស និងបរិស្ថានដែរឬទេ ៩៧ភាគរយនៃអ្នកប្រើប្រាស់ឆ្លើយថា គាត់ច្រើនប្រើសារធាតុមានហានិភ័យមធ្យម និងមានតែ៤ភាគរយប៉ុណ្ណោះប៉ាន់ប្រមាណថា ពួកគេប្រើសារធាតុមានភាពពុលខ្លាំងដែលតម្រូវឱ្យមានបច្ចេកទេស នីតិវិធីការអនុវត្តន៍ និងរៀបចំទុកដាក់ដាក់លាក់ ដូចជា៖ ប្រើឧបករណ៍បាញ់ថ្នាំមាន

ក្បាលបាញ់វេទ្ធធំៗដើម្បីកាត់បន្ថយការសាយភាយក្នុងបរិយាកាស ការជៀសវាងការបាញ់សារជាតុនៅពេលមានកំដៅខ្លាំង ខ្យល់ខ្លាំង ឬភ្លៀង ជៀសវាងការបាញ់នៅជិតប្រភពទឹក ទុកកាកសំណល់ដបចូលនៅក្បែរប្រភពទឹក និងចោលទឹកដែលបានសំអាតឧបករណ៍សារជាតុបាញ់ទៅកាន់ទីតាំងមួយដែលមានស្លាកសម្គាល់ជាក់លាក់ ប៉ុន្តែកន្លែងនេះភាគច្រើនមិនមានទេ។ នៅកម្ពុជា បើប្រៀបធៀបនឹងការសិក្សាមុនៗបានបញ្ជាក់ថា ការប្រើប្រាស់ថ្នាំពុលបាញ់សម្លាប់សត្វល្អិតមានហានិភ័យខ្ពស់យ៉ាងទូលំទូលាយជាសកល។ ឧទាហរណ៍៖ តាមការសិក្សារបស់អង្គការកសិកម្មនិងស្បៀងអាហារពិភពលោក(FAO) នៃអង្គការសហប្រជាជាតិ នៅឆ្នាំ ២០០៨ បានបញ្ជាក់ថា៖ ៤៣ ភាគរយនៃកសិករប្រើសារជាតុថ្នាក់ ១a (ពុលខ្លាំងណាស់) ហើយ ៨៤ ភាគរយប្រើសារជាតុថ្នាក់ទី II (ពុលខ្លាំង[១៦])។ ស្រដៀងគ្នានេះដែរ ការសិក្សាពីគំរូទឹក និងដីនៅឆ្នាំ ២០២៣[១៧] និង ២០២៤[១៨]បានបង្ហាញថា កម្រិតសារជាតុ tebufenozide ក្នុងទឹក (ដែលចាត់ទុកថាពុលខ្លាំងចំពោះជីវិតអាកាសជាតុ) និងសារជាតុ bromphos-ethyl ក្នុងដី (ដែលពុលខ្លាំងចំពោះឃ្មុំ និងសត្វល្អិតទឹក) មានកម្រិតលើសចំណុះសុវត្ថិភាពយ៉ាងខ្លាំង។

ការសិក្សាបន្ថែម ឆ្នាំ២០២៤ បានកំណត់ថា សារជាតុប្រឆាំងរោគរុក្ខជាតិ dimethomorph ត្រូវបានរកឃើញនៅក្នុងបន្លែប្រភេទផ្សេងៗជាច្រើន និងក្នុងត្រីភាគច្រើន បើទោះបីជាសារជាតុនេះមានហានិភ័យទាបជាង tebufenozide និង bromphos-ethyl។ ស្តង់ដារអន្តរជាតិសម្រាប់ការប្រើប្រាស់សារជាតុទាំងនេះ ទាមទារឱ្យប្រើវ៉ែនតា និងម៉ាសខ្យល់ពេលបាញ់[១៩] ទោះជាយ៉ាងណាក៏ដោយ វត្ថុបរិក្ខារទាំងនេះត្រូវបានប្រើប្រាស់យ៉ាងតិចនៅកម្ពុជា។

[១៦] See Visarto Preap and Kang Sareth, ២០១៦, Current use of pesticides in the agricultural products of Cambodia. AgNews (news.agropages.com). and FAO ២០១៥, Progress in pesticide risk assessment and phasing-out of highly hazardous pesticides in Asia.

[១៧] See Putheary Ngin et al., ២០២៤, Pesticide screening of surface water and soil along the Mekong River in Cambodia, Science of the Total Environment, vol. ៩១២.

[១៨] See Putheary Ngin, ២០២៤, Pesticides in Cambodia: usage, fate, and health risk. Umeå University, Department of Chemistry.

[១៩] See Tebunfenocide and its associated end use products. Re-evaluation decision.

## រូបភាពទី ៥៣៖ សមាមាត្រ ប្រជាជនដែលប្រើប្រាស់ជីសម្រាប់កសិកម្ម ឬបសុសត្វនិងបានប្រើប្រាស់ជី ថ្នាំសម្លាប់សត្វល្អិត ឬសារធាតុជម្រុញការលូតលាស់ បែងចែកតាមភេទ (ភាគរយ)




## រូបភាពទី៥៤៖ សមាមាត្រ ប្រជាជនដែលប្រើប្រាស់ថ្នាំសំយោគសម្លាប់សត្វល្អិត ឬសារធាតុរ៉ែ ដែលដាក់ចេញនូវវិធានការការពារផលប៉ះពាល់លើសុខភាពមនុស្ស បែងចែកតាមភេទ (ភាគរយ)




ពេលនិយាយអំពីការប្រើប្រាស់ជី ៦៨ភាគរយ ជឿជាក់ថាគាត់បានអនុវត្តតាមសេចក្ដីណែនាំពីអ្នកលក់ឬបទប្បញ្ញត្តិដើម្បីការពារបរិស្ថាន ដូចជាមិនប្រើជីលើសពីបរិមាណដែលបានផ្ដល់អនុសាសន៍។ ៥៧ ភាគរយ ក៏បានបញ្ជាក់ថាបានប្រើជីត្រឹមត្រូវតាមអំឡុងពេលលូតលាស់ដំណាំ(រូបទី៥៥)។ទោះជាយ៉ាងណា ការប្រើជីខុសគោលការណ៍ក៏មានការរាលដាលយ៉ាងទូលំទូលាយផងដែរ។លើសពីនេះទៅទៀត ស្ត្រីមានតែប្រមាណ ៦ ភាគរយ និង បុរស៨ ភាគរយដែលយកប្រភេទដី និងអាកាសធាតុមកពិចារណាក្នុងការសម្រេចចិត្តប្រើប្រាស់សារធាតុទាំងនេះ។ ការអនុវត្តខុស និងការយល់ឃើញខុសរបស់កសិករបង្ហាញឱ្យឃើញថា ត្រូវមានការកែលម្អការអប់រំនិង បណ្ដុះបណ្ដាលកសិករឱ្យកាន់តែប្រសើរ ដើម្បីជួយការពារបរិស្ថាន។ ឧទាហរណ៍ ការលើកស្ទួយការប្រើប្រាស់ជី និងថ្នាំសម្លាប់សត្វល្អិតអោយបានត្រឹមត្រូវ កែលម្អការយល់ដឹងអំពីការណែនាំលើស្លាកសញ្ញា បទបញ្ញត្តិដែលទាក់ទងនឹងថ្នាំកសិកម្ម ព្រមទាំងជី ដើម្បីបង្រួមទំហំផលប៉ះពាល់ដល់សុខភាពមនុស្ស និងបរិស្ថាន។ អនុវត្តន៍ផ្សេងទៀតដែលអាចជួយកាត់បន្ថយការបំផ្លាញដី រួមមានការដំណាំគម្របការពារ ជំនួសជីសំយោគ និងជីរ៉ែ។ នៅកម្ពុជា ស្ត្រី៥ ភាគរយ និង បុរស៧ ភាគរយ ដាំដុះរុក្ខជាតិសណ្ដែកជាដំណាំគម្របការ ដែលជួយបញ្ចូល សារធាតុចិញ្ចឹមឡើងវិញនៅក្នុងដីដោយធម្មជាតិ។

## រូបទី ៥៥៖ សមាមាត្រប្រជាជនដែលប្រើប្រាស់ដីសម្រាប់កសិកម្ម ឬចិញ្ចឹមសត្វ ហើយបានអនុវត្តវិធានការដើម្បីកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងដី បែងចែកតាមភេទ (ភាគរយ)




សម្គាល់៖ មិនមានភាពខុសគ្នារវាងស្ត្រី និងបុរសក្នុងន័យស្ថិតិនៅ α=0,0៥ សម្រាប់ប្រភេទ "ប្រើប្រភពសារជាតុចិញ្ចឹម" "ប្រើប្រាស់ដីសំយោគ ឬជីរ៉ែ" និង "អនុវត្តការគ្រប់គ្រងសារជាតុចិញ្ចឹមដាក់លាក់តាមតំបន់ ឬការធ្វើកសិកម្មច្បាស់លាស់"

## បុរស មានច្រើនជាងស្ត្រីក្នុងការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថានលើវិស័យកសិកម្ម និងការចិញ្ចឹមសត្វ

ការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថានលើវិស័យកសិកម្ម និងការចិញ្ចឹមសត្វ ក្នុងចំណោមបុរសជាងស្ត្រី (រូបភាព៥៦) ។ ជាឧទាហរណ៍ បុរសជាធម្មតាគ្រប់គ្រងដំណើរការកសិកម្មខ្នាតធំច្រើនជាងស្ត្រី ដែលបានអនុវត្តន៍តាមការណែនាំស្លាកនៅលើសំបកវេចខ្ចប់ ថ្នាំសម្លាប់សត្វល្អិតអំឡុងពេលប្រើរួច (ស្ត្រី៤៩ ភាគរយ និង បុរស៥៣ ភាគរយ) ដោយរក្សាកម្រិតនិងបរិមាណប្រើថ្នាំសម្លាប់សត្វល្អិតដើម្បីការពារភាពធន់ ។ ផ្ទុយមកវិញ ស្ត្រីមានអត្រាខ្ពស់ជាបុរស ប្រើប្រាស់ជីដែលមិនមានជាតិគីមី ដូចជាការប្រើប្រាស់ដំណាំចម្រុះ និងដំណាំវិលជុំ (crop rotation) ដើម្បីការពារគុណភាពដី។ ការអនុវត្តការអភិរក្សបរិស្ថានសំខាន់ៗ ដូចជាការទុកដីអោយនៅទំនេរ ដែលអាចឱ្យដីមានជីវជាតិឡើងវិញ ត្រូវបានអនុវត្តដោយស្ត្រីតែ ៩ ភាគរយ និងបុរស ១០ ភាគរយប៉ុណ្ណោះ។ ដោយសារស្ត្រីជាច្រើនប្រកបរបរកសិកម្មនៅក្នុងសួនច្បារតាមផ្ទះ ជាទូទៅមានដីផ្ទាល់ខ្លួនតិចជាងបុរស ស្ត្រីបានទុកដីអោយនៅទំនេរតិចជាងបុរស។

ការប្រើប្រាស់វិធីដុតភ្លើង ដែលកសិករប្រើដើម្បីសម្អាតដីសម្រាប់ការដាំដំណាំ ឬដុតស្មៅ និងសារជាតុរុក្ខជាតិដែលនៅសល់នៅលើដីកសិកម្មក្រោយការប្រមូលផល នៅកម្ពុជានៅតែមានការប្រើប្រាស់យ៉ាង ទូលំទូលាយ ស្ត្រី ៨ ភាគរយ បុរសនិង ១០ ភាគរយបានអនុវត្តវិធីនេះជាប្រចាំរដូវ។ ការអនុវត្តនេះបណ្តាលឱ្យមានសំណឹកដី និងការថយចុះសារជាតុចិញ្ចឹមក្នុងរយៈពេលយូរ រួមចំណែកដល់ការបាត់បង់សត្វល្អិត និងប្រភេទសត្វ ធ្វើឱ្យគុណភាពនៃទឹកនៅក្បែរនោះកាន់តែអាក្រក់ និងរួមចំណែកដល់ការបំពុលខ្យល់យ៉ាងខ្លាំង។ ការទប់ស្កាត់ការអនុវត្តនេះគឺមានសារៈសំខាន់បំផុតក្នុងការលើកកម្ពស់គុណភាពដី ការអភិរក្សជីវចម្រុះ និងសុខភាពមនុស្ស។
ការរក្សាទុករុក្ខជាតិធម្មជាតិ ដូចជា ព្រៃឈើធម្មជាតិ វាលស្មៅធម្មជាតិ និងស្រះទឹកធម្មជាតិ នៅលាយលំជាមួយដីកសិកម្ម វាបានជួយអភិរក្សជីវចម្រុះ និងការពារការបាក់បែកគុណភាពដី។ នៅកម្ពុជាមានស្ត្រីប្រមាណ ៣៦ ភាគរយ និងបុរស ៣៥ ភាគរយ ធ្វើកសិកម្មលើដីដែលមានវាលស្មៅធម្មជាតិ ឬដីចំការជាដីស្មៅ (តាមរូបទី៥៧)។ ទោះជាយ៉ាងណាក៏ដោយ មានស្ត្រីតែ ៦ ភាគរយ និងបុរស ៧ ភាគរយប៉ុណ្ណោះ ដែលធ្វើកសិកម្មលើដីសើម ឬស្រះធម្មជាតិ និងមានតែ ៤ ភាគរយនៃប្រជាជនប៉ុណ្ណោះដែលធ្វើកសិកម្មលើដីវាលព្រៃធម្មជាតិ។ ការបាត់បង់យ៉ាងលឿននៃធម្មជាតិទាំងនេះកំពុងធ្វើឱ្យមានការបាត់បង់បរិមាណនិងប្រភេទសត្វល្អិតជាច្រើន រួមមានសត្វល្អិត សត្វស្លាបល្អិតដែលមានផលប៉ះពាល់ដោយផ្ទាល់ដល់ទិន្នផលកសិកម្ម។ ដូចគ្នានេះដែរ ការបាត់បង់តំបន់ដីសើមធម្មជាតិគឺបង្កការលំបាកយ៉ាងខ្លាំងចំពោះការរកទឹកសម្រាប់ធ្វើស្រោចស្រព និងទឹកប្រើប្រាស់ វត្តរដូវភ្លៀងមិនទៀងទាត់ វាបានចូលរួមយ៉ាងខ្លាំងនៃការបាត់បង់ជីវចម្រុះក្នុងទឹកទឹក និងជីវចម្រុះលើដី ដែលទាំងអស់នេះមានផលប៉ះពាល់អវិជ្ជមានដល់ផលិតភាពរបស់ប្រព័ន្ធអេកូឡូស៊ី និងការធ្វើកសិកម្មផ្ទាល់តែម្តង។

ការអនុវត្តវិធានការការពារបរិស្ថានដែលពាក់ព័ន្ធនឹងការចិញ្ចឹមសត្វមានភាពទូលំទូលាយនៅកម្ពុជា។ មានប្រជាជនរហូតដល់៩៥ភាគរយ បានរាយការណ៍ថាគាត់បានចិញ្ចឹមសត្វដោយមិនប្រើសារជាតុអង់ទីប៊ូទិក( Antibiotics) នៅក្នុងចំណី ដែលជួយបង្កើនការលូតលាស់លើសត្វពាហនៈ ឬសត្វស្លាប (មើលរូបទី ៥៨)។ វាជាវិធីសាស្ត្រសំខាន់មួយដើម្បីធានាសុខភាពបរិស្ថាន និងសុខភាពមនុស្ស និងគួរតែបានលើកទឹកចិត្តឱ្យអនុវត្តបន្ត។ ទោះជាយ៉ាងណា វិធានការការពារបរិស្ថានផ្សេងៗទៀត មិនមានភាពទូលំទូលាយនោះទេ។ មានតែស្ត្រី ៣០ ភាគរយ និងបុរស ២៩ ភាគរយប៉ុណ្ណោះ ដែលប្រើវិធីសាស្ត្រផ្លាស់ប្តូរទីវាលឬកន្លែងចិញ្ចឹមសត្វ ដើម្បីបង្ការការរីករាលដាលសត្វល្អិតបំផ្លាញ និងការប៉ះពាល់ពីការចិញ្ចឹមលើសកម្រិត។ ទោះបីជាយ៉ាងនេះក៏ដោយ នៅពេលដែលបានសួរថាតើការគាត់ចិញ្ចឹមសត្វ មានការការពារធនធានធម្មជាតិ និងជីវចម្រុះឬទេ មានស្ត្រី ១៩ ភាគរយ និងបុរស ២៣ ភាគរយបានឆ្លើយថា មាន។ នេះអាចបណ្តាលមកពី ពួកគាត់មិនប្រើប្រាស់ថ្នាំអង់ទីប៊ីយោទិច (antibiotics) អរម៉ូនជួយលូតលាស់នៅក្នុងចំណីអាហារសត្វ ឬសារជាតុគីមីផ្សេងទៀត។ ឧទាហរណ៍ មានស្ត្រី ៤ ភាគរយ និងបុរស ៥ ភាគរយប៉ុណ្ណោះ ដែលប្រើបច្ចេកវិទ្យាបង្កាត់ពូជ (genetic engineering) កាំរស្មីអ៊ីយ៉ុង ឬជាតិវិទ្យុសកម្ម ដើម្បីថែរក្សាសត្វ ទាំងនេះជាសញ្ញាល្អនិងគួរលើកទឹកចិត្ត។ ទោះបីជាយ៉ាងណា ការលើកកម្ពស់សមត្ថភាពកសិករអំពីសារៈសំខាន់នៃការធ្វើធ្វើរបងការពារដើម្បីផ្លាស់ប្តូរទីវាលឬកន្លែងចិញ្ចឹមសត្វឱ្យមានប្រសិទ្ធ និងការពារការបាត់បង់គុណភាព ដី គឺមានសារៈសំខាន់ ហើយគួរតែបានផ្តល់អាទិភាពនៅទូទាំងប្រទេស។

## រូបភាពទី ៥៦៖ សមាមាត្រប្រជាជនដែលចូលរួមក្នុងវិស័យកសិកម្ម និងការចិញ្ចឹមសត្វ ដែលបានអនុវត្តវិធានការដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន បែងចែកតាមភេទ (ភាគរយ)




ចំណាំ៖ មិនមានភាពខុសប្លែកគ្នារវាងស្ត្រី និងបុរសគឺមិនសំខាន់តាមស្ថិតិនៅ α=0,0៥ សម្រាប់ប្រភេទ "ការអនុវត្តន៍គម្លាតដំណាំ" និង "អនុវត្តការគ្រប់គ្រងសត្វល្អិតជីវសាស្ត្រ",

## រូបភាពទី ៥៧៖ សមាមាត្រប្រជាជនដែលប្រកបរបរកសិកម្មនៅលើដីដែលរួមមានព្រៃធម្មជាតិ ឬចម្រុះ ឬលក្ខណៈផ្សេងទៀតដែលអំណោយផលដល់ការអភិរក្សជីវៈចម្រុះ និងការអភិរក្សគុណភាពដី តាមភេទ (ភាគរយ)




សម្គាល់៖ មិនមានភាពខុសប្លែកគ្នារវាងស្ត្រី និងបុរសក្នុងន័យស្ថិតិនៅ α=0,0៥ សម្រាប់ប្រភេទ "រុក្ខជាតិផ្កាថ្ម" និង "គំនរថ្ម ឬឈើ",

## រូបទី៥៨៖ សមាមាត្រអ្នកចិញ្ចឹមសត្វ ដែលអនុវត្តវិធានចិញ្ចឹមសត្វ ដើម្បីថែរក្សធនធានធម្មជាតិ និងជីវចម្រុះ តាមភេទ (ភាគរយ)




ចំណាំ៖ មិនមានភាពខុសប្លែកគ្នារវាងស្ត្រី និងបុរសក្នុងន័យស្ថិតិនៅ α=0,0៥ សម្រាប់ប្រភេទ "សត្វដែលគ្រប់គ្រងដោយគ្មានថ្នាំអង់ទីប៊ីយោទិច អ័រម៉ូនលូតលាស់ ថនិកសត្វ ឬសត្វបក្សីដោយផលិតផល ឬគ្រឿងផ្សំចំណីផ្សេងទៀត"

## ការធ្វើវារីវប្បកម្មមានហានិភ័យបរិស្ថានខ្ពស់ ដោយសារបុរសបានប្រើប្រាស់បរិមាណថ្នាំសម្លាប់មេរោគ និងស្ត្រីប្រើប្រាស់បរិមាណចំណីមិនសមាមាត្រ

នៅកម្ពុជា មានប្រមាណ ៣ភាគរយនៃប្រជាជន បានចូលរួមចំណែកក្នុងវិស័យវារីវប្បកម្ម។ ទោះបីវាអាចជួយលើសុវត្ថិភាពស្បៀងអាហារ និងជីវភាពរស់នៅក៏ដោយ ការធ្វើវារីវប្បកម្មក៏អាចបង្កគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់ បរិស្ថានផងដែរ ជាពិសេសនៅក្បែរ ឬនៅក្នុងបឹងទឹកធម្មជាតិ ដូចជា ទន្លេ ស្ទឹង ឬតំបន់ឆ្នេរសមុទ្រ ដែលបានប្រើប្រាស់ថ្នាំអង់ទីប៊ីយ៉ូទិក អាហារសិប្បនិម្មិត អាចនាំឱ្យកើតមានការបំពុល បណ្តាលឱ្យមានការរីករាលដាលជំងឺ បំពុលបរិស្ថានជីវៈចម្រុះ និងបំពុលប្រភពទឹកផងដែរ។ ជាឧទាហរណ៍ ២០ ភាគរយនៃអ្នកធ្វើវារីវប្បកម្មនៅក្នុងទន្លេបានប្រើសារជាតុសម្លាប់សត្វល្អិត ឬជីកសិកម្ម ដែលជាភាពគំរាមកំហែងយ៉ាងខ្លាំងដល់ប្រព័ន្ធអេកូឡូស៊ី និងប្រព័ន្ធជីវចម្រុះ ។
នៅកម្ពុជា ប្រមាណ ៩០ ភាគរយនៃអ្នកធ្វើវារីវប្បកម្ម មិនបានប្រើថ្នាំសម្លាប់សត្វល្អិត ឬអង់ទីប៊ីយ៉ូទិកនោះទេ (តារាងទី ៤)។ ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតគឺគេសង្កេតឃើញថា បុរសមានអត្រាខ្ពស់ជាងស្ត្រី (ស្ត្រី៧ ភាគរយ និង បុរស១០ ភាគរយ ប្រើតែថ្នាំសម្លាប់សត្វល្អិត ខណៈមានតែ ២ភាគរយ ប្រើទាំងថ្នាំសម្លាប់សត្វល្អិត និងសារជាតុអង់ទីប៊ីយ៉ូទិក) (រូបភាពទី ៥៩)។ ជាធម្មតា ការប្រើប្រាស់ចំណីចិញ្ចឹមគឺមានយ៉ាងទូលំទូលាយ ស្ត្រីមានបានប្រើប្រាស់ខ្ពស់ជាងបុរស (ស្ត្រី៧៣ ភាគរយ បើប្រៀបធៀបទៅនឹង បុរស៦៦ ភាគរយ) (រូបភាពទី ៦០)។ ការប្រើប្រាស់ចំណី (ចំណីត្រីជាធម្មតាផលិតមកពីម្សៅត្រី និងប្រេងត្រីដែលរួមចំណែដល់ការនេសាទ) នៅក្នុងស្រះចិញ្ចឹម ប្រសិនបើចំណីនៅសល់មិនត្រូវបានបំបាត់ឱ្យទាន់ពេលវាអាចរលួយក្នុងស្រះចិញ្ចឹម វាបណ្តាលឱ្យមានជំងឺសត្វចិញ្ចឹម។ ដូច្នេះការប្រើប្រាស់ចំណីអាចនាំឱ្យមានការប្រើប្រាស់អង់ទីប៊ីយ៉ូទិកកាន់តែច្រើន ដើម្បីការពារជំងឺ បន្ថែមនាំឱ្យបរិស្ថានជុំវិញទទួលរងការខូចខាត។ ទោះបីជាការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងអង់ទីប៊ីយ៉ូទិក ការធ្វើវារីវប្បកម្មនៅកម្ពុជាមានអត្រាទាប គឺជាសញ្ញាល្អដែលមិនប៉ះពាល់ដល់បរិស្ថាន ប៉ុន្តែការប្រើប្រាស់ចំណីយ៉ាងទូលំទូលាយនៅតែជាបញ្ហានាំឱ្យព្រួយបារម្ភ។

ក្នុងបរិបទនៃការប្រើប្រាស់ថ្នាំអង់ទីប៊ីយោទិច ថ្នាំសម្លាប់សត្វល្អិត និងចំណី ឥរិយាបថនៃការគ្រប់គ្រងវារីវប្បកម្មរបស់ស្ត្រី និងបុរសបានបង្កការគំរាមកំហែងដល់បរិស្ថានយ៉ាងខ្លាំង។ នេះជាការពិតជាពិសេសសម្រាប់អ្នកដែលប្រកបរបរវារីវប្បកម្មនៅតាមដងទន្លេ ដែលការប្រើប្រាស់សារជាតុគ្រោះថ្នាក់ និងមានឥទ្ធិពលបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ។ ទោះជាយ៉ាងណាក៏ដោយ ការសម្រេចចិត្តជុំវិញការគ្រប់គ្រងវារីវប្បកម្ម និងការប្រើប្រាស់សមាសធាតុទាំងនេះមិនតែងតែធ្វើឡើងដោយស្ត្រី និងបុរសដែលធ្វើសកម្មភាពវារីវប្បកម្មទាំងនេះទេ។ ជាឧទាហរណ៍ ស្ត្រី ៧៥ភាគរយប៉ុណ្ណោះដែលប្រកបរបរវារីវប្បកម្មធ្វើការសម្រេចចិត្តដោយខ្លួនឯងអំពីការប្រើប្រាស់សារជាតុទាំងនេះ បើធៀបនឹងបុរស ៨៩ ភាគរយ (រូបភាព ៦១) ។ ក្នុងចំណោមករណីទាំងអស់ មានចំនួន ៦ ភាគរយដែលស្ត្រីបានរាយការណ៍ថាម្ចាស់ស្រះ បានសម្រេចចិត្តជំនួសគាត់ ខណៈដែលមានចំនួន ១៩ ភាគរយ ការសម្រេចចិត្តត្រូវបានធ្វើឡើងដោយប្តី ឬសមាជិកគ្រួសារផ្សេងទៀត។

## តារាងទី ៤៖ សមាមាត្រនៃអ្នកធ្វើវារីវប្បកម្មតាមទីតាំង តាមភេទនៃអ្នកអនុវត្ត និងថាតើការអនុវត្តបានបង្កការគំរាមកំហែងដល់បរិស្ថានឬទេ" (ភាគរយ)

| ទីតាំងការធ្វើវារីវប្បកម្ម | គ្រប់គ្រងដោយស្ត្រី | គ្រប់គ្រងដោយបុរស | ប្រើថ្នាំសម្លាប់សត្វល្អិត | | ប្រើអង់ទីប៊ីយោទិច | | ប្រើចំណី | |
|---|---|---|---|---|---|---|---|---|
| | | | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស |
| លើដី | ៩៨ | ៩៥ | ៨ | ១០ | ២ | ១ | ៧៣ | ៦៤ |
| លើទឹក | ២ | ៥ | ៥០ | ៤៦ | ១៧ | ៨ | ៩២ | ៩២ |
| ផ្សេងទៀត | ០.៥ | ១ | ០ | ០ | ០ | ០ | ២៤ | ៥៩ |

សម្គាល់៖ មិនមានទិន្នន័យត្រូវបានកត់ត្រាសម្រាប់ស្ត្រី និងបុរសដែលមានសកម្មភាពចិញ្ចឹមត្រីនៅក្នុងសមុទ្រទេ។ ចំនួនទិន្នន័យសម្រាប់ស្ត្រី និងបុរសដែលមានសកម្មភាពចិញ្ចឹមត្រីនៅក្នុងទន្លេ និងតំបន់ផ្សេងៗ គឺតិចជាង ១០០ ដូច្នេះ តម្លៃទិន្នន័យសម្រាប់ទីតាំងទាំងនេះគួរត្រូវបានបកស្រាយដោយប្រុងប្រយ័ត្ន។

## រូបភាពទី ៥៩៖ សមាមាត្រអ្នកដែលប្រើថ្នាំសម្លាប់សត្វល្អិត និង/ឬថ្នាំអង់ទីប៊ីយោទិចក្នុងការធ្វើវារីវប្បកម្ម បែងចែកតាមភេទ (ភាគរយ)




## រូបភាពទី ៦០៖ សមាមាត្រអ្នកដែលប្រើប្រាស់ចំណីក្នុងការធ្វើវារីវប្បកម្ម បែងចែកតាមភេទ (ភាគរយ)



រូបភាពទី ៦១៖ សមាមាត្រអ្នកធ្វើការសម្រេចចិត្តគ្រប់គ្រងវារីវប្បកម្ម បែងចែកតាមភេទ (ភាគរយ)




រូបភាពទី ៦២៖ សមាមាត្រអ្នកធ្វើសេចក្តីសម្រេចចិត្តគ្រប់គ្រងវារីវប្បកម្មបង្កការគំរាមកំហែងដល់ធនធានធម្មជាតិ បែងចែកតាមភេទ (ភាគរយ)




## សកម្មភាពអនុវត្តន៍នេសាទរបស់បុរស បានបង្កផលប៉ះពាល់ដល់បរិស្ថានខ្លាំងជាងរបស់ស្ត្រី

នៅកម្ពុជា ស្ត្រី ១០ភាគរយ និង បុរស ៣២ភាគរយ បានអនុវត្តសកម្មភាពនេសាទ ឬប្រមូលផលផល ដើម្បីប្រើប្រាស់សម្រាប់ជីវភាពប្រចាំថ្ងៃ ប្រាក់ឈ្នួល ប្រាក់ចំណេញ កំសាន្ត បែបប្រពៃណី ឬហេតុផលផ្សេងទៀត។ ខណៈបុរសភាគច្រើនធ្វើនេសាទក្នុងសមុទ្រ ស្ត្រីវិញភាគច្រើនបានប្រមូលសត្វសមុទ្រ ឬស្លែតាមឆ្នេរឬក្បែរឆ្នេរ។ ដូច្នេះវិធីសាស្ត្រនេសាទរបស់គាត់មានភាពខុសគ្នា ដូចជាឥទ្ធិពលទៅលើប្រព័ន្ធអេកូស៊ីឡូស៊ីផងដែរ។ ជាឧទាហរណ៍ ស្ត្រី ៥២ ភាគរយ និង បុរស២៨ ភាគរយ បានចូលរួមក្នុងការប្រមូលផលនេសាទឬទម្រង់ផ្សេងទៀតនៃការប្រមូលផលនេសាទ ជាទូទៅចាត់ទុកថាជាការអនុវត្តប្រកបដោយនិរន្តរភាពជាង (រូបភាព ៦៣)។ ម៉្យាងវិញទៀត បុរសមានអត្រាច្រើនជាងស្ត្រីក្នុងការប្រើ ស្បៃមង អួន ដើម្បីនេសាទ (វិធីសាស្ត្រនេសាទដែលប្រើយ៉ាងទូលំទូលាយបំផុតក្នុងចំណោមបុរស ៥៧ ភាគរយ)។ ស្រដៀងគ្នានេះដែរ បុរសបានប្រើសន្ទូចរនង ដែលជាវិធីសាស្ត្រនេសាទដែលខ្សែជាមួយទំពក់ផ្លែ ជួនកាលមានប្រវែងរាប់គីឡូម៉ែត្រ ដើម្បីចាប់យកសត្វគោលដៅ និងប្រភេទសត្វមិនគោលដៅ។ គឺជាការអនុវត្តដែលបំផ្លិចបំផ្លាញខ្លាំងនៅពេលចាប់បានបរិមាណច្រើននៃប្រភេទសត្វអភិរក្ស។

បើប្រៀបធៀបទៅនឹងប្រជាជនក្នុងប្រទេសផ្សេងទៀត ប្រជាជនកម្ពុជានៅតែពឹងផ្អែកយ៉ាងសំខាន់លើការនេសាទបែបបុរាណ ដូចជាសំណាញ់ និងឈ្នាង( wedge-shaped scoop baskets) ដែលអាចកំណត់គោលដៅនេសាទបានប្រសើរជាងមុន ហើយជាទូទៅមិនសូវប៉ះពាល់ដល់ជីវិតសត្វសមុទ្រ និងប្រព័ន្ធអេកូឡូស៊ី។ ការពឹងផ្អែកលើវិធីសាស្ត្រប្រពៃណីទាំងនេះគឺមានសារៈសំខាន់ក្នុងការអភិរក្សធនធានសមុទ្រ ទន្លេ និងធនធានជលផលទាំងមូលរបស់ប្រទេស។ ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់វិធីសាស្ត្របុរាណដែលបានបំផ្លាញច្រើនជាងនេះ ដូចជាទម្រង់ផ្សេងៗនៃលបដាក់ត្រីនៅតែបន្តប្រើប្រាស់ទូទៅ ។ សរុបមក ស្ត្រីប្រមាណ ៦២ ភាគរយ និងបុរស ៧៤ ភាគរយនៅកម្ពុជា ប្រើប្រាស់វិធីសាស្ត្រនេសាទដែលមានការបំផ្លាញខ្លាំងយ៉ាងតិចមួយប្រភេទ[២០]ជាប្រចាំ។ ដោយសារការធ្វើនេសាទរបស់បុរសជាធម្មតាមានទំហំធំជាងស្ត្រី បុរសក៏ទំនងជាមើលព័ត៌មានផ្លូវការទាក់ទងនឹងស្ថានភាពស្តុកត្រី ដើម្បីទាំងកំណត់គោលដៅនេសាទ និងដើម្បីការពារការនេសាទហួសកម្រិតនៃប្រភេទសត្វដែលធ្វើអាជីវកម្មហួសកម្រិត ឬជិតផុតពូជ។ តាមការប៉ាន់ស្មាន បុរស៥ ភាគរយ និង ស្ត្រី២ ភាគរយ បានមើលព័ត៌មានស្ថានភាពស្តុកត្រីជាទៀងទាត់ (រូបភាព ៦៤) ។ ទោះយ៉ាងណាក៏ដោយ មានតែបុរស ១ ភាគរយ និងស្ត្រី ០,៤ ភាគរយប៉ុណ្ណោះដែលប្រកបរបរនេសាទតាមសមុទ្រ បានធ្វើរបាយការណ៍ស្តីពីផលនៃការនេសាទសរុបបញ្ជូនវាទៅអាជ្ញាធរ។នេះគឺជាការអនុវត្តដ៏សំខាន់មួយសម្រាប់ការគ្រប់គ្រងប្រកបដោយជោគជ័យនៃស្ថានភាពស្តុកត្រី និងការអភិរក្សសមុទ្រ ទន្លេ និងទម្រង់ផ្សេងៗទៀតនៃជីវចម្រុះក្នុងទឹក ។

[២០] ទាំងនេះរាប់បញ្ចូលទាំង សំណាញ់អួន អួនអូស សំណាញ់ សន្ទូច អន្ទាក់នេសាទ (រួមទាំង FADs) ។

## រូបភាព៦៣៖ សមាមាត្រ ចំនួនប្រជាជននេសាទ/ការប្រមូលផលនេសាទ តាមភេទ និងឧបករណ៍សាទ(ភាគរយ)




សម្គាល់៖មិនមានភាពខុសគ្នារវាងស្ត្រី និងបុរសក្នុងន័យស្ថិតិកម្រិតជឿជាក់ α=0,0៥ សម្រាប់ ប្រភេទ Trawling និងផ្សេងទៀត

## រូបភាពទី ៦៤៖ សមាមាត្រនៃអ្នកដែលគាំទ្រការត្រួតពិនិត្យស្តុកត្រី ដោយមើលស្ថានភាពស្តុកត្រី និងការរាយការណ៍អំពីត្រីតាមភេទ (ភាគរយ)



ការបំពុលទឹក ជាពិសេសការបំពុលប្លាស្ទីកដែលមានប្រភពចេញពីឧបករណ៍នេសាទដែលគេបោះបង់ចោល គឺជាបញ្ហាសំខាន់ដែលរួមចំណែកយ៉ាងធាប់រហ័សដល់ការបាត់បង់ជីវចម្រុះក្នុងសមុទ្រ និងក្នុងទឹកផ្សេងទៀត រួមទាំងការបាត់បង់ផ្កាថ្ម។ ក្នុងចំណោមប្រជាជនកម្ពុជាដែលប្រកបរបរនេសាទ ឬប្រមូលផលនេសាទ បុរសត្រូវទទួលខុសត្រូវយ៉ាងសំខាន់ចំពោះការបំពុលប្រភេទនេះ ដោយសារគាត់បានចូលរួមក្នុងការនេសាទមិនសមាមាត្រដែលប្រើសំណាញ់អួនធំៗ។ ក្នុងចំណោមមនុស្សទាំងអស់ដែលប្រកបរបរនេសាទ ប្រហែល ៦០ ភាគរយនាំយកឧបករណ៍នេសាទដែលបានប្រើរួច ទៅកាន់កន្លែងកែច្នៃឡើងវិញ ឬកន្លែងណាមួយដែលវាអាចប្រើឡើងវិញបាន (រូបភាព ៦៥)។ គួរឱ្យព្រួយបារម្ភ មានរហូតដល់ ៤០ ភាគរយនៅតែបោះចោលឧបករណ៍របស់ពួកគេនៅលើដី និង ១ ភាគរយបោះវាទៅក្នុងសមុទ្រ ឬក្នុងទឹកផ្សេងទៀត។ ការដោះស្រាយបញ្ហាឧបករណ៍នេសាទដែលគេបោះចោលគឺមានសារៈសំខាន់ណាស់ក្នុងការធ្វើឱ្យជីវចម្រុះសមុទ្រ និងប្រព័ន្ធអេកូឡូស៊ីងើបឡើងវិញ។

**រូបភាព ៦៥៖ សមាមាត្រអ្នកនេសាទ/ប្រមូលផលនេសាទ បានចូលរួមកែច្នៃ ឬប្រើប្រាស់ឧបករណ៍ចាស់ឡើងវិញ បែងចែកតាមភេទ (ភាគរយ)**



## ស្ត្រីមានច្រើនជាងបុរសដែលបានអនុវត្តន៍ប្រកបដោយនិរន្តរ៍ភាពសម្រាប់ការអនិរក្សព្រៃធម្មជាតិ

ព្រៃឈើធម្មជាតិ វាលស្មៅរុក្ខជាតិ និងទម្រង់ផ្សេងទៀតនៃដីព្រៃធម្មជាតិ ដើរតួយ៉ាងសំខាន់សម្រាប់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។ ស្ត្រី ២ ភាគរយ និងបុរស ៤ ភាគរយពឹងផ្អែកលើកន្លែងទាំងនេះ និងមានតិចជាង ១ ភាគរយ ធ្វើសកម្មភាពនៅក្នុងព្រៃឈើធម្មជាតិ និងដីព្រៃ ដើម្បីប្រាក់ចំណូលចម្បងរបស់គាត់។ ដូច្នេះផលិតផលព្រៃឈើមានសារៈសំខាន់សម្រាប់ជីវភាពរស់នៅ ប្រពៃណី និងវប្បធម៌ ប៉ុន្តែមនុស្សជាច្រើនមិនបានប្រើប្រាស់ការអនុវត្តប្រកបដោយនិរន្តរភាពនៅពេលទាញយកផលិតផលពីព្រៃឈើ។ ករណីលើកលែងអាចជាការអនុវត្តន៍ការផ្លាស់ទីទីតាំងឬពេលវេលាចិញ្ចឹមសត្វ ដើម្បីឱ្យព្រៃអាចស្តារឡើងវិញបាន ដែលស្ត្រីចំនួន ៧៧ ភាគរយ និងបុរសចំនួន ៦៩ ភាគរយបានអនុវត្តន៍។ផ្ទុយទៅវិញ មានស្ត្រីតែចំនួន ២៤ភាគរយ និងបុរស ២០ ភាគរយប៉ុណ្ណោះដែលអនុវត្តការដាំឡើងវិញ និងស្តារឡើងវិញបន្ទាប់ពីការប្រមូលផលរួច និងមានតែស្ត្រី ២១ ភាគរយ និងបុរស ១៥ ភាគរយប៉ុណ្ណោះដែលអនុវត្តន៍ការបញ្ឈប់ការប្រមូលផលក្នុងរយៈពេលណាមួយ ឬប្រមូលតិចតួចជាបន្តបន្ទាប់ (រូបភាព៦៦)។ អ្វីដែលគួរឱ្យព្រួយបារម្ភគឺ មានតែស្ត្រី ១២ ភាគរយ និងបុរស ១០ ភាគរយប៉ុណ្ណោះដែលអនុវត្តន៍ការជ្រើសរើសគំរូសត្វឬរុក្ខជាតិ ដោយគិតទៅលើការថែទាំនិងការរក្សាទុក (ឧទាហរណ៍ ការរក្សាទុកពង កូនសត្វ កូនបក្សី ឬរុក្ខជាតិដែលកំពុងលូតលាស់ និងចៀសវាងការប្រមូលសត្វឬរុក្ខជាតិទាំងអស់នៃប្រភេទណាមួយ ដើម្បីធានាថាអាចជំនួសជំនាន់ក្រោយបាន)។ ការលើកកម្ពស់និងអនុវត្តន៍ជាប្រចាំនូវវិធីសាស្ត្រទាំងនេះអាចជួយស្តារឡើងវិញនូវប្រភេទរុក្ខជាតិ និងសត្វ បង្កើនឱកាសសេដ្ឋកិច្ច និងជម្រុញឱ្យព្រៃនាំអាចរក្សាបាននូវស្ថានភាពសម្បូរបែបនិងប្រកបដោយនិរន្តរភាពផងដែរ។

**រូបភាពទី ៦៦៖ សមាមាត្រនៃអ្នកប្រើប្រាស់ព្រៃឈើដែលប្រើប្រាស់ការអនុវត្តការគ្រប់គ្រងប្រកបដោយនិរន្តរភាពតាមភេទ (ភាគរយ)**



## បុរសនៅកម្ពុជាមានអត្រាចូលរួមក្នុងសេដ្ឋកិច្ចបៃតងខ្ពស់ជាងស្ត្រី ការធ្វើឱ្យស្ត្រីមានជំនាញគឺជាចំណុចសំខាន់សម្រាប់ការផ្លាស់ប្តូរទៅរកអនាគតបៃតងដែលមានតុល្យភាព

នៅក្នុងខណៈដែលរដ្ឋាភិបាលកម្ពុជាកំពុងខិតខំផ្លាស់ប្តូរទៅសេដ្ឋកិច្ចដែលមានការបញ្ចេញឧស្ម័នតិច បន្ថយការបំពុល និងថែរក្សាធនធានធម្មជាតិ ការចូលរួមរបស់ស្ត្រី និងបុរសតាមរយៈការងាររបស់គាត់ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចបាននូវគោលដៅទាំងនេះ។ នៅកម្ពុជាបច្ចុប្បន្ន ស្ត្រីប្រមាណជា ៣ភាគរយ និងបុរស៤ភាគរយមានសេដ្ឋកិច្ចបៃតងយ៉ាងហោចណាស់មួយ(ឬតាមរយៈសកម្មភាពសេដ្ឋកិច្ចចម្បង ឬសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំ) គឺជាការងារដែលមានគុណភាព និងរួមចំណែកក្នុងការថែរក្សា ឬស្តារឡើងវិញនូវបរិស្ថាន (រូបភាព ៦៧)។ ក្នុងចំណោម ប្រភេទការងារបៃតងពេញនិយមបំផុតគឺទាក់ទងនឹងការកាត់បន្ថយ និងការដកយកការបំពុល និងឧស្ម័នក្នុងខ្យល់ ដែល ស្ត្រី ០,៩ភាគរយ និងបុរស ១,៥ ភាគរយកំពុងធ្វើការងារ ការផលិតនូវផលិតផលពាក់ពន្ធ័នឹងវិស័យនេះ និងមានស្ត្រី ១,៥ ភាគរយ និងបុរស ១,៨ ភាគរយកំពុងធ្វើការងារដែលពាក់ពន្ធ័នឹងដំណើរការ (រូបភាព ៦៨)។[២១]

ជារួម បុរសមានអត្រាខ្ពស់ជាងស្ត្រីបានចូលរួមក្នុងការងារបៃតង ដែលបានចូលរួមចំណែកទាំងក្នុងកាផលិតទំនិញ និងសេវាកម្មផ្នែកបរិស្ថាន ព្រមទាំងដំណើរការបរិស្ថានផ្សេងៗ ដែលជាផ្នែកធំបំផុតនៃការងារពណ៌បៃតងនៅកម្ពុជា។ ភាពខុសគ្នាធំបំផុតរវាងយេនឌ័រ ជាតម្លៃដាច់ខាត កើតមានក្នុងចំណោមអ្នកមានការងារដែលពាក់ព័ន្ធនឹងដំណើរការកែលម្អប្រសិទ្ធភាពថាមពល និងទឹក ដែលស្ត្រីមានត្រឹមតែ ០,៥ ភាគរយនៃអ្នកមានការងារ ប៉ុន្តែបុរសមានដល់ទៅ ១,៤ ភាគរយ។ វាជាផ្នែកសំខាន់បំផុតមួយសម្រាប់ជំរុញការអភិវឌ្ឍប្រកបដោយចីរភាពផ្នែកបរិស្ថាននៅកម្ពុជា ក្នុងបរិបទដែលមានឥទ្ធិពលធំធេងនៃការប្រែប្រួលអាកាសធាតុ ការបំពុលខ្យល់ និងបញ្ហាខ្វះទឹក នៅតំបន់សំខាន់ៗនៃប្រទេស (រូបភាព ៦៩)។ វិស័យសំខាន់ៗដូចជា កសិកម្ម ព្រៃឈើ និងនេសាទប្រកបដោយចីរភាព នៅតែមានការអភិវឌ្ឍតិចតួច ខណៈពេលដែលវិស័យទាំងនេះ មានត្រឹម០,៧៥ភាគរយនៃប្រជាជនដែលមានការងាររួមចំណែកក្នុងការផលិត (ផលិតផលបរិស្ថាន) និង ១,០៥ភាគរយសម្រាប់ដំណើរការបរិស្ថាន។ ស្រដៀងគ្នានេះផងដែរ ការងារផ្នែកការពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិ ក៏បានទាក់ទាញអ្នកមានការងារត្រឹមតែ ០,៨ ភាគរយសម្រាប់ផ្នែកផលិតកម្ម និង ១,១ ភាគរយសម្រាប់ផ្នែកដំណើរការ។ នៅកម្ពុជា បញ្ហាប្រឈមដ៏សំខាន់ៗជាច្រើនដែលពាក់ព័ន្ធនឹងការប្រើប្រាស់ជីគីមី ថ្នាំបាញ់សត្វល្អិតលើសកម្រិត រួមទាំងការកាប់បំផ្លាញព្រៃឈើ និងការនេសាទលើសកំណត់ការជម្រុញការផ្លាស់ប្តូរទៅអនុវត្តន៍ប្រកបដោយចីរភាពសម្រាប់កសិករ អ្នកនេសាទ និងអ្នកប្រមូលផល ត្រូវបានចាត់ទុកជាៈអាទិភាពសំខាន់។

ដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័ននៅកម្ពុជា និងការថែរក្សាបរិស្ថានជាទូទៅ ការផ្លាស់ប្តូរទៅរកការងារបៃតងរបស់បុរស និងស្ត្រី គឺមានសារៈសំខាន់យ៉ាងខ្លាំង។ ទោះជាយ៉ាងណា បច្ចុប្បន្ន នៅតែ

---

២១ ប្រជាពលរដ្ឋជាច្រើនមានការងារធ្វើទាំងការផលិតផល និងដំណើរការសម្រាប់ការងារពណ៌បៃតងក្នុងប្រភេទដូចគ្នា។ ដូច្នេះ មនុស្សម្នាក់អាចត្រូវបានគេចាត់ទុកថាមានការងារពណ៌បៃតងច្រើនជាងមួយបាន ហើយផលបូកនៃប្រភេទទាំងអស់អាចមិនស្មើនឹងចំនួនសរុបនៃមនុស្សដែលមានការងារពណ៌បៃតងនោះទេ។

មានឧបសគ្គសំខាន់មួយចំនួនដែលអាចជាហេតុធ្វើឱ្យស្ត្រីមិនចូលរួមក្នុងការងារទាំងនេះ។ ឧទាហរណ៍ ស្ត្រីមានអត្រាចូលរួមរៀនវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ទាបជាងបុរស ដែលធ្វើឱ្យស្ត្រីមិនបានត្រៀមខ្លួនគ្រប់គ្រាន់សម្រាប់ការងារផ្នែកវិស្វកម្មដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័ន និងការងារផ្នែកថាមពលកកើតឡើងវិញ និងបច្ចេកវិទ្យា ដែលជាផ្នែកស្នូលនៃការងារពណ៌បៃតង។ នៅកម្ពុជា មានតែ ១៧ ភាគរយប៉ុណ្ណោះនៃនិស្សិតបញ្ចប់ការសិក្សាផ្នែក STEM ជាស្ត្រី[២២]។ បើទោះបីស្ត្រីបានសិក្សាជំនាញទាំងនេះក៏ដោយ ទំនៀមទំលាប់សង្គម និងវប្បធម៌ការងារអាចជំរុញឱ្យគាត់បោះបង់អាជីពទាំងនោះ។ លើសពីនេះ ស្ត្រីក៏មានសិទ្ធទទួលបានប្រភពហិរញ្ញវត្ថុតិចជាងបុរសផងដែរ ដែលអាចជាឧបសគ្គសម្រាប់ការចាប់ផ្តើមអាជីវកម្មបៃតងរបស់គាត់។ នៅកម្ពុជា បុរសមានអត្រាមានគណនីធនាគារ ធានារ៉ាប់រងជីវិត និងប្រាក់បៀវត្សន៍ខ្ពស់ជាងស្ត្រី (រូបភាព ៧០)។ ស្ថានភាពនេះបានដាក់កម្រិតសមត្ថភាពស្ត្រីក្នុងការចូលរួមបង្កើតសហគ្រិនភាព ឬវិនិយោគលើការច្នៃប្រឌិតថ្មីៗ។ ការដោះស្រាយឧបសគ្គទាំងនេះគឺមានសារៈសំខាន់ដើម្បីធានាបាននូវការផ្លាស់ប្តូរដែលមានតុល្យភាពឆ្ពោះទៅរកសេដ្ឋកិច្ចមានការបញ្ចេញឧស្ម័នតិច។

**រូបភាព ៦៧៖ សមាមាត្រនៃប្រជាជនមានការងារធ្វើក្នុងការងារសេដ្ឋកិច្ចបៃតងក្នុងខែមុន បែងចែកតាមភេទ និងបានចំណាយពេលវេលាលើការងារនេះ (ភាគរយ)**




សម្គាល់៖ ការវិភាគនេះលើបុគ្គលអាយុ ១៨ ឬច្រើនជាង ដែលសកម្មភាពសេដ្ឋកិច្ចសំខាន់ ឬសកម្មភាពសេដ្ឋកិច្ចរងរបស់គាត់ ត្រូវបានចាត់ថាជាការងារពណ៌បៃតង។ មិនមានភាពខុសគ្នារវាងស្ត្រី និងបុរសក្នុងន័យស្ថិតិ នៅកម្រិត $\alpha$ = 0.0៥ សម្រាប់ប្រភេទ "ចំណាយពេលលើស ៥០%" លើផលផលិតផ្នែកបរិស្ថាន។

[22] ទិន្នន័យចុងក្រោយដែលមានស្រាប់គឺសម្រាប់ឆ្នាំ ២០១៥។ Gender Data Portal របស់ ធនាគារពិភពលោក (World Bank).

## រូបភាពទី ៦៨៖ សមាមាត្រប្រជាជនដែលមានការងារធ្វើការងារបៃតង ទាក់ទងនឹងការផលិតនូវផលិតផលបរិស្ថាន បែងចែកតាមភេទ




សម្គាល់៖ ការវិភាគនេះ លើបុគ្គលអាយុ ១៨ ឆ្នាំឬច្រើនជាងដែលសកម្មភាពសេដ្ឋកិច្ចសំខាន់ ឬសកម្មភាពសេដ្ឋកិច្ចរងរបស់គាត់ ត្រូវបានចាត់ថាជាការងារពណ៌បៃតង។

## រូបភាពទី៦៩៖ សមាមាត្រនៃចំនួនប្រជាជនដែលបានធ្វើការងារបៃតង ទាក់ទងនឹងដំណើរការបរិស្ថាន តាមភេទ




សម្គាល់៖ ការវិភាគនេះ បុគ្គលអាយុ ១៨ ឆ្នាំឬច្រើនជាង ដែលសកម្មភាពសេដ្ឋកិច្ចចម្បង ឬសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំ ត្រូវបានចាត់ថាជាការងារពណ៌បៃតង។មិនមានភាពខុសគ្នារវាងស្ត្រី និងបុរសមិនមានន័យស្ថិតិសម្រាប់ប្រភេទ "ការស្រាវជ្រាវ ការធ្វើផែនការ ការថែទាំ និងការត្រួតពិនិត្យបច្ចេកវិទ្យា" និង "បច្ចេកវិទ្យាផ្សេងៗដែលមានទំនាក់ទំនងជាមួយបរិស្ថាន

## រូបភាពទី ៧០៖ សមាមាត្រនៃចំនួនប្រជាជន ដែលជាម្ចាស់តែម្នាក់ឯង ឬរួមគ្នារូបភាពលើទ្រព្យសម្បត្តិហិរញ្ញវត្ថុ បែងចែកតាមភេទ




សម្គាល់៖មិនមានភាពខុសគ្នារវាងស្ត្រី និងបុរសក្នុងន័យស្ថិតិសំខាន់នៅកម្រិត α = ០.០៥ សម្រាប់ប្រភេទ "គណនីមីក្រូហិរញ្ញវត្ថុ" និង "ទ្រព្យសម្បត្តិហិរញ្ញវត្ថុផ្សេងទៀត"។ ចំនួនទិន្នន័យសម្រាប់កម្មវិធីសន្សំមានតិចជាង ៣០ ហើយដោយឡែកហេតុនេះ មិនបានបង្ហាញក្នុងនេះទេ។

## ភាពខុសគ្នារវាងយេនឌ័រក្នុងការកាន់កាប់ទ្រព្យសម្បត្តិ នាំឱ្យមានឥទ្ធិពលខុសគ្នាលើការអភិរក្ស និងការបំផ្លាញបរិស្ថាន

បុរសមានការងារជាប់ពាក់ព័ន្ធនឹងវិស័យកសិកម្ម មានអត្រាខ្ពស់ជាងស្ត្រីក្នុងការកាន់កាប់នង្គ័ល រទេះ និងទ្រព្យបរិក្ខារកសិកម្មផ្សេងទៀត (រូបភាព ៧១)។ ការប្រើប្រាស់ម៉ាស៊ីនខ្នាតធំនានា ដូចជា ត្រាក់ទ័រ រទេះ និងឧបករណ៍ខ្នាតធំផ្សេងទៀតៗ ជានាបង្កើនទិន្នផលខ្ពស់បើប្រៀបធៀបទៅនឹងពេលវេលា និងធនធានដែលបានវិនិយោគ ព្រមទាំងការអនុវត្តធ្វើការកសិកម្មបានកាន់តែសកម្ម និងមានប្រសិទ្ធភាព។ ទោះយ៉ាងណាការប្រើប្រាស់ឧបករណ៍ទាំងនេះមានឥទ្ធិពលខ្ពស់លើការបំផ្លាញបរិស្ថាន ហើយអាចធ្វើឱ្យបញ្ហានេះកាន់តែធ្ងន់ធ្ងរឡើង បើការអនុវត្តន៍ការធ្វើកសិកម្មត្រូវគ្មានវិធានការអភិរក្សបរិស្ថានដ៏ចាំបាច់។

កម្មសិទ្ធិលើទ្រព្យសម្បត្តិមានសារៈសំខាន់ ពីព្រោះអ្នកដែលជាម្ចាស់ទ្រព្យអាចលក់វាក្នុងករណីចាំបាច់ ដែលអាចបង្កើនភាពធន់ គួរកត់សម្គាល់ក្នុងចំណោមទ្រព្យសម្បត្តិបរិស្ថានគ្រប់ប្រភេទ ស្ត្រីមានអត្រាតិចជាងបុរស លើកម្មសិទ្ធិ បង្ហាញពីភាពងាយរងគ្រោះរបស់គាត់។ ជាឧទាហរណ៍ ភាពខុសគ្នាខាងយេនឌ័រក៏មានទាក់ទងនឹងកម្មសិទ្ធិឧបករណ៍នេសាទធំផងដែរ បុរសមានច្រើនជាងស្ត្រីលើកម្មសិទ្ធិឧបករណ៍នេសាទ ដូចជាអួនអូស និងអួនអូសក្រោមសមុទ្រ ដែលអាចនេសាទប្រមូលផលបានច្រើនដោយគ្មានការជ្រើសរើស ដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើជីវចម្រុះសមុទ្រ (រូបភាព៧២)។ ការចូលរួមមិនសមាមាត្ររបស់បុរសនៅក្នុងសកម្មភាពប្រមូលផលដែលពឹងផ្អែកខ្លាំងទាំងនេះ បានរួមចំណែកដល់ការវិចវិលនៃសមុទ្រ អាចប៉ះពាល់ដល់ជីវភាពរបស់ស្ត្រីដោយផ្ទាល់ ដោយសារស្ត្រីតែងតែពឹងផ្អែកលើការប្រមូលផលតាមឆ្នេរសមុទ្រ។ ស្ត្រីមានការលំបាកជាងបុរសក្នុងការប្តូរទីតាំង

ដើម្បីទប់ទល់នឹងការថយចុះបរិមាណត្រីដែលបណ្តាលឱ្យបាត់បង់ជីវចម្រុះក្នុងទឹក ដោយ មួយផ្នែកធំដោយការនេសាទហួសកម្រិត និងការប្រើប្រាស់ឧបករណ៍មិនជ្រើសរើស។

## រូបភាព ៧១៖ ភាគរយប្រជាជនដែលប្រកបអាជីវកម្មកសិកម្ម និងកាន់កាប់ទ្រព្យសម្បត្តិកសិកម្មធំៗ ផ្ទាល់ខ្លួនឬរួមគ្នា បែងចែកតាមភេទ




ចំណាំ៖ ភាពខុសគ្នារវាងស្ត្រី និងបុរស គឺមិនមានសារៈសំខាន់តាមស្ថិតិនៅ α = 0,0៥ សម្រាប់អ្នកដែលមានកម្មសិទ្ធិផ្តាច់មុខនៃម៉ាស៊ីនច្រូតកាត់ និងសម្រាប់អ្នកដែលមានកម្មសិទ្ធិរួមគ្នានៃប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធចំណីស្វ័យប្រវត្តិ និងម៉ាស៊ីនកិនស្រូវ។

## រូបភាព៧២៖ សមាមាត្រប្រជាជនដែលចូលរួមក្នុងការធ្វើវារីវប្បកម្ម ការធ្វើនេសាទ ឬការប្រមូលផលពីសមុទ្រ ដែលកាន់កាប់ឧបករណ៍នេសាទធំៗដោយខ្លួនឯង ឬរួមជាមួយអ្នកដទៃ បែងចែកតាមភេទ។

### សិទ្ធិម្នាក់ឯង




### កម្មសិទ្ធិរួមគ្នា




សម្គាល់: មិនមានទិន្នន័យសម្រាប់ប្រភេទ "រ៉ាដា" និង "ប្រព័ន្ធទំនាក់ទំនងនៅលើទូក" ទេ ដូច្នេះ ប្រភេទទាំងនេះមិនត្រូវបានបង្ហាញក្នុងគំនូសតាងនេះឡើយ។

## ការកាន់កាប់ទ្រព្យសម្បត្តិអនុញ្ញាតឲ្យស្ត្រីជាច្រើនមានសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងបរិស្ថាន

ជារួម បុរសមានអត្រាខ្ពស់ជាងស្ត្រីក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងបញ្ហាបរិស្ថាន ពាក់ព័ន្ធនឹងសកម្មភាពកសិកម្ម និងការប្រតិបត្តិការដាំដុះ។ តាមការប៉ាន់ស្មាន បុរសប្រមាណ ៩៤ ភាគរយ បានបញ្ជាក់ថា គាត់បានធ្វើសេចក្តីសម្រេចផ្ទាល់ខ្លួន(ដោយខ្លួនឯងឬរួមគ្នា) ទាក់ទងនឹងការទិញផលិតផលកសិកម្ម និងចំនួនដូចគ្នា បុរសក៏បានធ្វើសេចក្តីសម្រេចទាក់ទងនឹងការលក់ផលិតផលទាំងនោះផងដែរ។ អត្រានេះសម្រាប់ស្ត្រីមានចំនួន ៩០ ភាគរយសម្រាប់ការធ្វើសេចក្តីសម្រេចទាក់ទងនឹងការទិញផលិតផលកសិកម្ម និង ៩២ភាគរយសម្រាប់ការលក់ផលិតផល(រូបទី៧៣)។ ភាពខុសគ្នា មានលក្ខណៈស្រដៀងត្រូវបានរកឃើញក្នុង សេចក្តីសម្រេចទាក់ទងនឹងការទិញសត្វចិញ្ចឹមផងដែរ។ បើទោះបីជាប្រពៃណីសង្គម ភាពខុសគ្នារវាងអាយុដៃគូ កម្រិតការអប់រំ និងស្ថានភាពការងារ ជាធាតុសំខាន់ៗដែលប៉ះពាល់ដល់ការធ្វើសម្រេចចិត្ត និងអំណាចរបស់ស្ត្រីជាទូទៅក៏ដោយការកាន់កាប់ទ្រព្យសម្បត្តិបរិស្ថានក៏មានឥទ្ធិពលយ៉ាងសំខាន់ក្នុងការលើកកម្ពស់សិទ្ធិ និងសមត្ថភាពក្នុងការធ្វើសេចក្តីសម្រេចរបស់ស្ត្រីផងដែរ។ ជាឧទាហរណ៍ ស្ត្រីប្រមាណ ៩៧ ភាគរយ ដែលកាន់កាប់ទ្រព្យសម្បត្តិកសិកម្មដូចជា គោយន្ត ត្រាក់ទ័រ និងរទេះ បានធ្វើសេចក្តីសម្រេចដោយខ្លួនឯងទាក់ទងនឹងការទិញផលិតផលកសិកម្ម។ ចំណែកឯស្ត្រីដែលមិនកាន់កាប់ទ្រព្យសម្បត្តិកសិកម្មធំៗវិញ មានតែប្រហែល ៨៣ ភាគរយប៉ុណ្ណោះដែលធ្វើសេចក្តីសម្រេចដោយខ្លួនឯង។ ភាពខុសគ្នាស្រដៀងគ្នានេះដែរ ក៏ត្រូវបានរកឃើញក្នុងការសម្រេចចិត្តផ្សេងៗទៀត ដូចជា ការទិញសត្វចិញ្ចឹម និងការលក់ផលិតផលកសិកម្ម (រូបទី ៧៤)។ដោយសារតែវិយាបទរបស់ស្ត្រី និងបុរសក្នុងការអនុវត្តកសិកម្ម និងនេសាទមានភាពខុសគ្នាយ៉ាងទូលំទូលាយ (ដូចបានឃើញនៅក្នុងផ្នែកមុននៃរបាយការណ៍នេះ) ដោយការអនុវត្តរបស់ស្ត្រីជាទូទៅប្រើប្រាស់ធនធានយ៉ាងប្រុងប្រយ័ត្ន និងថែរក្សាបរិស្ថាន ភាពខុសគ្នានៃកម្មសិទ្ធិលើទ្រព្យសម្បត្តិបរិស្ថាន ដូច្នេះការសម្រេចចិត្តទាក់ទងនឹងការអនុវត្តកសិកម្ម និងដាំដុះ ក៏អាចដើរតួយ៉ាងសំខាន់ក្នុងការអភិរក្ស ឬការរិចរិលនៃប្រព័ន្ធអេកូឡូស៊ីផងដែរ។

**រូបទី ៧៣៖ សមាមាត្រសរុបនៃប្រជាជនដែលធ្វើសេចក្ដីសម្រេច (ដោយខ្លួនឯងឬរួមគ្នា) ទាក់ទងនឹងការទិញ និងការលក់ផលិតផលកសិកម្ម និងសត្វចិញ្ចឹម បែងចែកតាមភេទ**




**រូបទី៧៤៖ សមាមាត្រនៃប្រជាជនដែលធ្វើសេចក្ដីសម្រេចដោយខ្លួនឯងទាក់ទងនឹងក្នុងការទិញ និងការលក់ផលិតផលកសិកម្ម និងសត្វចិញ្ចឹម បែងចែកតាមភេទ និងប្រភេទនៃការកាន់កាប់ (គិតជាភាគរយ)**




ចំណាំ៖ សត្វកសិដ្ឋានរួមមានប្រភេទសត្វធំជាង រួមទាំងគោ ក្របី ពពែ ចៀម ជ្រូក និងសេះ សម្រាប់ប្រភេទ "សម្រេចចិត្តលើការទិញសត្វកសិដ្ឋាន" ការចាត់តាំង "ម្ចាស់ទ្រព្យសកម្ម" បង្ហាញពីគ្រួសាររបស់អ្នកឆ្លើយថាជាម្ចាស់សត្វកសិដ្ឋាន ហើយបុគ្គលនោះគឺជាអ្នកថែរក្សាសត្វតែម្នាក់ឯង ឬរួមគ្នាអំពីសត្វទាំងនេះ ដោយសារការស្ទង់មតិនីមួយៗមិនមាននៅក្នុងគ្រួសារនីមួយៗ។ "សម្រេចចិត្តលើការលក់កសិផល" និង "សម្រេចចិត្តលើការទិញកសិផល និងកសិកម្ម" ទ្រព្យសម្បត្តិផ្ទាល់ខ្លួន" សំដៅលើកម្មសិទ្ធិផ្ដាច់មុខរបស់អ្នកឆ្លើយ ឬរួមនៃណាមួយដូចខាងក្រោមៈ ត្រាក់ទ័រ ភ្ជួររាស់ស្រែ ប្រព័ន្ធធារាសាស្ត្រ រ៉ឺម៉ក ម៉ាស៊ីនបូមទឹក ម៉ាស៊ីនបោកគក់ ម៉ាស៊ីនច្រូតកាត់ ប្រព័ន្ធចំណីដោយស្វ័យប្រវត្តិសម្រាប់បសុសត្វ ប្រព័ន្ធដកលាមកសត្វ ឬឧបករណ៍កសិកម្មធំៗផ្សេងទៀត ។ មិនមានភាពខុសគ្នារវាង ស្ត្រី និងបុរស ឧបករណ៍កសិកម្ម។ សម្រាប់ការសម្រេចចិត្តលើការទិញសត្វកសិដ្ឋាន និងជាម្ចាស់ទ្រព្យសកម្មនៅកម្រិតជឿជាក់ ០,០៥។

## ការអនុវត្តន៍គ្រួសារក៏មានការរួមចំណែកដែរ ក្នុងការអតិរេក្ស និងបំពុលបរិស្ថាន

ការប្រើប្រាស់ប្រភពថាមពលផ្សេងៗ ឥន្ធនៈសម្រាប់ចម្អិនអាហារ និងការអនុវត្តន៍អនាម័យនៅតាមផ្ទះ បានចូលរួមរួមចំណែកក្នុងការបំពុលបរិស្ថានតាមកម្រិតផ្សេងៗគ្នា។ នៅកម្ពុជា មានគ្រួសារ ៩៧ ភាគរយប្រើប្រាស់អគ្គិសនីបណ្តាញ ប្រភពថាមពលសម្រាប់បណ្តាញនេះភាគច្រើន បានមកពីប្រភពមិនអាចកកើតឡើងវិញ។យោងតាមអង្គការអន្តរជាតិសម្រាប់ថាមពលកកើតឡើងវិញ (IRENA) បង្ហាញថា ៤៩ ភាគរយនៃថាមពលអគ្គិសនីសរុបតាមបណ្តាញពឹងផ្អែកលើប្រេងឥន្ធនៈ ១៧ ភាគរយពឹងផ្អែកលើធ្យូងថ្ម និងចំនួននៅសល់ ៣៥ ភាគរយបានមកពីប្រភពថាមពលអាចកកើតឡើងវិញ[២៣] ។ ដូចដែលដឹងហើយ ការប្រើប្រាស់អគ្គិសនីក្នុងគ្រួសារ ក៏ជាធាតុមួយបានចូលរួមចំណែកក្នុងការបំពុលបរិស្ថានផងដែរ ទោះបីមានគ្រួសារច្រើន(៩៧ភាគរយ)ទទួលបាន អត្ថប្រយោជន៍ពីការប្រើប្រាស់អគ្គិសនីតាមបណ្តាញក៏ដោយ ក៏មានគ្រួសារមួយចំនួន ជាពិសេសនៅតំបន់ជនបទ នៅតែពឹងផ្អែកលើម៉ាស៊ីនភ្លើងផ្ទាល់ខ្លួន ចំពោះគ្រួសារនៅតំបន់ជនបទដែលប្រើប្រាស់ថាមពលក្រៅបណ្តាញ ភាគច្រើន(ស្ទើរតែទាំងអស់)ប្រើថាមពលពន្លឺថ្ងៃ(សូឡា) ឬប្រភពថាមពលអាចធ្វើឡើងវិញផ្សេងទៀត (រូបទី៧៥)។

ថ្វីបើមានបរិមាណតិចជាងសកម្មភាពឧស្សាហកម្ម ប៉ុន្តែការប្រើប្រាស់អគ្គិសនីសម្រាប់គ្រួសារដូចជា អំពូលបំភ្លឺ ម៉ាស៊ីនកម្តៅ ម៉ាស៊ីនត្រជាក់ ឬការចម្អិន ត្រូវបានរាប់ថាមានឥទ្ធិពលយ៉ាងសំខាន់លើការបញ្ចេញឧស្ម័ន។ ទូទៅការសម្រេចចិត្តអំពីប្រភេទឥន្ធនៈដែលត្រូវប្រើ គ្រប់គ្រងដោយបុរសភាគច្រើន(រូបទី៧៦)។ ប្រមាណជា ៩៣ ភាគរយនៃបុរសបានរាយការណ៍ថា គាត់ធ្វើសេចក្តីសម្រេចដោយខ្លួនឯង ឬរួមគ្នា ក្នុងការទិញឥន្ធនៈ បើប្រៀបធៀបនឹង ស្ត្រី៨៩ ភាគរយ ។ ការសម្រេចចិត្តទាំងនេះភាគច្រើនត្រូវបានធ្វើរួមគ្នា (បុរស ៨១ភាគរយបានរាយការណ៍ថា គាត់សម្រេចរួមគ្នាលើការទិញឥន្ធនៈ បើប្រៀបធៀបនឹងស្ត្រីចំនួន ៧៨ ភាគរយ)។

**រូបភាព៧៥៖ សមាមាត្រប្រជាជនដែលរស់នៅក្នុងគ្រួសារដែលប្រើថាមពលអគ្គិសនីក្រៅបណ្តាញ (off-grid) មកពីថាមពលកកើតឡើងវិញ បែងចែកតាមភេទ និងទីតាំង (ជាភាគរយ)**




**រូបភាព ៧៦៖ សមាមាត្រប្រជាជនដែលជាធម្មតា សម្រេចចិត្តដោយខ្លួនឯង ឬរួមគ្នា ពាក់ព័ន្ធនឹងការទិញឥន្ធនៈ**

២៣ ទិន្នន័យដែលមានចុងក្រោយបំផុតគឺឆ្នាំ ២០១៦។ សូមមើលកម្រងព័ត៌មានថាមពលនៃប្រទេសកម្ពុជា ដែលរៀបចំដោយ IRENA

## បែងចែកតាមភេទ (ជាភាគរយ)




សម្រាប់ការចម្អិនប្រចាំថ្ងៃ មានគ្រួសារជិតបីក្នុងចំនួនប្រាំគ្រួសារ (៥៥ ភាគរយ) ពឹងផ្អែកលើឥន្ធនៈមិនស្អាត ដូចជា អុស ធ្យូង ចំបើង កំទេចរុក្ខជាតិ ឫស្មៅ ដែលបង្កការគំរាមកំហែងដល់សុខភាពមនុស្ស។ ជាពិសេស អុស ត្រូវបានប្រើយ៉ាងទូលំទូលាយ។ មានចំនួនដល់ទៅ ៨២ ភាគរយនៃអ្នកដែលមិនមានឥន្ធនៈស្អាតប្រើ ពឹងផ្អែកលើ អុស។ ស្ត្រីជាអ្នកទទួលខុសត្រូវក្នុងការចម្អិនម្ហូបអាហារច្រើនជាងបុរស ត្រូវប្រឈមមុខជាខ្លាំង ដែលបណ្ដាល មកពីការប្រើប្រាស់ឥន្ធនៈមិនស្អាតនេះ។ ប្រហែលជា ៩៥ ភាគរយនៃគ្រួសារដែលប្រើប្រាស់ឥន្ធនៈស្អាត ស្ត្រីជាអ្នកទទួលបន្ទុកលើការចម្អិនអាហារ ។ តួលេខនេះស្មើរតែដូចគ្នា (៩៦ ភាគរយ) សម្រាប់គ្រួសារដែលប្រើឥន្ធនៈមិនស្អាត (រូបភាព ៧៧)។

នៅកម្ពុជា មានគ្រួសារប្រមាណ ៥៣ ភាគរយ ប្រើឥន្ធនៈមិនស្អាតក្នុងផ្ទះ និងមិនមានឧបករណ៍ស្រូបផ្សែង ធ្វើឱ្យមានផលប៉ះពាល់ខ្ពស់ដល់សមាជិកគ្រួសារការបំពុលខ្យល់ក្នុងផ្ទះ។ ក្នុងគ្រួសារទាំងនេះ ស្ត្រីចំនួន ៩៦ ភាគរយគឺជាអ្នកទទួលខុសត្រូវលើការចម្អិនម្ហូបអាហារដែលត្រូវប្រឈមជាមួយនឹងផលប៉ះពាល់ដ៏ខ្លាំងនៃឥន្ធនៈនេះ។

ចំពោះគ្រួសារមិនបានប្រើឥន្ធនៈឧស្ម័នតាមបំពង់ឬអគ្គិសនីសម្រាប់ធ្វើការចម្អិន ស្ត្រី និងបុរសជាច្រើនត្រូវតែចេញទៅប្រមូលឥន្ធនៈដោយខ្លួនឯង (រូបភាព៧៨)។ នៅកម្ពុជា បុរសមានអត្រាខ្ពស់ជាងស្ត្រី ដែលទទួលបន្ទុកទៅយកឥន្ធនៈសម្រាប់ធ្វើការចម្អិនអាហារ (បុរស ៥៣ភាគរយ ខណៈស្ត្រីមាន ៤៧ភាគរយក្នុងគ្រួសារ)។ ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាពរបស់អ្នកដែលទទួលខុសត្រូវក្នុងការប្រមូលឥន្ធនៈ មានសារៈសំខាន់ខ្លាំងក្នុងការថែរក្សាសេវាអេកូស៊ីឡូស៊ី និងការរស់រានមានជីវិតរបស់ព្រៃឈើ។

### រូបភាព៧៧៖ សមាមាត្រគ្រួសារ តាមអ្នកទទួលខុសត្រូវក្នុងការចម្អិន តាមភេទ និងប្រភេទឥន្ធនៈ (ជាភាគរយ)




### រូបភាព៧៨៖ សមាមាត្រនៃគ្រួសារតាមអ្នកដែលទទួលខុសត្រូវក្នុងការប្រមូលឥន្ធនៈសម្រាប់ការចម្អិនអាហារ បបែងចែកតាមភេទ (ភាគរយ)




ប្រមាណ ២៤ ភាគរយនៃគ្រួសារកម្ពុជាប្រើប្រាស់ទឹកស្អាតតាមបំពង់បណ្តាញក្នុងផ្ទះ ឬលំនៅដ្ឋានរបស់គាត់ (២៥ ភាគរយនៅរដូវប្រាំង និង ២៣ ភាគរយនៅរដូវវស្សា)។ ក្នុងចំណោមប្រជាពលរដ្ឋខ្វះខាតហេដ្ឋារចនាសម្ព័ន្ធទឹកនៅផ្ទះ ភាគច្រើនពឹងផ្អែកលើទឹកដប (២៧ ភាគរយនៅរដូវប្រាំង ២៣ ភាគរយនៅរដូវវស្សា) បន្ទាប់មកអណ្តូងស្នប់ (២៤ ភាគរយ និង ២៣ ភាគរយ រៀងគ្នា) និងទឹកទិញធុងរទេះ(៣ ភាគរយ ២ ភាគរយ រៀងគ្នា)។ ទោះយ៉ាងណាក៏ដោយ ដោយតំបន់ខ្លះនៅកម្ពុជាប្រឈមនឹងការខ្វះខាតទឹកកាន់តែច្រើនឡើង ដោយសារតែទឹកក្រោមដី និងប្រភពផ្សេងទៀតកំពុងមានការថយចុះយ៉ាងឆាប់រហ័ស ការផ្គត់ផ្គង់ទឹកស្អាតអាចក្លាយជាបញ្ហាប្រឈមកាន់តែខ្លាំងឡើង។ជាឧទាហរណ៍ នៅខេត្តសៀមរាប មានប្រជាជនច្រើនលើសលុប ដែលបណ្តាលឱ្យមានការខ្វះខាតទឹកការប្រើ អាជ្ញាធរបានបង្ខំទាញយកទឹកក្រោមដីមកប្រើប្រាស់ ការនេះកំពុងបន្ថយកម្រិតទឹកក្រោមដី ដែលបង្កគ្រោះថ្នាក់ដល់ការអភិរក្សប្រព័ន្ធអេកូស៊ីឡូស៊ីលើដី និងបណ្តាលឲ្យដីចុះសម្ពាធបាក់ស្រុត។ស្រដៀងគ្នានេះដែរ ដោយសារការប្រែប្រួលអាកាសធាតុ ខេត្តតាកែវ គឺជាខេត្តស្ងួតបំផុតមួយក្នុងប្រទេសកម្ពុជា ហើយកម្ពស់ទឹកនៅតាមដងទន្លេមេគង្គអាចធ្លាក់ចុះជិតពាក់កណ្តាលក្នុងរដូវប្រាំង បណ្តាលឱ្យគ្រួសារនៅក្បែរនោះដែលមិនមានទឹកបំពង់បណ្តាញប្រើប្រាស់ក្នុងការឆ្លើយតបចំពោះបញ្ហាបំពុល និងការខ្វះខាតទឹក ទាំងអស់ជាបញ្ហាប្រឈមសម្រាប់គ្រួសារដែលគ្មានទឹកបំពង់បណ្តាញប្រើប្រាស់ ឬយកទឹកប្រប្រាស់ពីប្រភពផ្សេងទៀត។ការប្រើ ទឹកដបយ៉ាងទូលំទូលាយ មានឥទ្ធិពលក្នុងការកាត់បន្ថយហានិភ័យនៃជំងឺឆ្លងតាមទឹក ប៉ុន្តែវានៅមានបន្ទុកការប្រមូលសម្រាប់មនុស្សជាច្រើន ដែលត្រូវទៅយកទឹកដបផ្ទាល់ ហើយជាញឹកញាប់ក៏បានរួមចំណែកបង្កការបំផ្លាញបរិស្ថានផងដែរ ព្រោះដបដែលប្រើប្រាស់រួច មិនត្រូវបានប្រើឡើងវិញទេ និងជាញឹកញាប់ត្រូវបានបោះបង់ចោលទៅក្នុងបរិស្ថាន។ នៅកម្ពុជា បុរសមានខ្ពស់ជាងស្ត្រី ដែលទទួលខុសត្រូវក្នុងការទៅយកទឹក (រូបភាព៨០)។

មូលហេតុដោយផ្នែក ដោយសារត្រូវការកម្លាំងរាងកាយក្នុងការដឹកទឹកចម្ងាយឆ្ងាយ និងមួយផ្នែកទៀតដោយសារហានិភ័យសុវត្ថិភាពដែលស្ត្រីអាចប្រឈម នៅពេលត្រូវដើរតែម្នាក់ឯង ដូចជាការជួបអំពើហិង្សា និងការរំលោភបំពាន។

ការខ្វះខាតទឹកទូទៅក៏អាចមានឥទ្ធិពលដល់អនាម័យ និងសុវត្ថិភាពរបស់ស្ត្រី និងបុរសផងដែរ។ ឧទាហរណ៍ ការខ្វះទឹកអាចធ្វើឱ្យប៉ះពាល់ដល់ការប្រើប្រាស់និងការទទួលបានបង្គន់ដែលបានកែលម្អ និងអនាម័យ សម្រាប់ទាំងស្ត្រី និងបុរស។ ដូចគ្នានេះផងដែរ នៅពេលគ្មានបង្គន់អនាម័យប្រើប្រាស់នៅក្នុងផ្ទះ វាអាចបង្កគ្រោះថ្នាក់សុវត្ថិភាពសម្រាប់ស្ត្រី ជាពិសេសនៅពេលយប់។ នៅកម្ពុជា គេប្រមាណ ១៨ ភាគរយ ប្រើបង្គន់ដែលគ្មានភ្លើងបំភ្លឺត្រឹមត្រូវ និង ៥៧ ភាគរយ ប្រើបង្គន់ដែលគ្មានសោរចាក់ត្រឹមត្រូវ (រូបភាព៨១)។

### រូបភាព ៧៩៖ សមាមាត្រនៃចំនួនប្រជាជនដែលប្រើប្រាស់សេវាទឹកផឹកដែលគ្រប់គ្រងដោយសុវត្ថិភាព តាមភេទ




ចំណាំ៖ មិនមានភាពខុសគ្នារវាងស្ត្រី និងបុរស ក្នុងន័យតាមស្ថិតិនៅ $\alpha = 0,05$ សម្រាប់ប្រភេទដូចខាងក្រោម៖ 'ទឹកលូការពារ ' និង 'ទឹកទិញធុងរទេះ ' ក្នុងរដូវទាំងពីរ។ 'ទឹកលើដី' និង ' ដឹកទិញឡានស៊ីទែន' នៅរដូវប្រាំង; និង 'ទឹកបណ្តាញក្នុងទីធ្លី/បរិវេណលំនៅដ្ឋាន ' នៅរដូវវស្សា

## រូបភាពទី៨០៖ សមាមាត្រគ្រួសារ តាមអ្នកទទួលខុសត្រូវក្នុងការប្រមូលទឹក តាមភេទ និងចម្ងាយទៅប្រភពទឹក (ភាគរយ)




ចំណាំ៖ គំរូស្ទង់អង្កេតនេះបានចាប់យកតែគ្រួសារទាំងពីរដែលស្ថិតនៅចម្ងាយប្រហែល ៤៥-៦០ នាទីពីប្រភពទឹក ប៉ុណ្ណោះ ដូច្នេះ ប្រភេទ ៤៥-៦០ នាទីត្រូវបានលុបចោល។

## រូបភាព៨១៖ សមាមាត្រនៃចំនួនប្រជាជនដែលរស់នៅក្នុងគ្រួសារ ដែលបង្គន់អនាម័យមានភ្លើងបំភ្លឺមិនល្អ មិនមានសោរចាក់ ឬបានចែករំលែកជាមួយគ្រួសារផ្សេងទៀត បែងចែកតាមភេទ (ភាគរយ)



ផ្ទុយពីការទិញឥន្ទនៈ ជាការសម្រេចចិត្តភាគច្រើនរបស់បុរស គេឃើញថាការសម្រេចចិត្តទាក់ទងនឹងការគ្រប់គ្រងសំណល់ក្នុងគ្រួសារវិញ ត្រូវបានធ្វើឡើងជាធម្មតាដោយស្ត្រី (រូបទី៨២)។ ស្ត្រីប្រមាណ ៩២ភាគរយ និង បុរស៨៤ភាគរយ បានរាយការណ៍ថាគាត់ បានធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងការគ្រប់គ្រងសំណល់ក្នុងគ្រួសារ រួមមានការជ្រើសរើសសំណល់ ញែក ដើម្បីកែច្នៃប្រើប្រាស់ឡើងវិញ និងការសម្រេចថាសំណល់ត្រូវបានចោល ឬដោះស្រាយដោយរបៀបណា។ មានគម្លាតខុសគ្នាខ្លាំង នៅពេលនិយាយពីការសម្រេចចិត្តដោយដោយខ្លួនឯង ក្នុងនោះស្ត្រី ១៩ភាគរយ បានធ្វើសេចក្តីសម្រេចចិត្តតែឯង បើប្រៀបធៀបនឹងបុរសមានតែ៦ភាគរយ។ ការធ្វើ សេចក្តីសម្រេចចិត្តក្នុងការគ្រប់គ្រងកាកសំណល់ក្នុងគ្រួសារអាចមានឥទ្ធិពលយ៉ាងខ្លាំងដល់បរិស្ថានជាសកល តាមការប៉ាន់ស្មានប្រមាណ ៦០ភាគរយនៃកាកសំណល់អាហារគឺកើតចេញពីគ្រួសារ[២៤]។ នៅកម្ពុជា ថ្វីត្បិតតែ ៨៤ និង ៩០ភាគរយនៃសំណល់ទីក្រុងទាំងអស់មាននៅរាជធានីភ្នំពេញ និងខេត្តព្រះសីហនុ ត្រូវបានប្រមូល និងបញ្ជូនទៅកន្លែងចាក់សំរាម ឬមជ្ឈមណ្ឌលកែច្នៃឡើងវិញក៏ដោយ ក៏អត្រានេះមានទាបជាងនៅតាមទីក្រុងដទៃទៀត ដូចជាទីក្រុងកែប មាន ៥៨ភាគរយ ជាបរិមាណសំណល់ច្រើនសន្ធឹកសន្ធាប់ ដែលត្រូវបានបញ្ចេញទៅក្នុងបរិស្ថានដោយផ្ទាល់ដោយមិនមានការបំលែងណាមួយ។ មានតែ ៤៧ ភាគរយប៉ុណ្ណោះនៃទឹកកខ្វក់ក្នុងគ្រួសារត្រូវបានប្រព្រឹត្តិកម្មអោយមានសុវត្ថភាពត្រឹមត្រូវនៅទូទាំងប្រទេស ២៥ ភាគល្អិតនៃទឹក បានចូលរួមបង្កផលអវិជ្ជមានរួមចំណែកដល់ការបំពុលទឹក និងដី ដូច្នេះការសម្រេចចិត្តរបស់គ្រួសារអាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើបរិស្ថានទាំងមូល។

### រូបភាពទី៨២៖ សមាមាត្រ ប្រជាជនដែលជាធម្មតាសម្រេចចិត្តតែម្នាក់ឯង ឬរួមគ្នាទាក់ទងនឹងការគ្រប់គ្រងកាកសំណល់តាមផ្ទះ តាមភេទ (ភាគរយ)




២៤ សូមមើល UNEP ២០២៤ របាយការណ៍សន្ទស្សន៍កាកសំណល់។

២៥ សូមមើលមូលដ្ឋានទិន្នន័យ SDG សកលឆ្នាំ ២០២៥។

## លក្ខណៈខុសគ្នានៃការធ្វើដំណើរ របស់បុរស និងស្ត្រី ការធ្វើដំណើររបស់បុរសមានការចូលរួមបង្កការបំពុលខ្យល់ក្នុងបរិយាកាសខ្ពស់ជាងស្ត្រី

សកម្មភាពប្រចាំថ្ងៃរបស់ប្រជាជន បានរួមចំណែកយ៉ាងសំខាន់ដល់ការបំពុលបរិយាកាស និងទម្រង់ផ្សេងទៀតនៃការរិចរិលបរិស្ថាន ដូច្នេះការសម្រេចចិត្តពាក់ព័ន្ធទាក់ទងនឹងកិច្ចការប្រចាំថ្ងៃអាចមានការរួមចំណែកយ៉ាងសំខាន់ឆ្ពោះទៅរកនិរន្តរភាព។ នៅកន្លែងធ្វើការ បុរសមានច្រើនជាងស្ត្រីក្នុងការចូលរួមក្នុងសកម្មភាពបំផ្លាញបរិស្ថាន(ដូចបានឃើញតាមរយៈការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ឧបករណ៍នេសាទដែលមិនបានកំណត់គោលដៅចង់បាន និងផ្សេងទៀត)។សម្រាប់ការធ្វើដំណើរប្រចាំថ្ងៃ ជាទូទៅស្ត្រីមានលទ្ធភាពច្រើនជាងបុរសក្នុងការធ្វើដំណើរចម្ងាយខ្លីដើម្បីអនុវត្តសកម្មភាពប្រចាំថ្ងៃរបស់គាត់ មិនថាការងារដែលមានប្រាក់ខែ ឬមិនទាន់បានប្រាក់ខែនោះទេ ប៉ុន្តែបុរសមានច្រើនបានប្រើប្រាស់យានយន្តឯកជន។

នៅកម្ពុជា ស្ត្រី៨៥ ភាគរយ និង បុរស៨៨ភាគរយ បានប្រើប្រាស់យានជំនិះឯកជន ដែលជាធម្មតាបានចូលរួមចំណែកខ្លាំងដល់ការបំពុលខ្យល់តាមបុគ្គលម្នាក់ៗ (រូបភាពទី ៨៣)។ សេវាដឹកជញ្ជូនសាធារណៈបានជួយទប់ស្កាត់ការបំភាយឧស្ម័ន ជាទូទៅស្ត្រីមានអត្រាច្រើនជាងបុរសដែលបានប្រើប្រាស់សេវាដឹកជញ្ជូននេះ (ស្ត្រី១១ ភាគរយ និងបុរស ៨ភាគរយ)។ ប៉ុន្តែ ទោះបីជាមិនអាចប្រើយានយន្តផ្ទាល់ខ្លួន ក៏ដោយ ក៏គាត់នៅតែប្រឈមមុខនឹងឧបសគ្គក្នុងការប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈ។ សម្រាប់ស្ត្រីដែលមិនបានប្រើប្រាស់យានយន្តផ្ទាល់ខ្លួន មូលហេតុដែលជួបប្រទះញឹកញាប់បំផុតក្នុងការមិនប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈរួមមាន៖ ការមិនមានជម្រើសនៃ សេវាដឹកជញ្ជូនសាធារណៈនៅក្បែរផ្ទះ (៨៥ ភាគរយ) ឬការមិនអាចមានលទ្ធភាពចំណាយលើសេវាជញ្ជូនសាធារណៈបានឡើយ (១១ ភាគរយ)។ ប្រភេទយានជំនិះដែលប្រើប្រាស់ បានចូលរួមចំណែកខុសគ្នាលើការបំពុលបរិយាកាសផងដែរ។ នៅកម្ពុជាប្រភេទមធ្យោបាយធ្វើដំណើរសាធារណៈដែលប្រជាពលរដ្ឋប្រើប្រាស់ញឹកញាប់បំផុត គឺរថយន្តជួល (តាក់ស៊ី) និងម៉ូតូជួល (ម៉ូតូឌុប) មធ្យោបាយទាំងពីរនេះមានការចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបញ្ចេញឧស្ម័នទៅក្នុងបរិយាកាស។ បុរស ហាក់មានច្រើនជាងស្ត្រី ក្នុងការប្រើប្រាស់តាក់ស៊ីសម្រាប់ជាមធ្យោបាយធ្វើដំណើរ ក្នុងចំណោមមធ្យោបាយធ្វើដំណើរសាធារណៈទាំងអស់នៅកម្ពុជា តាក់ស៊ីត្រូវបានគេរាប់ថាជាជម្រើសដែលបង្កបំពុលបរិយាកាសខ្ពស់បំផុត (រូបភាព ៨៤)។ ចំពោះស្ត្រីភាគច្រើនដែលប្រើរថយន្តសម្រាប់ធ្វើដំណើរទៅធ្វើការ ការប្រើប្រាស់រថយន្តមានកម្រិតទាបនៅឡើយ (រូបភាព ៨៧)។

មានភាពខុសគ្នាគួរឱ្យកត់សម្គាល់ផងដែរ ពាក់ព័ន្ធនឹងការប្រើប្រាស់មធ្យោបាយធ្វើដំណើរឯកជន។ បុរសមានច្រើជាងស្ត្រី ដែលបានប្រើប្រាស់ស្ទើតែគ្រប់មធ្យោបាយធ្វើដំណើរឯកជន លើកលែងតែ (rikshaw/remorque) ដែលស្ត្រីប្រើប្រាស់ច្រើនជាងបុរស។ ទាំងបុរស និងស្ត្រី ម៉ូតូជាមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនដែលត្រូវបានប្រើប្រាស់ញឹកញាប់បំផុត ប៉ុន្តែបុរសប្រើវាច្រើនជាងស្ត្រី (រូបភាពទី ៨៥)។ កង់ក៏ត្រូវបានប្រើប្រាស់យ៉ាងញឹកញាប់នៅកម្ពុជាផងដែរ ដោយស្ត្រីប្រើប្រាស់កង់ញឹកញាប់ដូចម៉ូតូដែរការប្រើម៉ូតូ។ តាមគ្រួសារ បុរសមានអត្រាខ្ពស់ជាងស្ត្រីក្នុងការសម្រេចចិត្តលើការប្រើប្រាស់ការដឹកជញ្ជូនសាធារណៈ ដោយមានរហូតដល់ ៩៥ ភាគរយនៃស្ត្រីបានរាយការណ៍ថាគាត់ បានធ្វើការសម្រេចចិត្តលើបញ្ហានេះមានកម្រិតណាមួយ បើប្រៀបធៀបទៅនឹង ៩៨ ភាគរយនៃបុរស (រូបភាព ៨៦)។

## រូបភាព៨៣៖ សមាមាត្រប្រជាជនដែលបានប្រើប្រាស់ និងមិនបានប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈ បែងចែកតាមភេទ និងមូលហេតុ (ភាគរយ)




*សម្គាល់៖ គ្មានការសង្កេតឃើញសម្រាប់ប្រភេទ "មិនមានការដឹកជញ្ជូនសាធារណៈទៅដល់គោលដៅដែលចង់ទៅបានទេ", "ការដឹកជញ្ជូនសាធារណៈយឺតឬមិនងាយស្រួល" និង "មិនមានអារម្មណ៍ថាដូចជាមានសុវត្ថិភាពនៅក្នុងការដឹកជញ្ជូនសាធារណៈ" ទេ។ មិនមានភាពខុសគ្នារវាងស្ត្រី និងបុរសក្នុងន័យស្ថិតិសំខាន់នៅកម្រិត α = 0.0៥ សម្រាប់ប្រភេទ "មិនអាចប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈបានទេ"*

## រូបភាពទី៨៤៖ សមាមាត្រចំនួនប្រជាជនដែលប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ តាមភេទ និងប្រភេទ (ភាគរយ)




សម្គាល់៖ គ្មានទិន្នន័យអង្កេតសម្រាប់ប្រភេទ "រថភ្លើងក្រោមដី/ ម៉េត្រូ/ រថភ្លើងលើអាកាស/" ទេ។

## រូបភាពទី ៨៥៖ សមាមាត្រ ប្រជាជនដែលប្រើប្រាស់យានជំនិះឯកជនយ៉ាងហោចណាស់ពីរដងក្នុងមួយសប្តាហ៍ តាមភេទ និងប្រភេទ (ភាគរយ)




សម្គាល់៖ គ្មានការសង្កេតឃើញសម្រាប់ប្រភេទ "ទូក" និង "ផ្សេងៗ" ទេ។ មិនមានភាពខុសគ្នារវាងស្ត្រី និងបុរសតាមបែមស្ថិតិកម្រិត α = 0.0៥ សម្រាប់ប្រភេទ "រ៉ឺម៉កកង់បីទេ"។

## រូបភាពទី ៨៦៖ សមាមាត្រ ប្រជាជនដែលជាធម្មតាធ្វើការសម្រេចចិត្តអំពីការប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ តាមភេទ និងការសម្រេចចិត្តត្រូវបានធ្វើឡើងតែម្នាក់ឯង ឬរួមគ្នា (ភាគរយ)




## រូបភាពទី ៨៧៖ ចំនួនមធ្យមនៃប្រើប្រាស់មធ្យោបាយធ្វើដំណើរឯកជន តាមប្រភេទយានយន្ត និងភេទ (តម្លៃមធ្យមមេគុណ)

| ប្រភេទយានយន្ត | កង់ | រថយន្ត | ម៉ូតូ | ទូក | រ៉ឺម៉កកង់បី | ផ្សេងទៀត |
|---|---|---|---|---|---|---|
| ស្ត្រី | ៤,៦២ | ៣,៥៨ | ៤,៦៤ | ៤,៥៦ | ៣,៥៩ | ៣,៩៧ |
| បុរស | ៤,៦៣ | ៤,៤៩ | ៤,៨៦ | ៤,៦៧ | ៣,៤៨ | ៣,៦៧ |

■ ប្រេកង់ច្រើន ■ ប្រេកង់មធ្យម ■ ប្រេកង់តិច

ចំណាំ៖ "ប្រេកង់ខ្ពស់" សំដៅលើការប្រើប្រាស់យានជំនិះឯកជនជារៀងរាល់ថ្ងៃ "ប្រេកង់មធ្យម" សំដៅលើការប្រើប្រាស់យានជំនិះឯកជនពីរដងក្នុងមួយសប្តាហ៍ ឬច្រើនជាងនេះ ហើយប្រេកង់ប្រើប្រាស់ណាមួយទាបជាងនោះត្រូវបានចាត់ទុកថាជា "ប្រេកង់ទាប"។

## មានប្រជាពលរដ្ឋតិចតួចប៉ុណ្ណោះដែលចូលរួមក្នុងការសម្រេចចិត្តដោះស្រាយបញ្ហាបរិស្ថាន ប៉ុន្តែ គម្លាតយេនឌ័រមិនមានភាពខុសគ្នាច្រើនទេ

ប្រជាជនភាគច្រើននៅកម្ពុជាមិនមានការចូលរួមក្នុងការសម្រេចចិត្តទាក់ទងនឹងបរិស្ថាននៅក្នុងបរិបទស្ថាប័ននានាទេ។ មានស្ត្រីតែ ៦ ភាគរយ និងបុរស ៥ ភាគរយប៉ុណ្ណោះ ដែលបានចូលរួមក្នុងក្រុមប្រើប្រាស់ ឬគ្រប់គ្រងទឹក និងគណៈកម្មការដែលពាក់ពន្ធ័នឹងវិស័យនេះ (រូបទី ៤៨)។ អត្រាការចូលរួមកាន់តែទាបជាងនេះទៀត នៅក្នុង វិស័យផ្សេងៗ ដូចជា ការពិភាក្សាអំពីដំណោះស្រាយសម្រាប់បញ្ហាប្រែប្រួលអាកាសធាតុ និងការចូលរួមក្នុងក្រុមឆ្លើយតបបរិបទគ្រោះមហន្តរាយ ដែលមានអត្រាចូលរួមចន្លោះពី ១ ដល់ ២ ភាគរយប៉ុណ្ណោះ។ មាន  គម្លាតយែនខ្លាំងក្នុងការចូលរួម ទោះបីជាមានតិចតួចក៏ដោយ ក៏ត្រូវបានរកឃើញនៅក្នុងក្រុមគ្រប់គ្រងព្រៃឈើ។ តាមការប៉ាន់ស្មានមានស្ត្រីប្រមាណ ៤ ភាគរយ និងបុរស ៧ ភាគរយ បានប្រើប្រាស់ធនធានព្រៃ និងព្រៃធម្មជាតិក្នុងជីវិតប្រចាំថ្ងៃមានការចូលរួមក្នុងការគ្រប់គ្រងដីសហគមន៍ និងក្រុមព្រៃឈើ។ ការចូលរួមនេះគឺមានសារៈសំខាន់ក្នុងការធានាថាប្រភពធនធានទាំងនេះត្រូវបានគ្រប់គ្រង តាមតម្រូវការរបស់ក្រុមប្រជាជនទាំងអស់ ហើយគួរត្រូវបានលើកទឹកចិត្តឱ្យមានការចូលរួម។ ការលើកកម្ពស់ឱ្យស្ត្រីចូលរួមច្រើនក្នុងក្រុមទាំងនេះគឺមានសារៈសំខាន់យ៉ាងខ្លាំង។ ស្ត្រីនៅតែមានការចូលរួមតិចនៅសព្វថ្ងៃ  នេះអាចបុរសមានច្រើនក្នុងការ គ្រប់គ្រង និងទាញយកអត្ថប្រយោជន៍ពីសកម្មភាពគ្រប់គ្រងធនធានព្រៃសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃដូចជាការកាប់ឈើជាដើម។ ដោយសារតែស្ត្រី បានគ្រប់គ្រងព្រៃអោយចីរភាពបានល្អជាងបុរស (ដូចដែលបានបង្ហាញក្នុងរបាយការណ៍នេះ ស្ត្រីមានសក្តានុពលច្រើនជាងក្នុងការចូលរួមការប្រមូលធនធានពីព្រៃ  ការដាំឡើងវិញ និងការផ្អាកការចូលរួមការប្រមូលធនធានព្រៃបណ្តោះអាសន្ន) ការរួមចំណែករបស់គាត់ ចំពោះការគ្រប់គ្រងដីនិងព្រៃគឺមានសារៈសំខាន់ក្នុងការលើកកម្ពស់ការគ្រប់គ្រងដែលមានចីរភាព។

ក្រៅពីការគ្រប់គ្រងព្រៃ និងដីសហគមន៍ គម្លាតយេនឌ័រមានតិចក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្សេងៗគ្រប់ផ្នែកទាំងអស់។ ទោះជាយ៉ាងណា បុរសមានការចូលរួមច្រើនជាងស្ត្រីក្នុងការសម្រេចចិត្តគ្រប់ប្រភេទសកម្មភាពជាច្រើនដូច្នេះនេះជាសញ្ញាសំខាន់មួយបង្ហាញថា ត្រូវលើកទឹកចិត្តឱ្យស្ត្រីមានការចូលរួមច្រើនឡើង។ ការចូលរួមក្នុងក្រុមទាំងនេះ មានសារៈសំខាន់ដើម្បីធានាថាការសម្រេចចិត្តគ្រប់គ្រងធនធានធម្មជាតិត្រូវស្របតាមតម្រូវការរបស់ស្ត្រី និងបុរស និងរួមចំណែកក្នុងការអភិរក្សបរិស្ថានជារួម។

## រូបភាពទី៨៨៖ សមាមាត្រប្រជាជន ដែលបានចូលរួមធ្វើសេចក្ដីសម្រេចចិត្តទាក់ទងនឹងបរិស្ថាន បែងចែកតាមភេទ (ភាគរយ)



# សេចក្ដីសន្និដ្ឋាន និងជំហានបន្ទាប់

ការអង្កេតយេនឌ័រ និងបរិស្ថានកម្ពុជា ឆ្នាំ២០២៤ (GES) ជាការអង្កេតថ្នាក់ជាតិលើកដំបូងនៅកម្ពុជា ដែលបង្ហាញពីអន្តរកម្មរបស់បុរស និងស្ត្រីជាមួយបរិស្ថាន ដោយរួមមានផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ការចូលរួមក្នុងជីវភាពទាក់ទងបរិស្ថាន ការសម្រេចចិត្តក្នុងបរិស្ថាន និងចំណុចសំខាន់ ផ្សេងៗទៀត។ ខាងក្រោមនេះជាសេចក្ដីសង្ខេបនៃលទ្ធផលសំខាន់ៗដែលបានរកឃើញពីការអង្កេត និងជំហានបន្ទាប់ដើម្បីប្រើប្រាស់ទិន្នន័យនេះឱ្យមានប្រសិទ្ធភាព។

## ១.កម្រិតប៉ះពាល់ពីគ្រោះថ្នាក់មានខ្ពស់នៅកម្ពុជា ការកែលម្អសមត្ថភាពដោះស្រាយរបស់ស្ត្រី និងការកាត់បន្ថយភាពងាយរងគ្រោះ នៅតែជាចំណុចសំខាន់

នៅកម្ពុជាមាន ៩នាក់ក្នុងចំណោមមនុស្ស ១០នាក់ រស់នៅក្នុងតំបន់ដែលមានហានិភ័យបរិស្ថានខ្ពស់[២៦] និងស្ទើរតែគ្រប់គ្នាធ្លាប់បានរងគ្រោះមហន្តរាយយ៉ាងហោចណាស់មួយ ក្នុងអំឡុងពេល១២ខែកន្លងមក។ លើសពីនេះទៅទៀត ស្ថិតិក៏បង្ហាញផងដែរ ប្រមាណ ៧៥ ភាគរយនៃប្រជាជន បានជួបប្រទះគ្រោះមហន្តរាយយ៉ាងហោចណាស់បី ក្នុងរយៈពេលដូចគ្នានេះ។ ការរងគ្រោះទាក់ទងនឹងអាកាសធាតុមានផលប៉ះពាល់ដល់ការរស់ប្រចាំថ្ងៃរបស់មនុស្ស និងសត្វមានដូចជា ការកើនឡើងសីតុណ្ហភាព ការធ្លាក់ចុះនៃទឹកភ្លៀង និងការរីរាលដាលនៃសត្វល្អិតបំផ្លិចបំផ្លាញផលដំណាំ។[២៧] បើទោះបីជា បុរសនិងស្ត្រីមានផល ប៉ះពាល់ដូចគ្នាក្នុងការជួបប្រទះគ្រោះថ្នាក់ទាំងនេះ ក្ដីប៉ះពាល់របស់វាទៅលើជីវិតបុរសនិងស្ត្រីមានភាពខុសគ្នា។ ស្ត្រីជនបទ និងបានផ្លាស់ទី ដោយសាររងគ្រោះមហន្តរាយ ឬគ្រោះថ្នាក់ធម្មជាតិផ្សេងៗ គឺជាអ្នកមានដែលជួបប្រទះឧបសគ្គខ្លាំងបំផុតក្នុងការទទួលបានសេវាសុខភាព និងផលិតផលអនាម័យ( ស្ត្រី១៩ ភាគរយ ដែលបានផ្លាស់ទី បើប្រៀបធៀបនឹង ១២ ភាគរយសម្រាប់ស្ត្រីដែលមិនបានផ្លាស់ទី។ ស្ត្រីក៏មានអត្រាច្រើនជាងបុរសដែលបានកត់សម្គាល់ឃើញថាផល ដំណាំ និងសត្វចិញ្ចឹមរបស់គាត់ត្រូវបានរងការខូចខាត ឬបំផ្លាញដោយសារគ្រោះថ្នាក់បហន្តរាយ ( ៥៩ភាគរយ សម្រាប់ស្ត្រីដែលមានផលប៉ះពាល់លើដំណាំ បើធៀបនឹងបុរសមាន ៤៤ភាគរយ)។ ផលប៉ះពាល់ជីវភាពរស់នៅប្រចាំថ្ងៃទាំងនេះក៏បណ្ដាលឱ្យស្ត្រីទទួលបន្ទុកមិនមានសមាមាត្រលើភារកិច្ចថែទាំ និងការងារផ្ទះដែលមិនបានជាប្រាក់។ ស្ត្រីមានរហូតដល់ ២៦ ភាគរយ មានការកើនឡើងលើការថែទាំកុមារដែលមិនទទួលបានប្រាក់ឈ្នួលដែលបណ្ដាលមកពីគ្រោះមហន្តរាយ បើប្រៀបធៀបនឹងបុរមានតែ ២២ ភាគរយប៉ុណ្ណោះ។ លើសពីនេះទៅទៀត មានស្ត្រី ៣១ ភាគរយ និងបុរស២៨ ភាគរយ បានឃើញថាបន្ទុការងារការថែទាំខ្លួន បានកើនឡើងដោយសារផលប៉ះពាល់អំពីការប្រែប្រួលអាកាសធាតុ។ ការកើនឡើងនេះ បានចូលរួមធ្វើឱ្យបន្ទុកការងាររបស់ស្ត្រីដែលមានស្រាប់ កាន់តែធ្ងន់ធ្ងរឡើងជាងបុរសលើការងារថែទាំគ្រួសារដែលមិនបានទទួលបានកម្រៃបន្ទាប់ពីព្រឹត្តិការណ៍គ្រោះថ្នាក់នេះ។ ការធានាបាន ប្រជាពលរដ្ឋមនុស្សគ្រប់រូប ទទួលបានសេវាសុខាភិបាលដែលសមរម្យ រួមទាំងអ្នកនៅតាមជនបទ និងការគាំទ្រដល់ស្ត្រីផ្លាស់ប្ដូរដាំដំណាំដែលអាចធន់នឹងអាកាសធាតុ មិនត្រឹមតែជួយកាត់បន្ថយឥទ្ធិពលទាំងនេះទេ

២៦ សូមមើលនិយមន័យនៃហានិភ័យបរិស្ថានខ្ពស់នៅក្នុងទំព័រ ១១ ។

២៧ សូមមើលទំព័រ ១០ សម្រាប់និយមន័យនៃគ្រោះថ្នាក់ និងគ្រោះមហន្តរាយដែលទាក់ទងនឹងអាកាសធាតុ។

ប៉ុន្តែអាចជួយពង្រឹងភាពធន់ជាងមុនផងដែរ។

**២.ការប្រែប្រួលអាកាសធាតុបានប៉ះពាល់ទាំងដល់សុខភាពរាងកាយ និងផ្លូវចិត្តរបស់ប្រជាពលរដ្ឋកម្ពុជាជាច្រើនរូបដោយស្ត្រីបានរងផលប៉ះពាល់នេះខ្លាំង ការផ្លាស់ប្តូរបរិបទសង្គម និងការលើកកម្ពស់ការទទួលបានព័ត៌មានអាចជួយសង្គ្រោះជីវិត និងជីវភាពរស់នៅបាន**

មានប្រជាពលរដ្ឋរហូតដល់ ៧៦ ភាគរយ សុខភាពផ្លូវចិត្តរបស់គាត់កាន់តែអាក្រក់ ដែលបណ្តាលមកពីផល ប៉ះពាល់នៃគ្រោះមហន្តរាយ និង ៧៧ ភាគរយ ដោយសារផលប៉ះពាល់អាកាសធាតុដែលកើតឡើងយឺតៗ។ អារម្មណ៍ស្រ្តេស និងការថប់បារម្ភដែលបណ្តាលមកពីបាតុភូតទាំងនេះ បានប៉ះពាល់ស្រដៀងគ្នាទៅដល់ស្ត្រី និងបុរស ទោះបីជាស្ត្រីមានច្រើនជាងបុរសបន្តិចបន្តួចពីផលប៉ះពាល់ទាំងនេះក៏ដោយ។ លើសពីនេះទៅទៀត ស្ត្រី ៤៨ ភាគរយ និងបុរស ៤៥ ភាគរយបានកត់សម្គាល់ឃើញថាសុខភាពរាងកាយរបស់គាត់ បានរងផលប៉ះពាល់ផងដែរ ដោយសារតែគ្រោះថ្នាក់នៃអាកាសធាតុអាចបង្ក ឬធ្វើឱ្យមានជំងឺផ្លូវដង្ហើមកាន់តែធ្ងន់ធ្ងរ បញ្ហាដល់ប្រព័ន្ធរំលាយអាហារ បញ្ហាបេះដូង ជំងឺដាច់សរសៃឈាម(ស្ត្រូក) ឬជំងឺដែលបណ្តាលមកពីសត្វល្អិត ក្នុងចំណោមជំងឺជាច្រើនទៀត។ លើសពីនេះទៅទៀត ដោយសារការប្រែប្រួលអាកាសធាតុ រួមមានភាពរាំងស្ងួតញឹកញាប់ ការកើនឡើងកំដៅ និងគ្រោះថ្នាក់ផ្សេងៗទៀត មនុស្សជាច្រើនបានចែករំលែករបបអាហាររបស់ខ្លួនទៅអោយអ្នកដទៃបរិភោគជំនួស។ ជាពិសេសចំពោះឪពុកឬម្តាយដែលចិញ្ចឹមកូនតែម្នាក់ឯង គឺជាអ្នកដែលបានកាត់បន្ថយរបបអាហាររបស់ខ្លួនច្រើនជាងគេដោយសារការប្រែប្រួលអាកាសធាតុ (២០ភាគរយ) ទោះជាយ៉ាងណាក៏ដោយ ស្ត្រីដែលមានដៃគូទោះបីមានកូនក្តី ឬគ្មានកូនក្តី ជាទូទៅស្ត្រីមានអត្រាខ្ពស់ជាងដៃគូរបស់គាត់ដែលបានបានកាត់បន្ថយរបបអាហាររបស់ខ្លួន (ស្ត្រី ១២ភាគរយ និងបុរសមាន៩ ភាគរយ)។ បទដ្ឋានសង្គមបានដើរតួនាទីយ៉ាងសំខាន់ក្នុងលទ្ធផលទាំងនេះ ហើយការផ្លាស់បទដ្ឋានសង្គមនោះអាចជម្រុញឱ្យបុរស និងស្ត្រី ចែករំលែកភារកិច្ចទាំងនេះបានសមស្របជាងមុន។ លើសពីនេះ ការលើកកម្ពស់ប្រជាជនមានឱកាសទទួលបានព័ត៌មានការព្រមានជាមុនអំពីគ្រោះថ្នាក់អាចជួយឱ្យគាត់រៀបចំខ្លួនបានល្អជាងមុន និងបន្ថយផលប៉ះពាល់ផងដែរ។ នៅកម្ពុជា គ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងការកើនឡើងកម្តៅ និងទឹកភ្លៀងត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ហើយប្រជាពលរដ្ឋភាគច្រើន បានទទួលបានព័ត៌មានតាមរយៈអ៊ីធីរណែតអំពីការត្រៀមខ្លួនទុកជាមុន។ ទោះជាយ៉ាងណា ព្រឹត្តិការណ៍ដូចជាការរីករាលដាលជំងឺដោយសត្វល្អិត និងការបំផ្លាញរបស់សត្វល្អិតជាប្រចាំ និងជំងឺបណ្តាលដោយសត្វល្អិត ទទួលបានការចាប់អារម្មណ៍តិចតួច។ នៅពេលដែលការព្រមានជាមុនមិនត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានសាធារណៈ ស្ត្រីនិងបុរសត្រូវពឹងផ្អែកលើប្រភពព័ត៌មានផ្សេងៗគ្នា (ដូចជាមិត្តភក្តិ និងគ្រួសារ និងអាជ្ញាធរមូលដ្ឋាន) ដូច្នេះគុណភាព និងពេលវេលានៃព័ត៌មានដែលទទួលបានអាចប៉ះពាល់ដល់ការរៀបចំខ្លួនជាមុនរបស់ពួកគាត់។

## ៣.ការអនុវត្តវិធីសាស្ត្រកសិកម្មកំពុងមានការប្រែប្រួល ប៉ុន្តែសកម្មភាពជាច្រើននៅតែរួមចំណែកបណ្តាលឱ្យខូចគុណភាពដី ការពង្រឹងបទប្បញ្ញត្តិទាក់ទងនឹងការប្រើប្រាស់ថ្នាំពុលសម្លាប់សត្វល្អិត និងជីគីមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការការពារសុខភាពប្រជាជន និងថែរក្សាប្រព័ន្ធអេកូឡូស៊ី

ទិន្នផលកសិកម្មកំពុងប្រឈមនឹងការធ្លាក់ចុះ ដោយសារការប្រែប្រួលអាកាសធាតុ។ ដើម្បីរក្សាជីវភាពរស់នៅ កសិករជាច្រើនកំពុងអនុវត្តការជ្រើសរើសគ្រាប់ពូជគួរឱ្យលើកទឹកចិត្ត ឱ្យអនុវត្តន៍បន្ត។ ទោះយ៉ាងណាក៏ដោយ កសិករខ្លះនៅតែប្រើប្រាស់សារធាតុពុលប្រឆាំងសត្វល្អិត និងជីសារជាតិកាន់តែច្រើន ដើម្បីកាត់បន្ថយការខាតបង់។ ស្ត្រីប្រហែល ៥០% និងបុរស ៥៥% កំពុងប្រើសារធាតុពុលប្រឆាំងសត្វល្អិត ខណៈដែល ៦៤% នៃប្រជាជនប្រើប្រាស់ជី។ អ្វីដែលគួរឱ្យព្រួយបារម្ភជាងនេះនោះគឺ ប្រមាណ ២៤% នៃប្រជាជនបច្ចុប្បន្នកំពុងប្រើសារធាតុពុលប្រឆាំងសត្វល្អិតក្នុងបរិមាណកាន់តែខ្ពស់។ ទោះបីជាវិធីសាស្ត្រទាំងនេះអាចជួយរក្សាបានផលផលិតក្នុងរយៈពេលខ្លី ប៉ុន្តែវាអាចនាំឱ្យមានផលវិបាកធ្ងន់ធ្ងរនៅក្នុងរយៈពេលវែង។ឧទាហរណ៍មួយ គឺច្រើនជាងពាក់កណ្តាលនៃកសិករបានកត់សម្គាល់ឃើញថា មានការធ្លាក់គុណភាពដីនៅលើដីដែលគាត់បានធ្វើកសិកម្ម ប៉ុន្តែក្នុងចំណោមអ្នកប្រើសារធាតុគីមីថ្នាំពុល តួលេខនេះបានកើនឡើងដល់ ៧០ ភាគរយ។ បញ្ហាសំខាន់មួយទៀតគឺការមិនគោរពតាមគោលការណ៍ណែនាំ។ បើទោះបីបុរសមានអត្រាច្រើនជាងស្ត្រីដែលបានអនុវត្តន៍តាមសេចក្តីណែនាំនៅលើផលិតផលថ្នាំសម្លាប់សត្វល្អិត (ស្ត្រី៥៣ ភាគរយ និង បុរស៥៨ ភាគរយ)។ តិចជាង ៣០ ភាគរយនៃអ្នកប្រើប្រាស់ថ្នាំពុលសម្លាប់សត្វល្អិតសរុប ដែលបានសម្អាត និងថែទាំសម្ភារៈការពារបន្ទាប់ពីប្រើប្រាស់។ មានតែស្ត្រី ១៦ ភាគរយ និង បុរស១១ ភាគរយ ប៉ុណ្ណោះ ដែលបានរៀបចំទុកដាក់សំបកថ្នាំសម្លាប់សត្វល្អិតដោយសុវត្ថិភាព។ បន្ថែមពីលើការយល់ដឹងអំពីហានិភ័យនៃថ្នាំពុលសារធាតុគីមី គឺមិនគ្រប់គ្រាន់នោះទេ ខណៈដែលអ្នកប្រើប្រាស់ថ្នាំពុលសារធាតុគីមី ចំនួន ៩៧ ភាគរយបាននិយាយថាគាត់ ប្រើប្រាស់តែសារធាតុដែលមានគ្រោះថ្នាក់មធ្យមក៏ដោយ ប៉ុន្តែការធ្វើសំណាកដីបានបង្ហាញឲ្យឃើញអ្វីខុសពីនេះ។ ការខ្វះការយល់ដឹងនេះ បានធ្វើឱ្យកសិករជាច្រើនមិនអនុវត្តន៍តាមនីតិវិធីសម្រាប់ការប្រើប្រាស់ និងរៀបចំទុកដាក់សំបកថ្នាំពុលសារធាតុគីមី ដែលអាចជួយកំណត់ផលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី និងសុខភាពមនុស្ស។ បញ្ហាដូចគ្នានេះក៏អាចឃើញបានក្នុងការប្រើប្រាស់ជីគីមីផងដែរ ទោះបីជាមានប្រជាជនចំនួន ៦៨ ភាគរយជឿថាពួកគាត់បានអនុវត្តតាមសេចក្តីណែនាំពីកន្លែងលក់ និងបទបញ្ញត្តិមូលដ្ឋាន ដើម្បីការពារបរិស្ថានក៏ដោយ ក៏ការប្រើប្រាស់ជីគីមីនេះខុសគោលដៅក៏មានការរីករាលដាលយ៉ាងខ្លាំងផងដែរ។ មានស្ត្រីប្រមាណ ១ ភាគរយ និង បុរស២ ភាគរយប៉ុណ្ណោះ ដែលបានធ្វើសំណាកដីដើម្បីរកសារធាតុចិញ្ចឹម (nutrient budget) និងមានស្ត្រីតែ ៦ ភាគរយ និង បុរស៨ ភាគរយប៉ុណ្ណោះ ដែលបានគិតពិចារណាអំពីប្រភេទដី និងអាកាសធាតុនៅពេលសម្រេចចិត្តប្រើសារធាតុទាំងនេះ។ ការប្រើប្រាស់ខុសគោលដៅទាំងនេះកំពុងរីករាលដាលយ៉ាងទូលំទូលាយ និងការយល់ច្រឡំរបស់កសិករ ថាពួកគាត់បានអនុវត្តន៍តាមនីតិវិធី បានបង្ហាញឱ្យឃើញពីសារៈសំខាន់នៃការកែលម្អការអប់រំកសិករ និងការរឹតបន្តឹងបទបញ្ញា ទាំងនេះរួមមាន ការជំរុញឲ្យកសិកម្មតាមបច្ចេកទេសត្រឹមត្រូវ(precision farming) លើកកម្ពស់ការយល់ដឹងអំពីស្លាកសញ្ញានៃផលិតផល ការអនុវត្តកំណត់លើការប្រើប្រាស់សារធាតុគ្រោះថ្នាក់ និងការលើកទឹកចិត្តឱ្យអនុវត្តន៍នូវវិធីសាស្ត្រដែលមានសក្តានុពល ដូចជាការជ្រើសរើសពូជ។

## ៤. ព្រៃឈើធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីកំពុងបាត់បង់យ៉ាងឆាប់រហ័ស ស្ត្រីគឺត្រូវបានសង្កេតឃើញការបាត់បង់ទាំងនេះច្រើនជាងគេ ការពង្រឹងការការពារតំបន់ព្រៃ និងការអប់រំអំពីការគ្រប់គ្រងប្រកបដោយនិរន្តរភាព ក្លាយជាការបន្ទាន់

ព្រៃឈើ ធម្មជាតិ ព្រៃវាលស្មៅ ព្រៃកោងកាង ឬដីព្រៃឈើប្រភេទផ្សេងៗទៀត ជាមូលដ្ឋានសំខាន់សម្រាប់ការអភិរក្សជីវចម្រុះ។ ទីតាំងទាំងនេះគឺជាដំណើរផ្គត់ផ្គង់សំខាន់សម្រាប់អាហារ អុស និងឈើសម្រាប់សំភារៈធ្វើសំណង់។ លើសពីនេះទៀត វាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារ និងទប់ទល់ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ នៅកម្ពុជា តំបន់ទាំងនេះកំពុងបាត់បង់យ៉ាងឆាប់រហ័ស និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីរបស់ពួកវាកំពុងត្រូវបានកាត់បន្ថយជាបន្តបន្ទាប់។ ស្ត្រីប្រមាណជា ៦៤ ភាគរយ និង បុរស៥៨ ភាគរយ ដែលប្រើប្រាស់តំបន់ទាំងនេះ បានសង្កេតឃើញមានការរីករាលដាលនៃការបំផ្លិចបំផ្លាញ។ ប្រហែល ៧ ក្នុងចំណោម ១០ នាក់នៃពួកគាត់ បានកត់សម្គាល់ការបាត់បង់ទំហំទូទៅ រួមមានព្រៃធម្មជាតិខ្លះៗដែលត្រូវបានកាប់យកឈើ ការធ្វើនគរូបនីយកម្ម និងការទិនទ្រានរំលោភលើដី។ ពួគាត់ជាច្រើនបានកត់សម្គាល់ឃើញថា គាត់មិនអាចរកឃើញប្រភេទ និងបរិមាណសត្វ និងរុក្ខជាតិដូចមុនទៀតឡើយ។ ទោះបីជាបុរសមានចំនួនច្រើនជាងស្ត្រីក្នុងការពឹងផ្អែកលើព្រៃធម្មជាតិសម្រាប់ជីវភាពរស់នៅ ប៉ុន្តែស្ត្រីភាគច្រើនសង្កេតឃើញថា សកម្មភាពក្នុងព្រៃធម្មជាតិ គឺជាផ្នែកសំខាន់នៃចំណូលរបស់គាត់ ការកាត់បន្ថយការបំផ្លាញព្រៃ និងជីវចម្រុះដែលទាក់ទងគ្នា គឺមានសារៈសំខាន់យ៉ាងខ្លាំងនៅកម្ពុជា ប៉ុន្តែការប្រព្រឹត្តិខុសនៃអ្នកប្រើប្រាស់ព្រៃធម្មជាតិភាគច្រើន មិនបានចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងព្រៃឲ្យប្រកបដោយនិរន្តរភាពឡើយ។ ករណីលេចធ្លោមួយ គឺការប្តូរពេលវេលាចិញ្ចឹមសត្វ ឬទីតាំងចិញ្ចឹមសត្វដើម្បីអនុញ្ញាតឲ្យធនធានធម្មជាតិអាចកើនឡើងវិញបាន។ វិធីនេះត្រូវបានអនុវត្តដោយស្ត្រីប្រមាណ ៧៧ ភាគរយ និងបុរស ៦៩ ភាគរយ ។ ការអនុវត្តន៍វិធីគ្រប់គ្រងព្រៃប្រកបដោយនិរន្តរភាពផ្សេងទៀត ត្រូវបានអនុវត្តដោយតិចជាង ៣០ ភាគរយនៃប្រជាជនដែលប្រើប្រាស់ព្រៃទាំងនេះ ដែលស្ត្រីមានឱកាសធ្វើការគ្រប់គ្រងព្រៃអោយមាននិរន្តរភាពច្រើនជាងបុរស។ ឧទាហរណ៍ ស្ត្រី មាន ២៤ ភាគរយ និង បុរស២០ ភាគរយ ដែលបណ្តុះដាំដើមឈើឡើងវិញ ឬការស្តារសត្វព្រៃឡើងវិញវិញបន្ទាប់ពីការប្រមូលផល។ ដូចគ្នានេះដែរ ស្ត្រីចំនួន ២១ ភាគរយ និងបុរស ១៥ ភាគរយ អនុវត្តការប្រមូលផលជាច្រើនដំណាក់កាល ខណៈដែលស្ត្រី ១២ ភាគរយ និងបុរស ១០ ភាគរយ អនុវត្តការជ្រើសរើសធនធានឲ្យនៅសល់សម្រាប់បន្តពូជ (ឧទាហរណ៍ ទុកស៊ុត ស្លឹក កូនសត្វឲ្យសល់) ដើម្បីអោយសត្វ/រុក្ខជាតិបន្តពូជ និងស្តារឡើងវិញ។ អត្រាទាបទាំងនេះ បានបង្ហាញឲ្យឃើញពីអត្រាបាត់បង់ព្រៃ និងជីវចម្រុះព្រៃដែលកំពុងកើនឡើងយ៉ាងឆាប់រហ័សនៅទូទាំងប្រទេស ទោះបីជាដំណើរការឧស្សាហកម្មធំៗ ដូចជា ការសាងសង់ ការរីកចម្រើនទីក្រុង ឬឧស្សាហកម្មក៏ជាជាចំណែកមួយដែលរួមចំណែកផងដែរ។ ដើម្បីធានាថា ព្រៃឈើនៅកម្ពុជា នឹងបន្តអនុវត្តតួនាទីសំខាន់របស់ខ្លួនក្នុងការគាំទ្រជីវភាពនិងប្រព័ន្ធអេកូឡូស៊ី ជំហានដំបូងគឺការពង្រឹងការការពារតំបន់ព្រៃឲ្យបានរឹងមាំ។ ការផ្លាស់ប្តូរអត្តចរិតលក្ខណៈបុគ្គលដើម្បីលើកកម្ពស់ ការគ្រប់គ្រងដោយនិរន្តរភាព តាមរយៈការអប់រំ និងបណ្តុះបណ្តាល ក៏អាចផ្តល់រួមចំណែកយ៉ាងសំខាន់ដែរ ដើម្បីសម្រេចបានគោលដៅនេះ។

## ៥.ការបាត់បង់បរិមាណមច្ឆាជាតិកំពុងប៉ះពាល់ដល់ជីវភាពរស់នៅ ទាំងស្ត្រី និងបុរស ប៉ុន្តែបុរសមានធនធានច្រើនជាងស្ត្រីក្នុងការស្តារឡើងវិញ ការសហការជាបន្ថែមរវាងប្រជាជននេសាទក្នុងស្រុក និងអាជ្ញាធរជាតិ អាចជួយឲ្យប្រភេទសត្វទឹកស្តារឡើងវិញបាន

ស្ត្រីចំនួន ២០ ភាគរយ និងបុរស ១៨ ភាគរយ ដែលអនុវត្តការចិញ្ចឹមត្រី ឬប្រមូលផលសត្វក្នុងទឹកផ្សេងៗ ក្នុងមហាសមុទ្រ ទន្លេ បឹង ឬផ្ទៃទឹកផ្សេងៗ បានចាប់អារម្មណ៍ឃើញថា ទិន្នផលដែលគាត់ចាប់បានបានធ្លាក់ចុះ។ រឿងនេះរួមជាមួយការកើនឡើងយ៉ាងខ្លាំងនៃការចាប់ត្រីដែលមិនចង់បាន (១៧ ភាគរយនៃមនុស្ស) គឺជាសញ្ញាច្បាស់លាស់នៃការបាត់បង់បរិមាណត្រី។ ដើម្បីដោះស្រាយបញ្ហានេះ ប្រជាជនកំពុងចំណាយពេលច្រើនជាងមុនក្នុងការនេសាទ ឬផ្លាស់ប្តូរទីតាំងនេសាទ។ ទោះបីជាយ៉ាងណា សម្រាប់ស្ត្រីជាអ្នកនេសាទ ការផ្លាស់ទីទីតាំងនេសាទមិនមែនរឿងងាយស្រួលទេ។ ប្រហែលជា ៥២ ភាគរយនៃស្ត្រីនេសាទ អនុវត្តវិធីសាស្ត្រនេសាទដោយដៃ ឬការប្រមូលត្រីដោយដៃ ជាវិធីចាប់ត្រីសំខាន់របស់ពួកគាត់ ប្រៀបធៀបនឹង ២៨ ភាគរយនៃបុរស។ ផ្ទុយពីនេះ បុរសមានភាពមានភាគរយខ្ពស់ជាងស្ត្រីក្នុងការប្រើប្រាស់ឧបករណ៍អួនអូស សំណាញ់បង់ សន្ទូចរនង លប និងវិធីសាស្ត្រនេសាទផ្សេងៗទៀត ដែលភាគច្រើនជាវិធីនេសាទចាប់ត្រីមិនជ្រើសរើស ដែលចាប់សត្វមិនមែនគោលដៅនិងបង្កឲ្យមានការបាត់បង់ជីវចម្រុះទឹកយ៉ាងខ្លាំង។បន្ថែមពីនេះ បុរសដែលពឹងផ្អែកលើវិធីសាស្ត្រនេសាទដែលភាគច្រើនត្រូវការទូកម៉ាស៊ីនជាចម្បង អាចផ្លាស់ទីតំបន់នេសាទបានងាយស្រួលជាងនៅពេលបរិមាណត្រីធ្លាក់ចុះ។ ខណៈមានតែ ១៥ ភាគរយនៃស្ត្រីបានប្តូរទីតាំងដើម្បីដោះស្រាយបញ្ហាការធ្លាក់ចុះនៃការចាប់ត្រី ប៉ុន្តែ ២៦ ភាគរយនៃបុរសបានអនុវត្តយុទ្ធសាស្ត្រនេះ។ ដើម្បីកាត់បន្ថយផលប៉ះពាល់ ការចាប់ត្រីលើការបាត់បង់ជីវចម្រុះសមុទ្រ និងជីវិតទឹកផ្សេងៗ ការអនុវត្តវិធានការការចាប់ត្រី ដូចជា ការកំណត់បរិមាណចាប់ និងការហាមឃាត់វិធីចាប់ត្រីដែលធ្វើឲ្យខូចខាត គឺមានសារៈសំខាន់ខ្លាំង។នៅពេលបានសួរថា តើគាត់បានតាមដាន និងត្រួតពិនិត្យបរិមាណត្រីតាមរយៈការមើលព័ត៌មានផ្លូវការអំពីស្ថានភាពបរិមាណត្រីមុនពេលជ្រើសរើសទីតាំងនេសាទ ឬអត់ មានតែស្ត្រី២ ភាគរយ និង បុរស៥ ភាគរយនៃ បានអនុវត្តន៍វា។ បន្ថែមពីនេះ ក៏មានតែតិចជាង ១ ភាគរយនៃអ្នកនេសាទទទួលខុសត្រូវ លើការរាយការណ៍ពីបរិមាណត្រីដែលនេសាទបានសរុបតាមប្រភេទ។ ជំហានទាំងនេះមានសារៈសំខាន់សម្រាប់តាមដាន និងរក្សាបរិមាណត្រី អ្នកនេសាទត្រូវតែធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរជាតិក្នុងការធានាថាវិធានការដែលមានស្រាប់ត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ និងការរាយការណ៍ជាប្រចាំ។ ប្រទេសកម្ពុជាកំពុងមានតំបន់ការពារសត្វទឹកជំទូលាយ និងទីកន្លែងសង្គ្រោះសត្វព្រៃទឹកផ្សេងៗ។ ការតាមដាន និងពង្រីកតំបន់ទាំងនេះ រួមទាំងការពារសហគមន៍រមណីយដ្ឋានទន្លេ និងបឹង គឺជាជំហានសំខាន់ក្នុងការផ្សព្វផ្សាយការអភិរក្សកាន់តែប្រសើរ។

## ៦.ចាប់ពីការងារសេដ្ឋកិច្ចបៃតង ការគ្រប់គ្រងសំណល់ និងការដឹកជញ្ជូន ប្រជាជនតំបន់ទីប្រជុំជនមានការចូលរួមយ៉ាងសំខាន់ក្នុងការការអភិរក្សបរិស្ថាន និងកាបំផ្លាញបរិស្ថាន ការលើកកម្ពស់ការអប់រំផ្នែកបរិស្ថាន និងបច្ចេកទេសអាចជួយបង្កើនការផ្លាស់ប្តូរដល់សេដ្ឋកិច្ចបៃតង

នៅកម្ពុជា ស្ត្រីប្រមាណ ៣ភាគរយ និង បុរស៤ភាគរយ មានការងារបៃតងយ៉ាងហោចណាស់មួយ។ ភាគច្រើនការងារនេះមិនមែនជាការងារចម្បងរបស់គាត់ទេ ប៉ុន្តែការចូលរួមក្នុងការអភិរក្សបរិស្ថានក្នុងទ្រង់ទ្រាយណាមួយក៏គួរឱ្យលើកទឹកចិត្តដែរ។ ប្រភេទការងារបៃតងដែលមានសក្តានុពលខ្ពស់ និងត្រូវបានអនុវត្តយ៉ាងទូលំទូលាយ រួមមានសកម្មភាពនៃការកាត់បន្ថយ និងការគ្រប់គ្រងកាកសំណល់ និងឧស្ម័នបំពុលដែលបញ្ចេញទៅបរិយាកាស ព្រមទាំងការផលិត និងការគ្រប់គ្រងថាមពលដែលបានផលិតចេញពីប្រភពថាមពលកកើតឡើងវិញ។ ការងារបៃតងភាគច្រើនកើតមានឡើងតំបន់ជិតទីប្រជុំជន ដែលបញ្ជាក់ថា ទីក្រុងអាចធ្វើជាចលករសំខាន់សម្រាប់វឌ្ឍនភាពបរិស្ថាន ទោះយ៉ាងណា ទីក្រុងក៏ជាអ្នកចូលរួមចំណែកដ៏សំខាន់ក្នុងការបំពុលខ្យល់ ដី និងទឹកផងដែរ។ នៅតំបន់ទីប្រជុំជនសំខាន់ៗនៅកម្ពុជា ស្ត្រីមានអត្រាច្រើនជាងបុរសបានចូលរួមក្នុងសកម្មភាពប្រមូលកាកសំណល់ និងនាំវាទៅកាន់កន្លែងញែក ឬដំណើរការកែច្នៃឡើងវិញ (ស្ត្រី ៧ភាគរយ ប្រៀបធៀបទៅបុរសនឹង៥ភាគរយ)។ ទោះបីពួកគាត់មានតួនាទីសំខាន់ក្នុងការអភិរក្សបរិស្ថាន ក៏ដោយ គាត់តែងតែប្រឈមមុខនឹងបញ្ហាសុខភាព សុវត្ថិភាព និងទទួលបានអយុត្តិធម៌ប្រាក់ចំណូល។ ឧទាហរណ៍ មានស្ត្រីចំនួន១៧ភាគរយមានការងារជាប់ទាក់ទងនឹងការគ្រប់គ្រងកាកសំណល់ បានបញ្ជាក់ថា មានអ្នកដទៃទទួលបានប្រាក់ឈ្នួលខ្ពស់ជាង ពេលទោះបីជាពួកគាត់រកបានឬមានវត្ថុធាតុដើមមានតម្លៃខ្ពស់ដូចជា ដែកចាស់ និងអាលុយមីញ៉ូម ច្រើនជាងបុរសក៏ដោយ។ លើសពីនេះទៅទៀត ស្ត្រីមានច្រើន ដែលខ្វះឧបករណ៍ឯកទេសសម្រាប់ប្រើប្រាស់ (មានតែ ៣ភាគរយប៉ុណ្ណោះនៃស្ត្រីប្រមូលកាកសំណល់ដោយប្រើរទេះ ឬកង់ ប្រៀបធៀបទៅនឹង ១១ភាគរយនៃបុរស និងមានតែ ៧ភាគរយប៉ុណ្ណោះទេដែលប្រើឧបករណ៍ការពារ)។ ការធ្វើដំណើររៀងរាល់ថ្ងៃនៅក្នុងតំបន់ទីប្រជុំជន ក៏បានចូលរួមចំណែកយ៉ាងសំខាន់មួយនៃការបំពុលអាកាសផងដែរ។ នៅកម្ពុជា ស្ត្រីចំនួន៨៥ភាគរយ និងបុរសចំនួន៨៨ ភាគរយប្រើយានជំនិះផ្ទាល់ខ្លួន ខណៈស្ត្រី ១១ភាគរយ និងបុរស៨ភាគរយ ប៉ុណ្ណោះដែលប្រើប្រាស់យានជំនិះ សាធារណៈ។ យ៉ាងណាមិញ មនុស្សភាគច្រើនដែលប្រើប្រាស់មធ្យោបាយសាធារណៈ ពឹងផ្អែកលើសេវាតាក់ស៊ី (៤២ភាគរយនៃស្ត្រី និង៦៥ភាគរយនៃបុរស) បន្ទាប់មកគឺម៉ូតូ។ មានតែ២៣ភាគរយប៉ុណ្ណោះនៃអ្នកប្រើប្រាស់យានសាធារណៈដែលជ្រើសរើសសេវារួមគ្នាច្រើនដូចជារថយន្តក្រុង និងរថយន្តដឹកជញ្ជូន ដែលអាចជួយកាត់បន្ថយការបំពុលអាកាស។ ការលើកកម្ពស់ភាពអាចរកបាន និងសុវត្ថិភាពនៃការដឹកជញ្ជូនសាធារណៈអាចរួមចំណែកដល់ការកាត់បន្ថយកម្រិតនៃការបំពុល ប៉ុន្តែអាចសម្រេចបានលទ្ធផលប្រសើរបើមានការចូលរួមជាមួយនឹងការផ្លាស់ប្តូរទស្សនៈ និងអាកប្បកិរិយា ដើម្បីលើកកម្ពស់ការអនុវត្តប្រកបដោយនិរន្តរភាពបន្ថែមទៀត។ឧទាហរណ៍ ការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំ បណ្តុះបណ្តាល និងការយល់ដឹងពីបរិស្ថាន អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយកាកសំណល់ ការលើកកម្ពស់ការចែករំលែកមធ្យោបាយសម្រាប់ការធ្វើដំណើរប្រចាំថ្ងៃ និងបង្កើនសមត្ថភាពដល់ប្រជាជនកម្ពុជា ដើម្បីចូលរួមក្នុងការងារបៃតង ដែលអាចជួយឲ្យផ្លាស់ប្តូរឆ្ពោះទៅរកសេដ្ឋកិច្ចការបំភាយឧស្ម័នទាប។

## ៧.ការចូលរួមការធ្វើសេចក្តីសម្រេចចិត្តអំពីបរិស្ថាននៅតែមានការកំណត់។ ការលើកកម្ពស់ការសម្រេចចិត្តឱ្យមានការចូលរួមយ៉ាងទូលំទូលាយគឺមានសារៈសំខាន់ដើម្បីសម្រេចបានដំណោះស្រាយប្រកបដោយចីរភាព

ប្រជាលរដ្ឋកម្ពុជាមានតិចតួច ដែលបានចូលរួមក្នុងដំណើរការការធ្វើសេចក្តីសម្រេចចិត្តផ្លូវការពាក់ព័ន្ធនឹងបរិស្ថាន ។ ឧទាហរណ៍ ប្រហែល ៦ ភាគរយនៃអ្នកយកទឹកចូលរួមក្នុងគណៈកម្មាធិការគ្រប់គ្រងទឹក និងមានតែ ស្ត្រី៤ ភាគរយ និង បុរស៧ ភាគរយ ដែលប្រមូលផលិតផលព្រៃដែលបានចូលរួមក្នុងក្រុមសហគមន៍ គ្រប់គ្រងដី និងព្រៃ ។ភាគរយនៃការចូលរួមនៅក្នុងការគ្រប់គ្រងវិស័យត្រីក្រម ឬដំណើរការដែលពាក់ព័ន្ធនឹងអាកាសធាតុមានទំនងថាតិចជាង។ ដោយសារតែហេតុនេះ ការសម្រេចចិត្តគ្រប់គ្រងបរិស្ថានអាចមិនត្រូវបានបញ្ចេញដោយផ្អែកលើតម្រូវការរបស់មនុស្សគ្រប់គ្នា។ នៅលើកម្រិតបុគ្គល សំណាក់មនុស្សជាច្រើនដែលប្រើប្រាស់ធនធានបរិស្ថានជារៀងរាល់ថ្ងៃ ក៏ប្រឈមមុខនឹងឧបសគ្គក្នុងការចូលរួមក្នុងការសម្រេចចិត្តពាក់ព័ន្ធ។ មានការចូលរួមក្នុងការគ្រប់គ្រងវិស័យជនផល  និងដំណើរការពាក់ព័ន្ធនឹងអាកាសធាតុនៅមានកម្រិតទាបនៅឡើយ ។ ដូច្នេះការសម្រេចចិត្តក្នុងការគ្រប់គ្រងបរិស្ថាន អាចមិនឆ្លុះបញ្ចាំងពីតម្រូវការរបស់មនុស្សគ្រប់គ្នា។ នៅកម្រិតបុគ្គល ភាគច្រើននៃអ្នកដែលប្រើប្រាស់ធនធានបរិស្ថានជាទៀងទាត់ក៏ប្រឈមនឹងឧបសគ្គក្នុងការរួមចំណែកដល់ការសម្រេចចិត្តដែលពាក់ព័ន្ធផងដែរ។ ជាឧទាហរណ៍ ការសម្រេចចិត្តជុំវិញការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងជីការទិញ ឬលក់ផលិតផល និងសត្វពាហនៈ ជាទូទៅស្ថិតនៅក្នុងដៃម្ចាស់កម្មសិទ្ធិលើធនធានបរិស្ថាន មិនមែនជាអ្នកប្រើប្រាស់ធនធាននោះជារៀងរាល់ថ្ងៃទេ។ អ្នកប្រើប្រាស់ប្រចាំក៏អាចជាជម្រើសសមហេតុផលក្នុងការធ្វើសេចក្តីសម្រេចប្រកបដោយចីរភាព ដើម្បីការពាររបររស់នៅ និងសុខភាពផ្ទាល់ខ្លួនរបស់ពួកគាត់។ខណៈដែលកសិកសរស្មើរគ្រប់រូបដែលកាន់កាប់ត្រាក់ទ័រ  នង្គ័ល និងទ្រព្យសម្បត្តិកសិកម្មផ្សេងទៀត មានសិទ្ធិសម្រេចចិត្តអំពីការទិញ និងលក់ផលិតផលកសិកម្មក៏ដោយមាន ស្ត្រី៨៣ ភាគរយ និងបុរស៩៧ ភាគរយ ដែលមិនកាន់កាប់ទ្រព្យសម្បត្តិទាំងនោះប៉ុន្តែអនុវត្តសេចក្តីសម្រេចពាក់ព័ន្ធជាប្រចាំ។ស្រដៀងគ្នានេះផងដែរ មានច្រើនជាង ៩៥ ភាគរយនៃអ្នកកាន់កាប់ដីធ្លីដែលអនុវត្តសេចក្តីសម្រេចពាក់ព័ន្ធ ខណៈដែលមានតិចជាង ៨៤ ភាគរយនៃអ្នកមិនកាន់កាប់ដីធ្លីប៉ុណ្ណោះដែលបានចូលរួមសម្រេចចិត្ត។ នៅកម្ពុជា មានតែស្ត្រី៦៤ ភាគរយ និងបុរស៦៣ ភាគរយប៉ុណ្ណោះ ដែលកាន់កាប់ដីកសិកម្មដែលគាត់ប្រើប្រាស់។ ការលើកកម្ពស់កាន់កាប់កម្មសិទ្ធលើដីកសិកម្ម និងទ្រព្យសម្បត្តិផ្សេងៗ អាចរួមចំណែកពង្រីកការចូលរួមក្នុងការគ្រប់គ្រងធនធានទាំងនេះដោយមានចីរភាព។ ការផ្តល់អំណាចឲ្យប្រជាជនចូលរួមក្នុងដំណើរការសម្រេចចិត្តទាំងផ្លូវការ និងក្រៅផ្លូវការនេះ អាចនាំឱ្យមាន ឥទ្ធិពលយ៉ាងសំខាន់លើការអភិរក្សបរិស្ថានប្រកបដោយចីរភាពក្នុងរយៈពេលវែង។"

UN WOMEN

WOMEN COUNT

NIS
National Institute of Statistics